# សិទ្ធិទទួលបានការអប់រំ
# នៅប្រទេសកម្ពុជា
## ការសិក្សាកម្រិតសហគមន៍





ការស្រាវជ្រាវផ្តួចផ្តើមដោយ ៖

VSO

UNESCO
United Nations
Educational, Scientific and
Cultural Organization

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

ខែមីនា ឆ្នាំ២០១៤

# សិទ្ធិទទួលបានការអប់រំក្នុងប្រទេសកម្ពុជា

# ការស្រាវជ្រាវកម្រិតសហគមន៍




ការផ្តួចផ្តើមស្រាវជ្រាវរួមគ្នាមួយដែលធ្វើឡើងដោយ ៖

VSO

UNESCO
United Nations
Educational, Scientific and
Cultural Organization

NGO EDUCATION PARTNERSHIP

ខែមីនា ឆ្នាំ២០១៤

# មាតិកា


សេចក្ដីថ្លែងអំណរគុណ ........ 5
១. សេចក្ដីផ្ដើម ........ 20
២. វិធីសាស្ត្រ ........ 21
២.១. ទីតាំងសំណាក ........ 21
២.២ កិច្ចសម្ភាសន៍ ព្រមទាំងទំហំ និងការជ្រើសរើសក្រុមពិភាក្សា ........ 21
២.៣. ក្រុមប្រឹក្សាយោបល់សម្រាប់ការស្រាវជ្រាវ ........ 24
៣. ការវិភាគទៅលើស្ថានភាពបច្ចុប្បន្ន និងភស្តុតាងដែលមានស្រាប់ ........ 24
៣.១. ការទទួលបានការអប់រំ ........ 24
៣.២. គុណភាពនៃការអប់រំ ........ 31
៤. លទ្ធផលរកឃើញ និងការវិភាគ ........ 34
៤.១. វត្តមាន និងលទ្ធភាពទទួលបានសេវាអប់រំ ........ 34
*៤.១.១. កត្តាដែលបង្កផលប៉ះពាល់ទៅលើលទ្ធភាពទទួលបានសេវា* ........ 35
*៤.១.២. សម្ភារៈរៀនសូត្រ* ........ 37
*៤.១.៣. ឯកសណ្ឋានសាលារៀន* ........ 38
៤.១.៤. មធ្យោបាយធ្វើដំណើរ និងរយៈចម្ងាយទៅសាលារៀន ........ 38
៤១.៥. គ្រូបង្រៀន ៖ បរិមាណ គុណភាព និងឥរិយាបថ ........ 40
៤.១.៦. ទឹកស្អាត និងបង្គន់អនាម័យ បរិស្ថាន និងអគារសាលារៀន ........ 41
៤.១.៧. ឥរិយាបថរបស់សិស្ស ........ 41
៤.១.៨. ឥរិយាបថរបស់ឪពុកម្ដាយ ........ 42
៤.១.៩. ធ្វើការនៅឯផ្ទះ ឬ ធ្វើការដើម្បីរកប្រាក់ ........ 43
៤.១.១០. ភាពក្រីក្រ និងកង្វះឱកាសសម្រាប់ចំណាយនៅឯសាលារៀន ........ 44
៤.១.១១. កុមារពិការ ........ 46
៤.១.១២. កុមារក្រុមជនជាតិដើមភាគតិច ........ 50
៤.១.១៣. ការប្រៀបធៀបការរៀនរបស់កុមារ ឆ្នាំ២០០៨ - ២០១៣ ........ 52
៤.២. ភាពអាចទទួលយកបាននៃសេវាអប់រំ ........ 53
៤.២.១. ទស្សនៈរបស់សិស្សចំពោះគ្រូបង្រៀន ........ 54
៤.២.២. ការផ្ដត់ផ្ដង់ និងតម្រូវការរបស់គ្រូ ........ 55
៤.២.៣. សិស្សត្រូវទទួលខុសត្រូវចំពោះការរៀនសូត្ររបស់ពួកគេ ........ 56
៤.២.៤. សៀវភៅមេរៀន និងសម្ភារៈបង្រៀន ........ 57
៤.២.៥. ការផ្ដល់តម្លៃចំពោះការអប់រំ ........ 57
៤.២.៦. ការប្រព្រឹត្តមិនស្មើភាពគ្នាចំពោះសិស្ស ........ 57
៤.៣. ភាពបត់បែននៃការអប់រំ ........ 59

៤.៣.១. ភាពបត់បែននៃការអប់រំទៅតាមសេចក្តីត្រូវការរបស់កុមារពិការ........................................ 59
៤.៣.២. ភាពបត់បែននៃការអប់រំទៅតាមសេចក្តីត្រូវការរបស់ក្រុមជនជាតិដើមភាគតិច........................ 62
៤.៣.៣. មាតិកាបង្រៀន និងកម្មវិធីសិក្សា.............................................................................. 64
៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ............................................................................... 66
៥.១. សេចក្តីសន្និដ្ឋាន ....................................................................................................... 66
៥.១.១. ការមានសេវា និងលទ្ធភាពទទួលបានសេវា ................................................................. 66
៥.១.២.ភាពអាចទទួលយកបាន................................................................................................. 69
៥.១.៣.លទ្ធភាពសម្រប ......................................................................................................... 71
៥.២. អនុសាសន៍ ............................................................................................................... 72
៦. ឧបសម្ព័ន្ធ.................................................................................................................... 74
ឧបសម្ព័ន្ធ១ ៖ ការចូលរៀនលើសអាយុ និងការចុះឈ្មោះចូលរៀនពិតនៅកម្រិតបឋមសិក្សា.................. 74
ឧបសម្ព័ន្ធ២ ............................................................................................................... 75

បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ASPBAE | : | សមាគមអាស៊ីប៉ាស៊ីហ្វិកភាគខាងត្បូងសម្រាប់ការអប់រំមូលដ្ឋាននិងមនុស្សពេញវ័យ |
| CWDCC | : | មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា |
| CSEF | : | មូលនិធិអប់រំសង្គមស៊ីវិល |
| CSES | : | ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជា |
| DOE | : | ការិយាល័យអប់រំស្រុក |
| EMIS | : | ប្រព័ន្ធគ្រប់គ្រងពត៌មានអប់រំ |
| FGD | : | ក្រុមពិភាក្សា |
| KAPE | : | អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា |
| KHR | : | ខ្មែររៀល |
| LSS | : | សាលាមធ្យមសិក្សាបឋមភូមិ |
| MoEYS | : | ក្រសួងអប់រំ យុវជន និង កីឡា |
| NUT | : | សហជីពគ្រូបង្រៀនជាតិនៃចក្រភពអង់គ្លេស |
| NER | : | អត្រាចុះឈ្មោះចូលរៀនពិត |
| NGO | : | អង្គការមិនមែនរដ្ឋាភិបាល |
| NEP | : | ភាពជាដៃគូរអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NTFP | : | អង្គការអនុផលព្រៃឈើ |
| POE | : | មន្ទីរអប់រំខេត្ត |
| RTE | : | សិទ្ធិទទួលបានការអប់រំ |
| RUPP | : | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| UN | : | អង្គការសហប្រជាជាតិ |
| UNESCO | : | អង្គការសហប្រជាជាតិសម្រាប់ការអប់រំវិទ្យាសាស្ត្រ និង វប្បធម៌ |
| WFP | : | កម្មវិធីស្បៀងអាហារពិភពលោក |

# សេចក្តីថ្លែងអំណរគុណ

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) សូមថ្លែងអំណរគុណចំពោះនាយកសាលា គ្រូបង្រៀន សិស្ស កុមារពិការ កុមារជនជាតិដើមភាគតិច និងឪពុកម្តាយទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធសម្រាប់ការស្រាវជ្រាវនេះ។ សូមថ្លែងអំណរគុណជាពិសេសចំពោះតំណាងមកពីសាលារៀនទទួលរ៉ាយ អង្គការ CWDCC, KAPE និង NTFP ដែលបានសម្របសម្រួលឱ្យកុមារពិការ កុមារជនជាតិដើមភាគតិច និងឪពុកម្តាយរបស់ពួកគេបានចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់។ NEP សូមកោតសរសើរចំពោះលោក យិនសៀង សូម៉េត មន្ត្រីកម្មវិធីជាតិនៃអង្គការយូណេស្កូការិយាល័យប្រចាំរាជធានីភ្នំពេញសម្រាប់ការចូលរួមដ៏ថ្លៃថ្លារបស់លោក ចំពោះការប្រមូលទិន្នន័យក្នុងខេត្តកំពត។

NEP ក៏សូមថ្លែងអំណរគុណផងដែរ ចំពោះអ្នកប្រមូលទិន្នន័យទាំងអស់ដែលបានប្រមូលព័ត៌មានយ៉ាងសកម្មពីមូលដ្ឋាន។

NEP សូមសម្តែងការដឹងគុណដល់សមាជិកគ្រប់រូបនៃក្រុមប្រឹក្សាយោបល់សម្រាប់ការស្រាវជ្រាវដែលបានចំណាយពេលវេលាដ៏មមាញឹករបស់ពួកគេដើម្បីចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាយោបល់សម្រាប់ការស្រាវជ្រាវព្រមទាំងផ្តល់មតិយោបល់ និងធាតុចូលប្រកបដោយភាពស្ថាបនាចាប់តាំងពីពេលដំបូងរហូតដល់ចុងបញ្ចប់នៃវដ្តស្រាវជ្រាវ។ ការរួមចំណែករបស់ពួកគេបានជួយឱ្យ NEP ផលិតបាននូវរបាយការណ៍ស្រាវជ្រាវពាក់ព័ន្ធ និងគ្រប់ជ្រុងជ្រោយមួយសម្រាប់អង្គការ វីអេសអូ និងយូណេស្កូ។ យើងខ្ញុំសូមថ្លែងអំណរគុណដល់លោក Hervé Roqueplan នៃអង្គការគ្រួសារថ្មី និងលោក Jan Noorlander នៃអង្គការឃែរចំពោះវិភាគទានប្រកបដោយអត្ថន័យរបស់ពួកគេទាក់ទងនឹងអន្តរាគមន៍ដើម្បីជួយដល់កុមារពិការ និងកុមារជនជាតិដើមភាគតិចព្រមទាំងការផ្តល់មតិយោបល់ទៅលើរបាយការណ៍ស្រាវជ្រាវនេះ។ សូមថ្លែងអំណរគុណផងដែរចំពោះ លោក ជិន ច័ន្ទវ៉ាសនា នាយកប្រតិបត្តិនៃអង្គការ NEP សម្រាប់ការផ្តល់មតិយោបល់ និងការត្រួតពិនិត្យកែសម្រួលរបាយការណ៍នេះ។

សូមថ្លែងអំណរគុណជាពិសេសចំពោះការអង្គការ VSO , NUT , យូណេស្កូ Misereor និង CSEF សម្រាប់កិច្ចគាំទ្រហិរញ្ញវត្ថុរបស់ពួកគេដើម្បីធ្វើឱ្យការសិក្សាស្រាវជ្រាវនេះអាចប្រព្រឹត្តទៅបាន។

## សមាជិកក្រុមប្រឹក្សាយោបល់សម្រាប់ការស្រាវជ្រាវ ៖

លោក ចនហ្វ្រែន គើរីវ៉ា អង្គការ វីអេសអូ
លោក ខាទ្រី សាន់តូស អង្គការយូណេស្កូកម្ពុជា
លោក បណ្ឌិតឈិញ ស៊ីថា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
លោក បណ្ឌិតវ័ត្ន ឆាង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
លោក ហាន ប៊ិនថេង អង្គការអាក់សិនអេតកម្ពុជា
កញ្ញា ហ្វ្រេស ផាក អ្នកស្ម័គ្រចិត្តរបស់សមាគមសហជីពគ្រូបង្រៀន
អ្នកស្រី កែវ រចនា សមាគមសហជីពគ្រូបង្រៀន

កិច្ចគាំទ្រហិរញ្ញវត្ថុដោយ៖

VSO
UNESCO — United Nations Educational, Scientific and Cultural Organization
National Union of Teachers
ASPBAE — Asia South Pacific Association for Basic and Adult Education — Learning Beyond Boundaries
MISEREOR — IHR HILFSWERK

**អង្គការ VSO**

VSO គឺជាអង្គការសប្បុរសធម៌អភិវឌ្ឍន៍អន្តរជាតិនាំមុខគេមួយក្នុងពិភពលោក ដែលធ្វើការងារតាមរយៈអ្នកស្ម័គ្រចិត្តដើម្បីប្រយុទ្ធប្រឆាំងភាពក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ VSO បាននិងកំពុងធ្វើការងារនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩១ មកម្ល៉េះ។ VSO បង្កលក្ខណៈឱ្យមានការជួបជុំគ្នាដើម្បីចែករំលែកជំនាញនិងចំណេះដឹងសំដៅបង្កើតឱ្យមានការផ្លាស់ប្តូរយូរអង្វែង។ អ្នកស្ម័គ្រចិត្តរបស់អង្គការ VSO ធ្វើការងារនៅក្នុងរាល់វិស័យនានា ដែលចាំបាច់ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងកម្លាំងចលករនានាដែលធ្វើឱ្យប្រជាពលរដ្ឋបន្តស្ថិតនៅក្នុងភាពក្រីក្ររាប់ចាប់ពីវិស័យអប់រំ និងសុខាភិបាលរហូតដល់ការជួយដល់ប្រជាពលរដ្ឋឱ្យរៀនសូត្រអំពីជំនាញសម្រាប់ចិញ្ចឹមជីវិត។

**អង្គការយូណេស្កូ ៖**

អង្គការយូណេស្កូមានជំនឿថាសន្តិភាពត្រូវតែត្រូវបានបង្កើតឡើងនៅលើមូលដ្ឋានសាមគ្គីភាព សីលធម៌ និងបញ្ញារបស់មនុស្សជាតិ។ អង្គការយូណេស្កូខិតខំក្នុងការកសាងបណ្តាញក្នុងចំណោមប្រទេសដែលអនុញ្ញាតឱ្យប្រភេទនៃសាមគ្គីភាពនេះដោយៈ

- ការកៀងគរការអប់រំៈដូច្នេះថាកុមារគ្រប់រូបមានលទ្ធភាពទទួលបានការអប់រំដែលមានគុណភាពដែលជាសិទ្ធិមនុស្សជាមូលដ្ឋាន។
- ការកសាងវប្បធម៌នៃការយល់ដឹងគ្នាៈ តាមរយៈការការពារបេតិកភណ្ឌ និងការគាំទ្រសម្រាប់ភាពសម្បូរបែបនៃវប្បធម៌។
- បន្តកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រៈ ដូចជាប្រព័ន្ធប្រកាសអាសន្នសម្រាប់ស៊ូណាមី ឬកិច្ចព្រមព្រៀងគ្រប់គ្រងទឹកឆ្លងកាត់ព្រំដែន។
- ការការពារសេរីភាពនៃការបញ្ចេញមតិៈ ជាលក្ខខណ្ឌចាំបាច់សម្រាប់លទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

**សហជីពគ្រូបង្រៀនជាតិនៃចក្រភពអង់គ្លេស** (NUT)

NUT គឺជាសហជីពមួយធំបំផុតនៃចក្រភពអង់គ្លេសសម្រាប់គ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សាដែលមានលក្ខណៈសម្បត្តិសមស្រប។ NUT គាំទ្រយុទ្ធនាការមួយចំនួនដែលដោះស្រាយបញ្ហាអភិវឌ្ឍន៍អន្តរជាតិក្នុងនោះរួមមានទិវាដឹងគុណគ្រូបង្រៀនរបស់អង្គការ VSO និងយុទ្ធនាការជាសកលសម្រាប់ការអប់រំ។ NUT សហការជាមួយសហជីពនិងអង្គការមិនមែនរដ្ឋាភិបាលនៅ Global South លើគម្រោងដែលមានគោលបំណងផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ជូនដល់កុមារគ្រប់រូបការពារសុខុមាលភាព និងភាពវិជ្ជាជីវៈរបស់គ្រូបង្រៀនព្រមទាំងកសាងសមត្ថភាពរបស់សហជីពគ្រូបង្រៀន។ សកម្មភាពទាំងនេះរួមមានការផ្តល់មូលនិធិគាំទ្រសម្រាប់គម្រោងរយៈពេលខ្លីការផ្តល់ឋវិកាសម្រាប់ការងារស្រាវជ្រាវ និងការធ្វើការងារក្រោមភាពជាដៃគូជាមួយសហជីព ឬអង្គការសង្គមស៊ីវិលលើកម្មវិធីអភិវឌ្ឍន៍រយៈពេលវែង។

## សមាគមអាស៊ីប៉ាស៊ីហ្វិកភាគខាងត្បូងសម្រាប់ការអប់រំមូលដ្ឋាន និងមនុស្សពេញវ័យ (ASPBAE)

សមាគមអាស៊ីប៉ាស៊ីហ្វិកភាគខាងត្បូងសម្រាប់ការអប់រំមូលដ្ឋាន និងមនុស្សពេញវ័យ (ASPBAE) គឺជាសមាគមតំបន់មួយដែលមានអង្គការ និងបុគ្គលជាសមាជិកជាង២០០។ សមាគមនេះធ្វើការងារសំដៅលើកកម្ពស់ការអប់រំប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា ព្រមទាំងលើកកម្ពស់ការអប់រំ និងការរៀនសូត្ររបស់មនុស្សពេញវ័យអស់មួយជីវិតដែលជម្រុញឱ្យមានការផ្លាស់ប្តូរនិងការទទួលយកគំនិតថ្មីៗ។ សមាគមនេះខិតខំពង្រឹងចលនាអាស៊ីប៉ាស៊ីហ្វិកមួយដើម្បីគាំទ្រសហគមន៍ និងអង្គការមហាជនសម្ព័ន្ធអប់រំជាតិ សហជីពគ្រូបង្រៀនបណ្តាញយុទ្ធនាការ និងក្រុមសង្គមស៊ីវិល ព្រមទាំងស្ថាប័នដទៃទៀតក្នុងការធ្វើឱ្យរដ្ឋាភិបាលនិងសហគមន៍ម្ចាស់ជំនួយអន្តរជាតិមានគណនេយ្យភាពក្នុងការសម្រេចបាននូវគោលដៅ និងការប្តេជ្ញាចិត្តចំពោះវិស័យអប់រំ។

**MISEREOR**

MISEREOR គឺជាអង្គការសហប្រតិបត្តិការអភិវឌ្ឍន៍សាសនាកាតូលិកមួយរបស់អាល្លឺម៉ង់។ អស់រយៈពេលជាង៥០ឆ្នាំកន្លងមក MISEREOR បានប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងភាពក្រីក្រនៅទ្វីបអាហ្វ្រិក អាស៊ី និងអាមេរិកឡាទីន។ កិច្ចគាំទ្ររបស់ MISEREOR មានផ្តល់ជូនចំពោះមនុស្សគ្រប់រូប ដែលមានតម្រូវការ ដោយមិនប្រកាន់សាសនា ជាតិពន្ធុ(ជាតិសាសនា) ឬយេនឌ័រឡើយ។ MISEREOR ជឿទៅលើការគាំទ្រចំពោះគំនិតផ្តួចផ្តើមរបស់ជនក្រីក្រ និងជនដែលបាត់បង់ប្រយោជន៍។ ដោយយោងតាមគោលការណ៍នៃការផ្តល់ជំនួយសំដៅធ្វើឱ្យពួកគេអាចជួយខ្លួនឯងបាន។ ជាក់ស្តែងអង្គការមូលដ្ឋានគឺជាអ្នកគ្រប់គ្រងដំណើរការគម្រោងទាំងនោះ។

## សង្ខេប

ការសិក្សាអំពីសិទ្ធិទទួលបានការអប់រំក្នុងប្រទេសកម្ពុជានេះ គឺជាផ្នែកមួយនៃគម្រោងសកលរបស់អង្គការយូណេស្កូ ដើម្បីត្រួតពិនិត្យឡើងវិញទៅលើក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគោលនយោបាយជាតិទាក់ទងទៅនឹងសិទ្ធិទទួលបានការអប់រំ។ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកគម្រោងនេះត្រូវបានសម្របសម្រួលដោយអង្គការយូណេស្កូ ប្រចាំទីក្រុងបាងកកដោយការសិក្សាត្រូវបានធ្វើឡើងក្នុងប្រទេសកម្ពុជា និងប្រទេសថៃក្នុងឆ្នាំ២០១៣។

NEP បានសហការជាមួយអង្គការ VSO និង យូណេស្កូ ដើម្បីធ្វើការស្រាវជ្រាវកម្រិតសហគមន៍អំពីបទពិសោធន៍របស់កុមារទាក់ទងទៅនឹងសិទ្ធិទទួលបានការអប់រំ (RTE) របស់ពួកគេក្នុងគោលបំណងកំណត់រកភាពជោគជ័យ និងបញ្ហាប្រឈមក្នុងការអនុវត្តន៍គោលនយោបាយដែលទាក់ទងទៅ នឹងសិទ្ធិទាំងនេះនៅក្នុងការអប់រំមូលដ្ឋាន(ថ្នាក់ទី១-៩)។ នៅក្នុងប្រទេសកម្ពុជាប្រជាពលរដ្ឋមានសិទ្ធិទទួលបានការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំដោយឥតគិតថ្លៃ។ ការវិភាគបានអនុវត្តតាមក្របខ័ណ្ឌ 4A (លទ្ធភាពទទួលបាន ភាពអាចទទួលយកបាន ការមានសេវា និងលទ្ធភាពសម្រប) ដែលអភិវឌ្ឍដោយសាស្ត្រាចារ្យ Katarina Tomaševski (អតីតអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានការអប់រំ)។

## វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងក្នុងឃុំចំនួន១២ នៃខេត្តចំនួន៣ ដែលរួមមានជាអាទិ៍ រតនគិរី សៀមរាប និងកំពត។ ឃុំទាំងនេះ គឺជាឃុំដែលមានមូលដ្ឋានខុសៗគ្នារួមមាន៖ តំបន់ដាច់ស្រយាលតំបន់ជនបទ និងតំបន់ជាយក្រុង។ ការប្រមូលទិន្នន័យរួមមានក្រុមពិភាក្សាសរុបចំនួន ៤៨ក្រុម ជាមួយឪពុកម្តាយរបស់សិស្សបឋមសិក្សា ឪពុកម្តាយរបស់សិស្សអនុវិទ្យាល័យ សិស្សបឋមសិក្សា និងសិស្សអនុវិទ្យាល័យ។ ក្រុមពិភាក្សានីមួយៗមានអ្នកចូលរួមចន្លោះពី៨នាក់ទៅ១២នាក់។ យើងក៏បានសម្ភាសន៍សរុបចំនួន១២៣នាក់ជាមួយគ្រូបង្រៀនកម្រិតមូលដ្ឋាន កុមារដែលបានបោះបង់ការសិក្សា និងកុមារដែលមិនធ្លាប់បានចូលរៀន។ បន្ថែមពីនេះទៀតយើងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយជាពិសេសជាមួយកុមារពិការ កុមារជនជាតិដើមភាគតិច និងឪពុកម្តាយរបស់ពួកគេព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាល (អ្នកចូលរួមសរុបចំនួន៣៤នាក់)។

ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការស្រាវជ្រាវមួយក្រុមរួមមានសមាជិក៦រូបមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ អង្គការយូណេស្កូប្រចាំប្រទេសកម្ពុជា អង្គការ VSO កម្ពុជា អង្គការ Action Aid និងសហជីពគ្រូបង្រៀន។ សមាជិកក្រុមបានផ្តល់មតិយោបល់ត្រឡប់ និងជាតុចូលនៅគ្រប់ដំណាក់កាលសំខាន់ៗទាំងអស់នៃការស្រាវជ្រាវដើម្បីធានាថាការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងស្របតាមល័ក្ខខ័ណ្ឌតម្រូវរបស់អង្គការយូណេស្កូ និងអង្គការ VSO ប្រចាំប្រទេសកម្ពុជា។

## ការវិភាគទៅលើស្ថានភាពបច្ចុប្បន្ន និងឥស្សុភាពដែលមានស្រាប់

*ការទទួលបានសេវាអប់រំ*

ស្ថិតិផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បង្ហាញឱ្យដឹងថា អត្រាចុះឈ្មោះចូលរៀនពិត (NER) នៅសាលាបឋមសិក្សា (ថ្នាក់ទី១-៦) មានកម្រិត ៩៧% ក្នុងឆ្នាំ២០១២-២០១៣[1]។ យ៉ាងណាមិញស្ថិតិដែលប្រមូលដោយក្រសួងដទៃទៀត បង្ហាញឱ្យឃើញថា អត្រាចុះឈ្មោះចូលរៀនពិតនៅកម្រិតបឋមសិក្សាមានចំនួនប្រមាណ ៨៥%[2]។ ការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ (ថ្នាក់ទី៧-៩) នៅតែបន្តជាបញ្ហាប្រឈមអាស្រ័យដោយ NER មានកម្រិតត្រឹម ៣៧,៨%[3] ប៉ុណ្ណោះក្នុងឆ្នាំសិក្សា ២០១២-២០១៣។ លើសពីនេះទៀតអត្រាបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យនៅតែបន្តមានកម្រិតខ្ពស់រហូតដល់ ២០% ក្នុងឆ្នាំសិក្សា ២០១១ -២០១២។[4]

ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានសាងសង់សាលាបឋមសិក្សាថ្មីចំនួន៣៤៥ខ្នង និងសាលាអនុវិទ្យាល័យថ្មីចំនួន៤២ខ្នងនៅចន្លោះឆ្នាំសិក្សា ២០០៩-២០១០ និង ឆ្នាំ ២០១២-២០១៣ ដោយសាលារៀនប្រមាណពាក់កណ្ដាលត្រូវបានសាងសង់នៅតំបន់ជនបទ និងពាក់កណ្ដាលទៀតនៅតំបន់ទីក្រុង។[5]

ក្រសួងអប់រំ យុវជន និងកីឡា កម្មវិធីស្បៀងអាហារពិភពលោក (WFP) និងអង្គការមិនមែនរដ្ឋាភិបាលបានផ្តល់អាហារូបករណ៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពក្នុងការទទួលបានការអប់រំ និងកាត់បន្ថយការបោះបង់ការសិក្សាជាពិសេសនៅក្នុងចំណោមកុមារងាយរងគ្រោះ។ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់អាហារូបករណ៍ដែលមានតម្លៃ ៤៥ដុល្លា[6] ក្នុងមួយឆ្នាំជូនដល់សិស្សអនុវិទ្យាល័យចំនួន ៥៦.៤៧៧នាក់។ អត្រាបោះបង់ការសិក្សារបស់សិស្សអាហារូបករណ៍នៅថ្នាក់ទី៧ និងថ្នាក់ទី៨ ក្នុងឆ្នាំសិក្សា ២០១២-២០១៣ មានចំនួនតិចជាងពាក់កណ្ដាលនៃអត្រាបោះបង់ការសិក្សាទូទាំងប្រទេសក្នុងឆ្នាំសិក្សាឆ្នាំ ២០១១-២០១២ ប៉ុន្តែពុំមានផលប៉ះពាល់សម្រាប់ថ្នាក់ទី៩ ឡើយ[7]។

---

[1]នាយកដ្ឋានផែនការ (២០១៣) ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣។ ក្រសួងអប់រំ យុវជន និងកីឡា ៖ ភ្នំពេញ។

[2]ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា បានរាយការណ៍ឱ្យដឹងអំពីអត្រា NER នៅកម្រិតបឋមសិក្សា មានចំនួន ៨៤,៣% ក្នុងឆ្នាំ២០១២ ហើយមូលដ្ឋានទិន្នន័យឃុំបានរាយការណ៍ថា NER បឋមសិក្សាមានចំនួន ៨៧,៩% ក្នុងឆ្នាំ២០១១ ទិន្នន័យទាំងពីរនេះ ត្រូវបានចងក្រងដោយក្រសួងផែនការ។

[3]តួលេខនេះ ត្រូវបានដកស្រង់ពីបទបង្ហាញមួយ ដែលធ្វើឡើងដោយ Peter De Vries ប្រធានផ្នែកអប់រំនៃអង្គការយូនីសេហ្វ ប្រចាំប្រទេសកម្ពុជា នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ នៅក្នុងកិច្ចប្រជុំមួយរបស់ក្រុមការងារវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា មិនបានរាយការណ៍អំពី NER ក្នុងឆ្នាំសិក្សា២០១២-២០១៣ សម្រាប់ LSS នៅក្នុងស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣ ឡើយ។ ក្នុងឆ្នាំសិក្សា ២០១១-២០១២ គេបានរាយការណ៍ឱ្យដឹងថា LSS មានចំនួន ៣៥,១% ។

[4]នាយកដ្ឋានផែនការ (២០១៣) *ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣*។ ក្រសួងអប់រំ យុវជន និងកីឡា ៖ ភ្នំពេញ។

[5]នាយកដ្ឋានផែនការ (២០១៣) *ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣*។ ក្រសួងអប់រំ យុវជន និងកីឡា ៖ ភ្នំពេញ។

[6]រាល់រូបិយប័ណ្ណដុល្លាទាំងអស់ សំដៅចំពោះដុល្លាសហរដ្ឋអាមេរិក។ ៤០០០រៀល មានតម្លៃប្រហាក់ប្រហែល១ដុល្លា។

[7]ដកស្រង់ពីបទបង្ហាញមួយដែលមានចំណងជើងថា "កម្មវិធីអាហារូបករណ៍សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា" ដែលត្រូវបានបង្ហាញនៅក្នុងដំណើរទស្សនកិច្ចពិភាក្សាប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាមួយដៃគូអភិវឌ្ឍន៍ ថ្ងៃទី២៣ រហូតដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៤។

កម្មវិធីស្បៀងអាហារពិភពលោកបាន និងកំពុងអនុវត្តកម្មវិធីអាហារូបករណ៍អស់រយៈពេលជិត១០ឆ្នាំមកហើយ។ នៅក្នុងឆ្នាំសិក្សា ២០១២-២០១៣ កម្មវិធីអាហារូបករណ៍ទាំងនេះបានគ្របដណ្តប់សិស្សអាហារូបករណ៍ចំនួន ៩៧.០០០នាក់ (៨៨.០០០នាក់ ទទួលបានស្បៀងអាហារ និង ៩.០០០នាក់ ទទួលបានសាច់ប្រាក់)។ កម្មវិធីអាហារូបករណ៍សាច់ប្រាក់ផ្តល់ថវិកាចំនួន៥០ដុល្លា ក្នុងមួយឆ្នាំសម្រាប់កុមារដែលកំពុងសិក្សាចន្លោះពីថ្នាក់ទី៤-៦ ហើយអត្រាបោះបង់ការសិក្សាមានចំនួន ២,៣៧% ដែលទាបជាងអត្រាបោះបង់ការសិក្សាថ្នាក់ជាតិ បើទោះបីជាក្រុមនេះស្ថិតនៅក្នុងចំណោមក្រុមកុមារដែលគេរំពឹងថាមានកម្រិតបោះបង់ការសិក្សាខ្ពស់ជាងអត្រាបោះបង់ការសិក្សាជាមធ្យមក៏ដោយ[8]។

ឧបសគ្គមួយដែលអាចរាំងស្ទះដល់ការទទួលបានសេវាអប់រំ អាចជាវត្តមាននៃការបង់ថ្លៃសាលារៀនក្រៅផ្លូវការ។ នៅក្នុងការស្រាវជ្រាវកន្លងមករបស់ NEP[9] បានឱ្យដឹងថា អ្នកផ្តល់ចម្លើយជាសិស្សចំនួន ៥៣% និងឪពុកម្តាយចំនួន ៦៧% បានប្រាប់ថាពួកគេត្រូវបង់ថ្លៃចំណាយសម្រាប់អ្វីដែលគេរំពឹងថា ជាការទទួលខុសត្រូវរបស់សាលារៀន និងក្រសួងអប់រំ យុវជន និងកីឡា ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម។

*តារាងទី១ ៖ ការបង់ថ្លៃសាលារៀនក្រៅផ្លូវការ*

| ប្រភេទនៃចំណាយ | ការឆ្លើយតបរបស់សិស្ស ៖ ចំណាយជាមធ្យម (រៀល) | ការឆ្លើយតបរបស់ឪពុកម្តាយ ៖ ចំណាយជាមធ្យម (រៀល) |
|---|---|---|
| សម្ភារៈរៀនសូត្ររបស់គ្រូបង្រៀន | 1400 ក្នុងមួយពេល | 6870 ក្នុងមួយពេល |
| ថ្លៃផ្ញើកង់ | 2860 ក្នុងមួយខែ | ទិន្នន័យមិនបានផ្តល់ត្រឡប់មកវិញ |
| ថ្លៃប្រឡង | 2300 ក្នុងមួយពេល | 2500 ក្នុងមួយពេល |
| ថ្លៃរៀនគួក្នុងសាលារៀន | 12500 ក្នុងមួយខែ | 12,480 ក្នុងមួយខែ |
| ថ្លៃរៀនគួក្រៅសាលារៀន | 18400 ក្នុងមួយខែ | 16410 ក្នុងមួយខែ |
| ក្រដាសមេរៀនរបស់គ្រូ | 1800 ក្នុងមួយពេល | 3090 ក្នុងមួយពេល |
| ថ្លៃគ្រូបង្រៀន | 13200 ក្នុងមួយខែ | 16200 ក្នុងមួយខែ |
| ប័ណ្ណសរសើរ | 1200 ក្នុងមួយខែ | 1100 ក្នុងមួយខែ |
| អំណោយសម្រាប់គ្រូបង្រៀន | 6800 ក្នុងមួយឆ្នាំ | |
| ចំណាយដទៃទៀត | 1200 ក្នុងមួយពេល | 6740 ក្នុងមួយពេល |

[8]កម្មវិធីស្បៀងអាហារពិភពលោក *គំហើញពីការប៉ាន់ប្រមាណឆាប់រហ័សមួយ ស្តីពីការអនុវត្តន៍សាកល្បងកម្មវិធីអាហារូបករណ៍សាច់ប្រាក់ថ្មីជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ AMK។ មិនទាន់បោះពុម្ពផ្សាយនៅឡើយ។*

[9]Ang, S. & Conochie, G. (2012). *ការលើកកម្ពស់សិទ្ធិនៅក្នុងសាលារៀន* អង្គការ NEP ភ្នំពេញ។

*គុណភាពនៃការអប់រំ*

សម្រាប់ការត្រួតពិនិត្យឡើងវិញនេះ យើងបានពិចារណាសូចនាករមួយចំនួនដូចជា អត្រាត្រួតថ្នាក់ ផលធៀបគ្រូសិស្ស សាវតាអប់រំរបស់គ្រូបង្រៀនបានឆ្លងកាត់ការបណ្តុះបណ្តាល គរុកោសល្យ និងការទទួលបានការបណ្តុះបណ្តាលវិក្រឹតការជាសូចនាករនៃគុណភាពអប់រំ។

អត្រាត្រួតថ្នាក់នៅបឋមសិក្សា ក្នុងឆ្នាំសិក្សា២០១២-២០១៣ មានចំនួន ៥,៣% ដែលអត្រានេះបានធ្លាក់ចុះពី៩%ក្នុងឆ្នាំសិក្សា ២០០៩-២០១០[10] ប៉ុន្តែ វានៅតែបង្ហាញឱ្យឃើញថា បញ្ហាប្រឈមនៅតែបន្តកើតមាន។ ផលធៀបសិស្សគ្រូនៅកម្រិតបឋមសិក្សាក្នុងប្រទេសកម្ពុជាគឺ៤៨:១ ដែលផលធៀបរវាងចំនួនសិស្ស និងគ្រូបង្រៀននេះ មានកម្រិតខ្ពស់ជាងគេបំផុតលំដាប់លេខរៀង ទី១៦ ក្នុងចំណោមប្រទេសចំនួន ២០២ បើផ្អែកលើព័ត៌មានដែលអង្គការយូណេស្កូមាន។ អង្គការយូណេស្កូបានផ្តល់ដំបូន្មានថា ផលធៀបសិស្សគ្រូទាំងឡាយណាដែលលើសពី៤០:១ អាចបង្ហាញថា ហួសពីលទ្ធភាពគ្រប់គ្រងរបស់គ្រូបង្រៀន[11]។

ចំនួនគ្រូបង្រៀនបឋមសិក្សាបានធ្លាក់ចុះចំនួន៦៧១នាក់ ចាប់តាំងពីឆ្នាំសិក្សា២០០៨-២០០៩ ដោយសារតែគ្រូបង្រៀនដែលចាកចេញពីវិជ្ជាជីវៈនេះមានចំនួនច្រើនជាងគ្រូបង្រៀនដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារ[12]។ បញ្ហានេះបានបង្ខំឱ្យ ក្រសួងអប់រំ យុវជន និងកីឡា អនុវត្តវិធីសាស្ត្រគ្រូម្នាក់បង្រៀនសិស្សច្រើននាក់នៅក្នុងថ្នាក់រៀន គ្រូបង្រៀនពីរវេន គ្រូបង្រៀនច្រើនកម្រិត និងការប្រើប្រាស់គ្រូកិច្ចសន្យាដែលមិនបានទទួលការបណ្តុះបណ្តាលដើម្បីគ្រប់គ្រងលើបញ្ហាខ្វះគ្រូបង្រៀនដែលចំណុចទាំងនេះសុទ្ធសឹងតែអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើការរៀនសូត្ររបស់កុមារ។

ដើម្បីក្លាយជាគ្រូបង្រៀនបឋមសិក្សានៅពេលនេះបេក្ខជនត្រូវបញ្ចប់ថ្នាក់ទី១២។បើទោះជាដូច្នេះក្តី គ្រូបង្រៀបឋមសិក្សាបច្ចុប្បន្នចំនួន៥៤% ប៉ុណ្ណោះដែលបានបញ្ចប់ថ្នាក់ទី១២ និង ៧% បានបញ្ចប់ការអប់រំត្រឹមកម្រិតបឋមសិក្សា។ ការអប់រំមានកម្រិតទាបបែបនេះ ទំនងនឹងរាំងស្ទះចំពោះសមត្ថភាពក្នុងការអនុវត្តភារកិច្ចវិជ្ជាជីវៈរបស់ពួកគេ។

## លទ្ធផលសំខាន់ៗ និងការវិភាគ

*វត្តមាន និងលទ្ធភាពទទួលបានសេវាអប់រំ*

ក្រុមឪពុកម្តាយនៅក្នុងគ្រប់ខេត្តទាំងអស់ដែលត្រូវបានសិក្សាបានរាយការណ៍ឱ្យដឹងថាការចុះឈ្មោះចូលរៀនគឺជាដំណើរការមួយដែលមានភាពងាយស្រួល និងឥតបង់ថ្លៃព្រមទាំងមានគ្រូបង្រៀន ឬនាយកសាលាជួយបំពេញទម្រង់ដាក់ពាក្យក្នុងករណីចាំបាច់។ ក្រុមអ្នកផ្តល់ចម្លើយទាំងអស់រាប់បញ្ចូលទាំងកុមារពិការ កុមារជនជាតិដើមភាគតិច និងឪពុកម្តាយរបស់ពួកគេបាននិយាយថា ការទទួលបានការអប់រំមានភាពងាយស្រួលជាងកាលពី៥ឆ្នាំមុន ដោយសារតែបច្ចុប្បន្នមានសាលារៀន និងគ្រូបង្រៀនច្រើនជាងមុន។ បើទោះជាដូច្នេះក្តី កុមារពិការបាននិយាយថា ពួកគេបានបោះបង់ការសិក្សាដោយសារតែគ្រូបង្រៀនខ្វះការ

[10]នាយកដ្ឋានផែនការ (២០១៣) ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣។ ក្រសួងអប់រំ យុវជន និងកីឡា ៖ ភ្នំពេញ។

[11]Leng, T. & Conochie, G. (2013), *កុមារគ្រប់រូបត្រូវការគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គាន់* NEP ភ្នំពេញ។

[12]Ibid.

យល់ដឹងអំពីបញ្ហាពិការភាពរបស់ពួកគេ និងមានការរើសអើងពីមិត្តភក្តិ។ ឪពុកម្តាយ និងសិស្សបានកំណត់រកឃើញកត្តាមួយចំនួនដែលបង្កឱ្យមានផលប៉ះពាល់ទៅលើលទ្ធភាពទទួលបានការអប់រំដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម។

| ឪពុកម្តាយ | សិស្ស |
|---|---|
| សម្ភារៈរៀនសូត្រ (សៀវភៅ ប៊ិច) | សម្ភារៈរៀនសូត្រ (សៀវភៅ ប៊ិច) |
| សិស្សមានមធ្យោបាយធ្វើដំណើរ | សិស្សមានមធ្យោបាយធ្វើដំណើរ |
| សាលារៀននៅជិតផ្ទះរបស់សិស្ស | សាលារៀននៅជិតផ្ទះរបស់សិស្ស |
| ការមានគ្រូបង្រៀនគ្រប់គ្រាន់ | ឥរិយាបថ និងការលើកទឹកចិត្តរបស់ឪពុកម្តាយ |
| ទឹកស្អាត និងបង្គន់ | ឥរិយាបថគ្រូបង្រៀន ៖ វត្តមាន ការទទួលយកប្រាក់ ការប្រព្រឹត្តទៅលើសិស្ស |
| សិស្សមានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយនៅឯសាលារៀន | គុណភាពគ្រូបង្រៀន |
| សិស្សមានឯកសណ្ឋានសាលារៀន | សិស្សមានឯកសណ្ឋានសាលារៀន |

ឪពុកម្តាយ និងកុមារដែលបានបោះបង់ការសិក្សាបានប្រាប់ឱ្យដឹងថា ជាញឹកញាប់ពួកគេរមែងតែងខ្វះសម្ភារៈរៀនសូត្រដែលនេះគឺជាមូលហេតុបណ្តាលឱ្យកុមារបោះបង់ការសិក្សា។ សិស្សបានប្រាប់ឱ្យដឹងថា តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេកង្វះសម្ភារៈរៀនសូត្រធ្វើឱ្យពួកគេមានការលំបាកក្នុងការទៅរៀនឱ្យបានទៀងទាត់ ប៉ុន្តែវាមិនបានបណ្តាលឱ្យពួកគេបោះបង់ការសិក្សាឡើយ។ ការដែលគ្មានលទ្ធភាពទិញសម្ភារៈរៀនសូត្រមានទំនាក់ទំនងទៅ នឹងបញ្ហាប្រឈមមួយទៀត ដែលមនុស្សជាច្រើនបានពិភាក្សានោះ គឺកង្វះថវិកាសម្រាប់ចំណាយនៅឯសាលារៀន។

កុមារជិតពាក់កណ្តាលដែលធ្លាប់បោះបង់ការសិក្សាបានប្រាប់ឱ្យដឹងថា ការដែលពួកគេធ្លាប់បោះបង់ការសិក្សាបែបនេះ គឺបណ្តាលមកពីភាពក្រីក្រ និងការដែលឪពុកម្តាយឧស្សាហ៍ប្រាប់ឱ្យពួកគេបោះបង់ការសិក្សា(បើទោះជាដូច្នេះក្តីហេតុផលបែបនេះមិនត្រូវបានលើកឡើងច្រើនដូចបញ្ហារយៈចម្ងាយទៅសាលារៀន/កង្វះមធ្យោបាយធ្វើដំណើរទេឡើយ)។ ទំនងជាមានចំណុចពិចារណាចំនួនពីរដែលប៉ះពាល់ដល់កុមារក្រីក្រ៖

១. កុមារគ្មានលទ្ធភាពទៅសាលារៀនបានដោយសារតែកុមារត្រូវធ្វើការងារ ដើម្បីរកប្រាក់ឬជួយឪពុកម្តាយ។

២. កុមារគ្មានលទ្ធភាពទៅសាលារៀនបាន ដោយសារតែកុមារពុំមានលទ្ធភាពទិញសម្ភារៈមួយចំនួន ដូចជា កង់ ឬ សម្ភារៈរៀនសូត្រដែលចាំបាច់ដើម្បីទៅសាលារៀន។

ភាគច្រើន ចំណុចទី១ ត្រូវបានដកស្រង់ថា ជាមូលហេតុដែលធ្វើឱ្យសិស្សបោះបង់ការសិក្សា ដោយឡែកចំណុចទី២វិញ ភាគច្រើនត្រូវបានដកស្រង់ពីឪពុកម្ដាយថាជាបញ្ហា (បើទោះជាដូច្នេះក្ដី ចំណុចទី១ ក៏ត្រូវបានលើកឡើងញឹកញាប់ផងដែរ)។ ក្នុងចំណោមកុមារដែលឆាប់បោះបង់ការសិក្សា កុមារភាគច្រើនបាននិយាយថាកង្វះមធ្យោបាយធ្វើដំណើរ គឺជាមូលហេតុដែលបណ្ដាលឱ្យពួកគេបោះបង់ការសិក្សាច្រើនជាងការដែលពួកគេត្រូវធ្វើការជាមួយគ្រួសារ ឬធ្វើការងារដទៃទៀតដើម្បីទទួលបានប្រាក់កម្រៃ។ នៅពេលដែលគេបន្ថែមទៅលើយោបល់ពីកុមារទាំងនេះ អំពីការដែលពួកគេគ្មានលទ្ធភាពទិញសម្ភារៈរៀនសូត្រ គេឃើញថាពួកគេឯកភាពទៅ នឹងឪពុកម្ដាយដែលថា មូលហេតុទី២ គឺជាបញ្ហាដែលកើតឡើងញឹកញាប់ជាង។ ដូច្នេះការផ្ដល់អាហារូបករណ៍ដល់កុមារក្រីក្រអាចបង្កលក្ខណៈឱ្យពួកគេចូលរៀនបានយ៉ាងច្រើន។

សិស្សបានប្រាប់ឱ្យដឹងថាកង្វះមធ្យោបាយធ្វើដំណើរ គឺជាការលំបាកធំបំផុតដែលពួកគេជួបប្រទះក្នុងការទៅរៀនឱ្យបានទៀងទាត់ ហើយការដែលសាលារៀននៅឆ្ងាយខ្លាំងពេកក៏ត្រូវបានគូសបញ្ជាក់ញឹកញាប់ថាជាឧបសគ្គក្នុងការទៅរៀនផងដែរ។ បើទោះជាដូច្នេះក្ដី សិស្សមិនបានគិតថា ទាំងនេះជាមូលហេតុចម្បងដែលធ្វើឱ្យពួកគេឆាប់បោះបង់ការសិក្សាឡើយ។ ឪពុកម្ដាយមានការយល់ឃើញដោយឡែក និងបានកំណត់ថារយៈចម្ងាយ និងកង្វះមធ្យោបាយធ្វើដំណើរ គឺជាមូលហេតុញឹកញាប់បំផុតនៃការឆាប់បោះបង់ការសិក្សា បើធៀបទៅនឹងកត្ដាដទៃទៀត។ រយៈចម្ងាយទៅសាលារៀន និងកង្វះមធ្យោបាយធ្វើដំណើរមានភាពពាក់ព័ន្ធជាងនៅតំបន់ជនបទបើធៀបទៅនឹងតំបន់ទីក្រុង និងមានភាពពាក់ព័ន្ធជាង ចំពោះសាលាអនុវិទ្យា-ល័យបើធៀបទៅនឹងសាលាបឋមសិក្សា។

សិស្សមួយចំនួនព្រមទាំងឪពុកម្ដាយបានប្រាប់ឱ្យដឹងថា មានបញ្ហាខ្វះគ្រូបង្រៀន។ កុមារមួយចំនួនដែលទៅរៀនយឺតរមែងតែងជ្រើសរើសមិនចូលសាលា ដោយសារតែពួកគេខ្លាចទទួលទណ្ឌកម្ម។ សិស្សមួយចំនួនតូចបានរៀបរាប់ឱ្យដឹងថា គ្រូបង្រៀនអាចប្រើអំពើហិង្សា។ គួរកត់សម្គាល់ថាបច្ចុប្បន្នកំពុងមានការប្រមូលថ្លៃសិក្សា ហើយវាអាចរារាំងកុមារមិនឱ្យវិលត្រឡប់មកសាលារៀនវិញនៅក្នុងឆ្នាំសិក្សាដដែលនោះប្រសិនបើពួកគេអវត្តមាន(ឧ.នៅពេលប្រមូលផល)។ បើទោះជាដូច្នេះក្ដី ឪពុកម្ដាយ សិស្ស ឬកុមារនៅក្រៅសាលារៀនមិនគិតថាបញ្ហាកង្វះគ្រូបង្រៀនគុណភាពឬការប្រព្រឹត្តរបស់គ្រូបង្រៀនគឺជាមូលហេតុចម្បងដែលធ្វើឱ្យកុមារមិនចូលរៀនឡើយ។

សម្រាប់សិស្សវិញអ្វីដែលសំខាន់ជាងឥរិយាបថរបស់គ្រូបង្រៀន គឺជាឥរិយាបថរបស់សិស្សខ្លួនឯងផ្ទាល់។ ក្រុមសិស្សបានរៀបរាប់ឱ្យដឹងថាការដែលកុមារខ្ជិលច្រអូសឬរៀនមិនចេះ គឺជាមូលហេតុធំបំផុតទី២ដែលធ្វើឱ្យកុមារស្ថិតនៅក្រៅសាលារៀនដែលមូលហេតុនេះសំខាន់ជាងការដែលកុមាររស់នៅឆ្ងាយពីសាលារៀន ឬខ្វះមធ្យោបាយធ្វើដំណើរទៀតផង។ មានការបញ្ជាក់អំពីតួនាទីសំខាន់របស់កុមារខ្លួនឯងផ្ទាល់នៅពេលដែលកុមារភាគច្រើនដែលបានឈប់រៀនមុនថ្នាក់ទី៩បានប្រាប់ឱ្យដឹងថា វាគឺជាការសម្រេចចិត្តរបស់ពួកគេក្នុងការបោះបង់ការសិក្សា។ កុមារទាំងនេះបាននិយាយថាពួកគេផ្ដល់តម្លៃចំពោះការអប់រំ ប៉ុន្តែកត្តាដទៃទៀត ដូចជាកង្វះមធ្យោបាយធ្វើដំណើរ និងសម្ភារៈរៀនសូត្រ ការដែលត្រូវធ្វើការងារ ឬថែទាំបងប្អូន/ឪពុកម្ដាយមានជម្ងឺបណ្ដាលឱ្យពួកគេគិតថាត្រូវឈប់រៀន។ ឥរិយាបថរបស់ឪពុកម្ដាយត្រូវបានគេមើលឃើញថាមិនសូវមានសារៈសំខាន់ ប៉ុន្តែក៏មានក្រុមសិស្សមួយចំនួនដែលបានរៀបរាប់អំពីសេចក្ដីត្រូវការឱ្យ

មានការលើកទឹកចិត្តពីឪពុកម្តាយផងដែរ។ ក្រុមសិស្សនិងឪពុកម្តាយមួយចំនួនតូចបានប្រាប់ឱ្យដឹងថា អំពើហិង្សារបស់ឪពុកម្តាយចំពោះកូនបានរារាំងកុមារមិនឱ្យទៅរៀនបានទៀងទាត់។

ការចាប់ផ្តើមចូលរៀនថ្នាក់ទី១នៅអាយុ៦ឆ្នាំ បង្កើនឱកាសក្នុងការរៀនចប់ថ្នាក់កាន់តែច្រើន។ មានតែកុមារម្នាក់ប៉ុណ្ណោះ ក្នុងចំណោមកុមារ២២នាក់ ត្រូវបានសម្ភាសន៍ដែលបានបោះបង់ការសិក្សាក្នុងកម្រិតបឋមសិក្សាចូលរៀននៅអាយុ៦ឆ្នាំ ដោយឡែកកុមារចំនួនពាក់កណ្តាលដែលបានបោះបង់កាសិក្សានៅកម្រិតអនុវិទ្យាល័យចាប់ផ្តើមចូលរៀននៅអាយុ៦ឆ្នាំ។ ប្រសិនបើកុមារចូលរៀនអាយុលើស៦ឆ្នាំពួកគេឈានដល់អាយុមួយដែលពួកគេមានលទ្ធភាពកាន់តែច្រើនក្នុងការរួមចំណែកធ្វើការងារនៅឯផ្ទះ ឬធ្វើការងារដទៃទៀតមុនពេលដែលពួកគេរៀនដល់ថ្នាក់ទី៩ ចំណុចនេះធ្វើឱ្យតម្លៃកាលានុវត្តភាពនៃការបន្តសិក្សានៅឯសាលារៀនមានតម្លៃកាន់តែខ្ពស់។ កុមារចំនួនពាក់កណ្តាលដែលបានបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាមានអាយុ ១៤-១៦ឆ្នាំ រួចទៅហើយ។

*ភាពអាចទទួលយកបាននូវសេវាអប់រំ*

ក្រុមសិស្ស និងឪពុកម្តាយជាច្រើនលើសលប់មានការពេញចិត្តទៅនឹងគុណភាពអប់រំ។ បើទោះជាដូច្នេះក្តី គេត្រូវពិចារណាទៅលើការពេញចិត្តធៀបទៅនឹងការរំពឹងទុក។ ប្រសិនបើការរំពឹងទុកចំពោះគុណភាពអប់រំមានកម្រិតទាបខ្លាំងនៅពេលនោះគេមិនចាំបាច់តម្រូវឱ្យប្រជាពលរដ្ឋមានការពេញចិត្តចំពោះគុណភាពអប់រំល្អឡើយ។ សិស្សចំនួនពីរក្រុមបាននិយាយថា ពួកគេមានអារម្មណ៍ថាពួកគេទទួលបានការអប់រំប្រកបដោយគុណភាពល្អ ដោយសារតែពួកគេអាចអាន និងសរសេរបាន។ កុមារស្ទើរគ្រប់រូបត្រូវបានសម្ភាសន៍ដែលបោះបង់ការសិក្សាមុនថ្នាក់ទី៩ បានប្រាប់ឱ្យដឹងថា ការអប់រំដែលពួកគេទទួលបានមានគុណភាពល្អ ប៉ុន្តែមានតែពាក់កណ្តាលប៉ុណ្ណោះក្នុងចំណោមកុមារទាំងនេះដែលនិយាយថាពួកគេចេះគិតលេខ។ គេអាចមើលឃើញថាការរំពឹងទុក គឺត្រឹមតែចេះអាននិងសរសេរប៉ុណ្ណោះ។ បន្ថែមពីនេះទៀតឪពុកម្តាយរបស់កុមារពិការនិងកុមារជនជាតិដើមភាគតិចដែលបានចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់បានប្រាប់ឱ្យដឹងថា គុណភាពអប់រំមិនល្អឡើយ។

ឪពុកម្តាយ និងសិស្សភាគច្រើន លើកលែងតែកុមារពិការមានការពេញចិត្តទៅនឹងគុណភាពគ្រូបង្រៀននៅក្នុងសាលារៀនរបស់ពួកគេ។ នៅពេលដែលសិស្សដែលជឿថា ពួកគេកំពុងទទួលបានការអប់រំមួយដ៏ល្អត្រូវបានសួរថាហេតុអ្វីបានជាពួកគេយល់ឃើញបែបនេះចម្លើយទូទៅបំផុតដែលទទួលបានកន្លងមកគឺពួកគេមានគ្រូបង្រៀនម្នាក់ដ៏ល្អ។ បើទោះជាដូច្នេះក្តីក្រុមសិស្សមួយក្រុមបានបន្ទោសអំពីគុណភាពអប់រំមិនល្អទៅលើគ្រូបង្រៀនដែលមិនល្អដោយនិយាយថា គ្រូបង្រៀនកម្រពន្យល់មេរៀនសរសេរច្រើនពេកនៅលើក្តារខៀន និងមិនប្រើលំហាត់ជាឧទាហរណ៍។ ឪពុកម្តាយ និងសិស្សនៅខេត្តសៀមរាប និងខេត្តរតនគិរី បានលើកឡើងនូវការព្រួយបារម្ភអំពីការប្រើប្រាស់គ្រូកិច្ចសន្យា គ្រូបង្រៀនពីរវេន និងគ្រូបង្រៀនច្រើនកម្រិតនៅក្នុងសហគមន៍របស់ពួកគេ។ ឪពុកម្តាយ និងសិស្សមួយចំនួននៅខេត្តសៀមរាបបាននិយាយឱ្យដឹងថា គ្រូត្រូវបង្រៀនពីរថ្នាក់ស្របពេលជាមួយគ្នានៅបន្ទប់ផ្សេងគ្នាទៀតផង។ ការអនុវត្តទាំងនេះអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើគុណភាពអប់រំ។

ប្រសិនបើសិស្ស ឬឪពុកម្ដាយមិនពេញចិត្តទៅនឹងគ្រូបង្រៀនភាគច្រើន វាទាក់ទងទៅនឹងឥរិយាបថរបស់គ្រូ ចំពោះអវត្តមានឬការប្រមូលប្រាក់។ បើទោះបីជាឪពុកម្ដាយនិងសិស្សភាគច្រើនមានអារម្មណ៍ថាសិស្សគ្រប់រូបទទួលបានការប្រព្រឹត្តស្មើភាពគ្នាក៏ដោយ ប៉ុន្តែមានក្រុមឪពុកម្ដាយចំនួន៦ក្រុមនិយាយថា គ្រូបង្រៀនមួយចំនួនមានភាពលម្អៀងចំពោះកុមារដែលបង់ថ្លៃរៀនគួ ឬកុមារដែលឪពុកម្ដាយរបស់ពួកគេឱ្យប្រាក់ទៅគ្រូបង្រៀនដើម្បីឱ្យកូនរបស់ពួកគេប្រឡងជាប់។

បើយោងតាមសិស្សបានឱ្យដឹងថា កត្តាដែលមានឥទ្ធិពលខ្លាំងបំផុតលំដាប់លេខរៀងទី២ ដែលនាំឱ្យប៉ះពាល់ដល់គុណភាពអប់រំ គឺជាឥរិយាបថរបស់សិស្ស ឆន្ទៈរបស់សិស្ស និងសមត្ថភាពរៀនសូត្រព្រមទាំងការដែលសិស្សជួយគាំទ្រគ្នាទៅវិញទៅមក។ អ្វីដែលគាំទ្រដល់ចំណុចនេះផងដែរនោះគឺមូលហេតុទូទៅបំផុត (ដែលផ្ដល់ដោយសិស្សចំនួន៦ក្រុម) ចំពោះការដែលរៀនមិនទាន់មេរៀនគឺដោយសារតែការដែលសិស្សគ្មានវិន័យនៅក្នុងថ្នាក់ ប៉ុន្តែក្រុមទាំងនេះក៏បានប្រាប់ឱ្យដឹងផងដែរថាសិស្សភាគច្រើនមានការប្ដេជ្ញាចិត្តចំពោះការរៀនសូត្រ។ មានតែសិស្ស៤ក្រុមប៉ុណ្ណោះ ដែលបានបន្ទោសទៅលើការដែលសិស្សរៀនមិនទាន់ដោយសារតែគ្រូពន្យល់មិនបានល្អ ឬ ពិចារណាទៅលើសិស្សដែលរៀនយឺត។

ក្រុមសិស្សជាងពាក់កណ្ដាលបានប្រាប់ឱ្យដឹងថា ពួកគេអាចរៀនទាន់មេរៀនដែលគ្រូបង្រៀន ហើយកត្តាមួយដ៏សំខាន់ គឺថាតើសិស្សមានអារម្មណ៍ថាពួកគេអាចសូមឱ្យគ្រូពន្យល់ម្ដងទៀតឬពន្យល់ក្នុងលក្ខណៈមួយដែលខុសពីមុនបានដែរឬទេ។

ក្រុមសិស្សចំនួនពាក់កណ្ដាលដែលកំណត់ថា សៀវភៅមេរៀន និងសម្ភារៈបង្រៀនមានសារៈសំខាន់សម្រាប់ការអប់រំប្រកបដោយគុណភាពបានប្រាប់ឱ្យដឹងថាពួកគេខ្វះសម្ភារៈទាំងនេះ។ យ៉ាងណាមិញពុំមានក្រុមសិស្សណាមួយរៀបរាប់ថាសៀវភៅមេរៀន/សម្ភារៈបង្រៀន គឺជាមូលហេតុដែលធ្វើឱ្យពួកគេទទួលបានការអប់រំប្រកបដោយគុណភាពល្អ មធ្យម ឬខ្សោយនោះទេ។ បន្ថែមពីនេះទៀតពុំមានក្រុមសិស្សណាមួយនិយាយថាសិស្សរៀនមិនទាន់ដោយសារតែខ្វះមេរៀន ឬសម្ភារៈបង្រៀនឡើយ។

*ភាពបត់បែនបាននៃសេវាអប់រំ*

ឪពុកម្ដាយ និងសិស្សបានរាយការណ៍ឱ្យដឹងថា កុមារពិការភ្នែក គ ឬថ្លង់មានសញ្ញាប្រកាច់ ឬពិការសតិបញ្ញាភាគច្រើនមិនចូលរៀន ហើយសាលារៀនមិនបានផ្ដល់ការគាំទ្រណាមួយដើម្បីឱ្យពួកគេទៅសាលារៀនឬជួយឪពុកម្ដាយដើម្បីផ្ដល់ការអប់រំនៅឯផ្ទះឡើយ។ ហេតុផលចម្បងៗចំនួនពីរដែលកុមារប្រភេទនេះមិនទៅសាលារៀនគឺដោយសារតែសាលារៀនពុំមានសម្ភារៈបរិក្ខារសម្រាប់កុមារប្រភេទនេះហើយគ្រូបង្រៀនមិនអាចសម្របវិធីសាស្ត្របង្រៀនរបស់ខ្លួនឱ្យស្របទៅតាមសេចក្ដីត្រូវការរបស់កុមារទាំងនេះឡើយ។ កុមារពិការសតិបញ្ញាដែលបានចូលរួមសិក្ខាសាលារបស់យើងក៏បានប្រាប់ឱ្យដឹងផងដែរថា គ្រូបង្រៀនមិនយល់អំពីសេចក្ដីត្រូវការរបស់ពួកគេ និងមិនអាចសម្របវិធីសាស្ត្របង្រៀនរបស់ពួកគេដើម្បីជួយដល់កុមារទាំងនេះ។

ឪពុកម្ដាយនិងសិស្សបាននិយាយថា ភាគច្រើនកុមារពិការរាងកាយឬខ្សោយសោតវិញ្ញាណបានចូលរៀននិងទទួលបានកិច្ចគាំទ្រអាហារូបករណ៍ដូចជាកង់ឬសម្ភារៈរៀនសូត្រ។ នៅក្នុងសាលារៀនមួយនៅខេត្ត

កំពតកុមារដែលខ្សោយចក្ខុវិញ្ញាណបានក្លាយជាសិស្សពូកែ ដោយសារតែសាលារៀនធ្វើការកែសម្រួលបន្តិចបន្តួចដូចជាការបង្កលក្ខណៈឱ្យពួកគេអង្គុយនៅតុខាងមុខ ការផ្តល់សៀវភៅមេរៀនដែលមានអក្សរធំៗ និងវ៉ែនតាសមស្រប។ សាលារៀននេះបានទទួលជំនួយពីអង្គការគ្រួសារថ្មី (អង្គការមិនមែនរដ្ឋាភិបាលមួយ) ប៉ុន្តែសាលារៀនដទៃទៀតមិនបានទទួលការគាំទ្របែបនេះឡើយ ហើយមានតែគ្រូបង្រៀនដែលត្រូវបានសម្ភាសន៍១១នាក់ ប៉ុណ្ណោះក្នុងចំណោម៨៤នាក់បានប្រាប់ឱ្យដឹងថា ពួកគេធ្លាប់បានទទួលការបណ្តុះបណ្តាលស្តីពីការអប់រំបញ្ចូលគ្នាសម្រាប់កុមារគ្រប់ប្រភេទ។ កត្តារួមចំណែកចំពោះកង្វះការបណ្តុះបណ្តាលខណៈពេលដែលកំពុងបម្រើការងារគឺបណ្តាលមកពីការប្រើប្រាស់គ្រូកិច្ចសន្យាដែលមិនបានទទួលការបណ្តុះបណ្តាលមុនពេលចូលបម្រើការងារដែលអាចជួយដល់ពួកគេក្នុងការសម្របការបង្រៀនរបស់ពួកគេសម្រាប់ប្រភេទសិស្សផ្សេងៗគ្នារាប់បញ្ចូលទាំងសិស្សជាជនជាតិដើមភាគតិចដែលភាសាទី១របស់ពួកគេមិនមែនជាភាសាខ្មែរផងដែរ។

ឪពុកម្តាយក្នុងខេត្តរតនគិរីបានប្រាប់ឱ្យដឹងថា ជារឿយៗគ្រូភាសាខ្មែរមិនអាចនិយាយភាសាជនជាតិក្នុងមូលដ្ឋានបានល្អគ្រប់គ្រាន់ក្នុងការបង្រៀនកុមារជាភាសាជនជាតិនោះឡើយ។ ម៉្យាងវិញទៀត ប្រសិនបើគ្រូបង្រៀនជាភាសាខ្មែរ សិស្សក្រុមជនជាតិដើមភាគតិចមិនយល់ពាក្យដែលគ្រូប្រើប្រាស់នៅពេលពន្យល់ឡើយ។ សិស្សបាននិយាយថាកង្វះការយល់ដឹងអត្ថន័យស៊ីជម្រៅរបស់ភាសាខ្មែរធ្វើឱ្យលទ្ធភាពរបស់ពួកគេមានកម្រិតក្នុងការអាន និងធ្វើកិច្ចការដែលគ្រូដាក់ឱ្យធ្វើនៅឯផ្ទះ។ ទាក់ទងទៅនឹងបញ្ហាវប្បធម៌ ឪពុកម្តាយជឿថាគ្រូបង្រៀនជនជាតិខ្មែរមួយចំនួនមិនបានគោរពវប្បធម៌របស់ជនជាតិដើមភាគតិចឱ្យបានសមស្រប ឬព្យាយាមសម្របការបង្រៀនរបស់ពួកគេដើម្បីជួយឱ្យសិស្សយល់ឡើយ។

ក្រសួងអប់រំ យុវជន និងកីឡា មានការគាំទ្រពីអង្គការយូនីសេហ្វ និងអង្គការសហប្រតិបត្តិការអន្តរជាតិកម្ពុជាកំពុងផ្តល់ការអប់រំពីរភាសានៅក្នុងសាលាបឋមសិក្សា។ ឪពុកម្តាយចំនួនពីរក្រុមក្នុងខេត្តរតនគិរីមានភាពសប្បាយរីករាយដែលកូនរបស់ពួកគេរៀនចេះអាន និងសរសេរភាសាខ្មែរដោយសារតែពួកគេទទួលបានការអប់រំពីរភាសា។

ក្រុមឪពុកម្តាយ និងសិស្សជាច្រើនក្រុមព្រមទាំងគ្រូបង្រៀនបាននិយាយថា ប្រធានបទនៅក្នុងកម្មវិធីសិក្សាបច្ចុប្បន្នមានភាពពាក់ព័ន្ធទៅនឹងសេចក្តីត្រូវការរបស់កុមារ ដោយបានដកស្រង់អំពីសមត្ថភាពរបស់ពួកគេ ក្នុងការអាន សរសេរ និងរាប់លេខ។ សិស្សបាននិយាយឱ្យដឹងថា មេរៀនជំនាញបំណិនជីវិតមានសារៈប្រយោជន៍ចំពោះជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ ហើយសួនបន្លែអាចជួយពួកគេក្នុងការសន្សំប្រាក់តាមរយៈការកាត់បន្ថយការទិញបន្លែទទួលទានពីផ្សារ។បើទោះជាដូច្នេះក្តីសិស្សចំនួន១០ក្រុមបានរាយការណ៍ថា ពួកគេមិនបានរៀនជំនាញណាមួយដែលអាចមានសារៈប្រយោជន៍សម្រាប់ពួកគេឬគ្រួសាររបស់ពួកគេនៅឡើយទេដែលនេះគឺជាការព្រួយបារម្ភជាក់លាក់មួយរបស់កុមារនៅអនុវិទ្យាល័យ។សិស្សនិងគ្រូបង្រៀនបានកំណត់រកឃើញប្រធានបទបន្ថែមទៀតដែលអាចមានសារៈសំខាន់ចំពោះពួកគេដូចជាការរៀនប្រើប្រាស់កុំព្យូទ័រ និងភាសាបរទេស។ គួរកត់សម្គាល់ថាពុំមានក្រុមសិស្សណាមួយមានអារម្មណ៍ថា ពួកគេអាចស្នើប្រធានបទដែលពួកគេចង់រៀនសូត្រក្នុងអំឡុងវគ្គជំនាញបំណិនជីវិតបានឡើយដោយសារតែពួកគេមានអារម្មណ៍ថា ពួកគេពុំមានសិទ្ធិធ្វើបែបនេះ។

## សេចក្តីសន្និដ្ឋាន

បុគ្គលស្ទើរតែគ្រប់រូបដែលយើងបានជួបនិយាយជាមួយមានអារម្មណ៍ថា ការចូលរៀននៅពេលនេះមានភាពងាយស្រួលជាងកាលពី៥ឆ្នាំមុន ហើយបុគ្គលទាំងនោះរួមមានកុមារពិការនិងឪពុកម្តាយរបស់ពួកគេ និងក្រុមជនជាតិដើមភាគតិច។ ចំណុចនេះឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពជាក់ស្តែងដែលសម្រេចបានក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងការអប់រំកម្រិតបឋមសិក្សា និងមិនគួរត្រូវបានបំភ្លេចនៅក្នុងការពិភាក្សាអំពីបញ្ហាប្រឈមដែលនៅសេសសល់ឡើយ។

មូលហេតុទូទៅបំផុតដែលកុមារបានផ្តល់ជូនអំពីការបោះបង់ការសិក្សា គឺបណ្តាលមកពីភាពក្រីក្រ ដែលធ្វើឱ្យពួកគេគ្មានលទ្ធភាពក្នុងការទិញកង់ និងសម្ភារៈរៀនសូត្រសម្រាប់បង្កលក្ខណៈឱ្យពួកគេអាចទៅរៀនបាន។ ពួកគេក៏ទំនងនឹងជ្រើសរើសឈប់រៀនដើម្បីថែទាំបងប្អូន ធ្វើការងារជាមួយឪពុកម្តាយរបស់ពួកគេ ឬស្វែងរកការងារធ្វើ។ សិស្សក៏បានយល់ឃើញផងដែរថាភាពក្រីក្រ គឺជាមូលហេតុចម្បងមួយនៃការបោះបង់ការសិក្សា ប៉ុន្តែឪពុកម្តាយមិនសូវផ្តោតទៅលើចំណុចនេះខ្លាំងប៉ុន្មានទេ។ គួរកត់សម្គាល់ថាកុមារភាគច្រើនដែលបោះបង់ការសិក្សាបានចាប់ផ្តើមចូលរៀនថ្នាក់ទី១ នៅពេលដែលពួកគេមានអាយុលើស ៦ឆ្នាំ។ កុមារចំនួនពាក់កណ្តាលដែលបោះបង់ការសិក្សាក្នុងកម្រិតបឋមសិក្សាមានអាយុ១៤-១៦ឆ្នាំ នៅពេលដែលពួកគេធ្វើយ៉ាងដូច្នេះស្ថិតក្នុងអាយុនេះ ពួកគេមានលទ្ធភាពកាន់តែច្រើនក្នុងការធ្វើការងារនៅឯផ្ទះ ឬធ្វើការងារដើម្បីរកប្រាក់ដែលជាហេតុនាំឱ្យមានការកើនឡើងនូវតម្លៃកាលានុវត្តភាពនៃការចូលរៀន។

ថ្លៃចំណាយដែលជាកត្តាបង្កការលំបាកបំផុតចំពោះការទៅរៀននៅឯសាលា គឺជាការទិញសម្ភារៈរៀនសូត្រ និងមធ្យោបាយធ្វើដំណើរ ដូចជាកង់ជាដើម ចំណុចទាំងនេះត្រូវបានគ្រប់ក្រុមទាំងអស់លើកឡើងម្តងហើយម្តងទៀតថាជាមូលហេតុដែលបណ្តាលឱ្យកុមារបោះបង់ ឬទៅរៀនមិនបានទៀងទាត់។ ក្រសួងអប់រំ យុវជន និងកីឡា គួរបន្តគោលនយោបាយពង្រីកអាហារូបករណ៍របស់ខ្លួនអាស្រ័យដោយវាមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើអត្រាបោះបង់ការសិក្សានៅកម្រិតបឋម និងមធ្យមសិក្សា ហើយថ្លៃចំណាយមានកម្រិតទាបបង្គួរ (៥០-៦០ ដុល្លាក្នុងមួយឆ្នាំ)។

ឪពុកម្តាយនិងសិស្សភាគច្រើនមានការពេញចិត្តទៅនឹងគុណភាពអប់រំលើកលែងតែកុមារពិការ។ បើទោះជាដូច្នេះក្តីកម្រិតនៃការរំពឹងទុកគឺត្រឹមតែចេះអាននិងសរសេរប៉ុណ្ណោះ។ គុណភាពអប់រំកំពុងរងផលប៉ះពាល់ពីបញ្ហាកង្វះគ្រូបង្រៀនដែលបណ្តាលឱ្យគ្រូបង្រៀនមួយចំនួនត្រូវបង្រៀនពីរថ្នាក់ក្នុងបន្ទប់ពីរដោយឡែកពីគ្នានៅពេលតែមួយ។ សិស្សមានការព្រួយបារម្ភផងដែរថា ពួកគេមិនបានរៀនសូត្រជំនាញដែល នឹងជួយឱ្យពួកគេអាចស្វែងរកការងារ ឬ រកប្រាក់ចំណូលបានឡើយ។

ជាញឹកញាប់កុមារពិការ និងឪពុកម្តាយរបស់ពួកគេរមែងតែងនិយាយថា គ្រូបង្រៀនមិនអាចសម្របការបង្រៀនរបស់ពួកគេដើម្បីជួយដល់កុមារពិការបានឡើយ។ ជម្រើសមួយ គឺត្រូវមានមជ្ឈមណ្ឌលធនធានមួយនៅក្នុងគ្រប់ខេត្តទាំងអស់ដែលអាចផ្តល់ការបណ្តុះបណ្តាលជូនដល់គ្រូបង្រៀនដែលមានសិស្សជាកុមារពិការឬអាចផ្តល់ព័ត៌មាន/ដំបូន្មានបាន។ មជ្ឈមណ្ឌលធនធានអាចមានបុគ្គលិកដែលចុះទស្សនកិច្ចតាម

សាលារៀនដើម្បីជួយដល់គ្រូបង្រៀន និងផ្តល់ការបណ្តុះបណ្តាលក្នុងអំឡុងពេលកិច្ចប្រជុំបច្ចេកទេសរៀងរាល់ថ្ងៃព្រហស្បតិ៍។

សិស្សក្រុមជនជាតិដើមភាគតិចក៏បានប្រាប់ឱ្យដឹងផងដែរថា គ្រូបង្រៀនមិនអាចសម្របការបង្រៀនរបស់ខ្លួនដើម្បីជួយដល់ពួកគេបានឡើយ ឧទាហរណ៍ដូចជា ការប្រើប្រាស់ពាក្យពេចន៍ជាភាសាខ្មែរដែលពួកគេមិនយល់។ គេអាចជ្រើសរើសគ្រូបង្រៀនពីរភាសាបន្ថែមទៀត ហើយនៅពេលដែលកំពុងមានការបែងចែកគរុសិស្សគេអាចធ្វើការបម្រុងទុកកូតាមួយសម្រាប់គ្រូបង្រៀនពីរភាសា។ គ្រូបង្រៀនទាំងនេះអាចចូលរួមការបណ្តុះបណ្តាលប្រក្រតីរយៈពេល២ឆ្នាំមុនពេលចូលបម្រើការងារនិងការបណ្តុះបណ្តាលរយៈពេល២ខែបន្ថែមទៀតនៅចុងវគ្គដើម្បីផ្តោតលើការបង្រៀនភាសាជនជាតិដើមភាគតិច។

***អនុសាសន៍***

១) ក្រសួងអប់រំ យុវជន និងកីឡា គួរផ្តល់មធ្យោបាយធ្វើដំណើរ និងអន្តេវាសិកដ្ឋាន ជូនដល់សិស្សអនុវិទ្យាល័យដែលមកពីគ្រួសារក្រីក្ររស់នៅឆ្ងាយពីសាលារៀន។

២) ក្រសួងអប់រំ យុវជន និងកីឡា គួរបន្តគោលនយោបាយពង្រីកអាហារូបករណ៍របស់ខ្លួនដើម្បីជួយដល់សិស្សក្នុងការទិញសម្ភារៈរៀនសូត្រ ឯកសណ្ឋានសាលារៀន ឬកង់។

៣) ក្រសួងអប់រំ យុវជន និងកីឡា គួរជ្រើសរើសគ្រូបង្រៀនបន្ថែមទៀត ជាពិសេសនៅតំបន់ជនបទ និងពង្រីកការបណ្តុះបណ្តាលខណៈពេលបម្រើការងារឱ្យបានច្រើនដើម្បីកសាងសមត្ថភាពគ្រូបង្រៀនរាប់បញ្ចូលទាំងគ្រូកិច្ចសន្យាផងដែរ។

៤) ក្រសួងអប់រំ យុវជន និងកីឡា គួរបង្កើនថ្នាក់រៀនពិសេសសម្រាប់កុមារពិការនៅក្នុងសាលារដ្ឋនៅគ្រប់ស្រុកទាំងអស់។

៥) ក្រសួងអប់រំ យុវជន និងកីឡា គួរបែងចែកកូតាសម្រាប់គ្រូបង្រៀនពីរភាសានៅពេលជ្រើសរើសគ្រូបង្រៀនហើយគ្រូបង្រៀនដែលមានស្រាប់នៅតាមសាលារៀនពីរភាសាគួរក្លាយជាមន្ត្រីរាជការស៊ីវិលពេញសិទ្ធិ ជាជាងគ្រូកិច្ចសន្យា។

៦) ក្រសួងអប់រំ យុវជន និងកីឡា គួរទទួលយកការទទួលខុសត្រូវក្នុងការបោះពុម្ពសៀវភៅមេរៀនសម្រាប់ការអប់រំពីរភាសា និងសៀវភៅមេរៀនសម្រាប់កុមារពិការ។

# ១. សេចក្តីផ្តើម

ការសិក្សាអំពីសិទ្ធិទទួលបានការអប់រំ(RTE) នៅក្នុងប្រទេសកម្ពុជាជាផ្នែកមួយនៃគម្រោងសាកល របស់អង្គការយូណេស្កូ ដើម្បីពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិទាក់ទងនឹងសិទ្ធិក្នុងការអប់រំ។ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក គម្រោងនេះត្រូវបានសម្របសម្រួលដោយ អង្គការយូណេស្កូ នៅទីក្រុងបាងកកជាមួយ នឹងការសិក្សាបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃក្នុងឆ្នាំ២០១៣ ។

នៅក្នុងប្រទេសកម្ពុជា អង្គការ VSO កំពុងចាប់ដៃគូជាមួយ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ដើម្បីបញ្ចប់ការស្រាវជ្រាវកម្រិតសហគមន៍នេះ។ តំណាងមួយរូបនៃការិយាល័យអង្គការយូណេស្កូ ប្រចាំរាជធានីភ្នំពេញ គឺជាសមាជិកក្រុមប្រឹក្សាយោបល់សម្រាប់ការស្រាវជ្រាវដែលបង្កើតឡើងដោយអង្គការ VSO និង NEP ដើម្បីត្រួតពិនិត្យមើលទៅលើការស្រាវជ្រាវនេះ។ NEP យូណេស្កូ និង VSO បានឯកភាពទៅលើវិសាលភាពនៃការស្រាវជ្រាវ ដូចតទៅ ៖

- ការស្រាវជ្រាវនឹងផ្តោតយកចិត្តទុកដាក់ទៅលើការអប់រំមូលដ្ឋាន (ថ្នាក់ទី១-៩)។
- ការស្រាវជ្រាវនឹងកំណត់ទៅលើភាពជោគជ័យ និងបញ្ហាប្រឈមក្នុងការអនុវត្តន៍គោលនយោបាយដែលទាក់ទងទៅនឹងសិទ្ធិទទួលបានការអប់រំ។
- ការស្រាវជ្រាវនឹងរៀបចំឱ្យមាននូវអនុសាសន៍ សម្រាប់រាជរដ្ឋាភិបាលបង្កើតនិយាមបទដ្ឋាន និងគោលនយោបាយនានា ដែលស្របតាមបទដ្ឋានអន្តរជាតិទាក់ទងនឹងសិទ្ធិទទួលបានការអប់រំ។

ការសិក្សាស្រាវជ្រាវនេះ នឹងផ្តោតយកចិត្តទុកដាក់ទៅលើសិទ្ធិទទួលបានការអប់រំនៅក្នុងវិស័យអប់រំមូលដ្ឋាន ហើយការវិភាគនឹងត្រូវបានរៀបចំរចនាសម្ព័ន្ធដោយប្រើប្រាស់ក្របខ័ណ្ឌ A4 ដែលបង្កើតឡើងដោយសាស្ត្រាចារ្យ Prof. Katarina Tomaševski[13] ៖

**លទ្ធភាពទទួលបានសេវាអប់រំ ៖** ស្ថាប័នអប់រំត្រូវមានចំនួនឱ្យបានគ្រប់គ្រាន់រាប់បញ្ចូលទាំងសម្ភារៈអនាម័យសម្រាប់សិស្សទាំងពីរភេទទឹកទទួលទានមានសុវត្ថិភាព គ្រូបង្រៀនមានការបណ្តុះបណ្តាល និងទទួលបានបៀវត្សរ៍សមរម្យ បែបប្រកួតប្រជែងក្នុងស្រុក ព្រមទាំងការផ្តល់សម្ភារៈបង្រៀន។

**ភាពអាចទទួលយកបានសេវាអប់រំ ៖** ទម្រង់ និងសមាសធាតុនៃការអប់រំត្រូវតែមានលក្ខណៈអាចទទួលយកបានចំពោះសិស្សនិងឪពុកម្តាយ។ វាគួរមានភាពពាក់ព័ន្ធ មានភាពសមស្របទៅតាមវប្បធម៌ និងមានគុណភាពល្អ។

**វត្តមាន ៖** ស្ថាប័នអប់រំត្រូវបង្កលក្ខណៈឱ្យជនគ្រប់រូបអាចទៅរៀនសូត្របានដោយគ្មានការរើសអើងទាំងនៅក្នុងច្បាប់ និងក្នុងការអនុវត្តន៍ជាក់ស្តែង។

[13] Prof. Katarina Tomasevski គឺជាអតីតនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានការអប់រំ។

**ភាពបត់បែន៖** ការអប់រំត្រូវមានភាពបត់បែនទន់ភ្លន់ដោយសម្របទៅតាមសេចក្តីត្រូវការរបស់សង្គមដែលកំពុងមានការផ្លាស់ប្តូរ និងសិស្សដោយយោងទៅតាមបរិបទសង្គម និងវប្បធម៌ផ្សេងៗគ្នារបស់ពួកគេ។

# ២. វិធីសាស្ត្រ

*២.១. ទីតាំងសំណាក*

ការស្រាវជ្រាវត្រូវបានធ្វើឡើងនៅក្នុងខេត្តចំនួន៣ដែលរួមមានជាអាទិ៍៖ ខេត្តរតនគិរី ខេត្តសៀមរាប និងខេត្តកំពត។ ខេត្តទាំងបីនេះ ឆ្លុះបញ្ចាំងនូវទិដ្ឋភាពផ្នែកសេដ្ឋកិច្ចសង្គម និងវប្បធម៌ ក្នុងប្រទេសកម្ពុជា និងអាចបង្កលក្ខណៈឱ្យការស្រាវជ្រាវធ្វើការឆ្លុះបញ្ចាំងអំពីបញ្ហាសំខាន់ៗដែលកើតមានឡើងបណ្តាលមកពីកត្តាភូមិសាស្ត្រដែលមានលក្ខណៈពិសេសផ្សេងៗគ្នា។ នៅក្នុងខេត្តនីមួយៗយើងបានចុះធ្វើទស្សនកិច្ចឃុំចំនួន៤ដែលឃុំទាំងនោះស្ថិតនៅក្នុងតំបន់ខុសៗគ្នា ដូចជាតំបន់ដាច់ស្រយាល តំបន់ជនបទ និងតំបន់ជាយក្រុងដែលឆ្លុះបញ្ចាំងអំពីទិដ្ឋភាពជារួមនៃប្រទេសកម្ពុជា។ ដោយសារពុំមានពេលនិងធនធានយើងមិនអាចធ្វើការសិក្សាស្រាវជ្រាវនៅរាជធានីភ្នំពេញដែលជាតំបន់មួយមានលក្ខណៈខុសប្លែកយ៉ាងខ្លាំងពីតំបន់ដទៃទៀតក្នុងប្រទេសកម្ពុជា និងអាចមានបញ្ហាប្រឈមខុសគ្នាផងដែរ។

រតនគិរី គឺជាខេត្តដាច់ស្រយាលមួយជាប់ព្រំដែនប្រទេសវៀតណាម នៅភាគឥសានប្រទេស ដែលនៅទីនោះប្រជាជនភាគច្រើនពឹងផ្អែកទៅលើធនធានធម្មជាតិ ដូចជាការធ្វើកសិកម្មយថាផល អនុផលព្រៃឈើ (ឧ.ផ្លែឈើផ្សិត) នេសាទ និងកសិឧស្សាហកម្ម ដូចជាស្វាយចន្ទី។ ថ្មីៗនេះមានកំណើនឧស្សាហកម្មដែលទាញផលពីធនធានធម្មជាតិ ដូចជាព្រៃឈើដែលធ្វើឱ្យមានការប្រែប្រួលទៅលើស្ថានភាពសង្គម សេដ្ឋ-កិច្ច។ រតនគិរី គឺជាខេត្តមួយដែលភាគច្រើនជាសហគមន៍ជនជាតិដើមភាគតិចដែលប្រើប្រាស់ភាសាផ្សេងៗគ្នាខុសពីភាសាខ្មែរ។

សៀមរាប គឺជាខេត្តមួយស្ថិតនៅភាគពាយ័ព្យប្រទេសដែលប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ហើយខេត្តនេះក៏ទទួលបាននូវកំណើនភ្ញៀវទេសចរគួរឱ្យកត់សម្គាល់ផងដែរ ដោយសារតែមានប្រាសាទអង្គរវត្ត ប៉ុន្តែបើទោះជាដូច្នេះក្តី ក្រៅពីតំបន់ទីក្រុង ខេត្តនេះនៅតែបន្តជាខេត្តមួយក្នុងចំណោមបណ្តាខេត្តក្រីក្រដទៃទៀត។ ខេត្តសៀមរាបក៏មានចំនួនប្រជាជនកើនឡើងផងដែរ ដោយសារតែប្រជាពលរដ្ឋចំណាកស្រុកមកកាន់ខេត្តសៀមរាប។ កំពត គឺជាខេត្តមួយស្ថិតនៅតាមបណ្តោយឆ្នេរភាគខាងត្បូងប្រទេសដែលប្រជាពលរដ្ឋភាគច្រើនប្រកបរបរនេសាទ និងធ្វើស្រែជាចម្បង ប៉ុន្តែនាពេលថ្មីៗនេះក៏មានកំណើននៅក្នុងវិស័យទេសចរណ៍ផងដែរ។ ខេត្តនេះក៏មានសហគមន៍ជនជាតិឥស្លាមមួយដ៏ធំផងដែរ។

២.២ កិច្ចសម្ភាសន៍ ព្រមទាំងទំហំ និងការជ្រើសរើសក្រុមពិភាក្សា

ក្រុមពិភាក្សាចំនួនពីរក្រុមដែលមានប្រជាពលរដ្ឋសហគមន៍ចូលរួមចន្លោះពី១០-១២នាក់ត្រូវបានធ្វើឡើងនៅក្នុងឃុំនីមួយៗ ក្នុងនោះក្រុមពិភាក្សាមួយក្រុមផ្តោតលើសហគមន៍សាលាបឋមសិក្សា និងក្រុមពិភាក្សាមួយក្រុមទៀតផ្តោតលើសហគមន៍សាលាអនុវិទ្យាល័យ។ អ្នកចូលរួមរួមមានគណៈកម្មការទ្រទ្រង់

សាលារៀន (SSC) និងឪពុកម្តាយសិស្សនៅក្នុងតំបន់ក្បែរសាលារៀន។ ពួកគេត្រូវបានកំណត់តាមរយៈការណែនាំពីអាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារនៅក្នុងឃុំនីមួយៗ។ ដោយមានជំនួយពីមេភូមិ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារនៅក្នុងមូលដ្ឋានក្រុមស្រាវជ្រាវរបស់ NEP បានអញ្ជើញសហគមន៍ឱ្យចូលរួមក្រុមពិភាក្សា មុនពេលការប្រមូលទិន្នន័យជាក់ស្តែង។

មានក្រុមពិភាក្សាចំនួនពីរប្រភេទ ដែលមានសិស្សចូលរួមចន្លោះពី៨នាក់ទៅ១០នាក់នៅក្នុងក្រុមនីមួយៗ ក្នុងនោះក្រុមពិភាក្សាមួយត្រូវបានធ្វើឡើងជាមួយសិស្សសាលាបឋមសិក្សា និងក្រុមពិភាក្សាមួយទៀតធ្វើឡើងជាមួយសិស្សអនុវិទ្យាល័យ។ សម្រាប់ក្រុមទាំងពីរនេះយើងមានគោលបំណងបង្កលក្ខណៈឱ្យមានការចូលរួមស្មើភាពគ្នារវាងកុមារា និងកុមារី ដែលមានអាយុចន្លោះពី១០-១៦ឆ្នាំ។

យើងមានគោលបំណងសម្ភាសន៍កុមារ២-៣នាក់ ក្នុងមួយស្រុកដែលបានបោះបង់ការសិក្សាមុនថ្នាក់ទី៩ក្នុងរយៈពេល៥ឆ្នាំកន្លងមក និងដែលកំពុងរស់នៅក្នុងឃុំដែលត្រូវបានជ្រើសរើស ព្រមទាំងមានអាយុចន្លោះពី១០ឆ្នាំ ទៅ ១៨ឆ្នាំ នៅពេលសម្ភាសន៍។ យើងក៏បានពិចារណាទៅលើកុមារដែលមិនធ្លាប់បានចូលរៀនសោះជាបេក្ខភាពប្រកបដោយសក្តានុពលសម្រាប់សម្ភាសន៍ផងដែរ។

ក្រុមស្រាវជ្រាវបានជួបប្រទះការលំបាកមួយចំនួនក្នុងការស្វែងរកកុមារដែលបានបោះបង់ការសិក្សា ឬមិនធ្លាប់បានចូលរៀនដើម្បីធ្វើសម្ភាសន៍។ ជាញឹកញាប់ពួកគេរមែងតែងចូលរួមនៅក្នុងសកម្មភាពបង្កើនប្រាក់ចំណូលដូចជាការធ្វើស្រែចម្ការ ការលក់កម្លាំងពលកម្ម និងការប្រមូលអនុផលព្រៃឈើនៅក្រៅភូមិ។ កុមារមួយចំនួនដែលបានបោះបង់ការសិក្សាមិនចង់និយាយជាមួយក្រុមស្រាវជ្រាវឡើយ ហើយកុមារដទៃទៀតមានការលំបាកក្នុងការប្រាស្រ័យទាក់ទងដូចជាកុមារពិការសតិបញ្ញា។ ដើម្បីកាត់បន្ថយបញ្ហាទាំងនេះក្រុមការងារបានណាត់ជួបជាមួយកុមារនៅក្រៅម៉ោងធ្វើការរបស់ពួកគេព្រមទាំងបានស្នើសុំការគាំទ្រពីអាណាព្យាបាលក្នុងករណីចាំបាច់និងសមស្រប។

គ្រូបង្រៀនចំនួន៧នាក់មកពីសាលាបឋមសិក្សានិងអនុវិទ្យាល័យក្នុងឃុំនីមួយៗត្រូវបានសម្ភាសន៍។ គ្រូបង្រៀនត្រូវបានជ្រើសរើសដោយប្រើប្រាស់វិធីសាស្ត្រជ្រើសរើសសំណាកសមស្រប និងតាមរយៈការទាក់ទងជាមួយនាយកសាលា។ ក្រុមការងាររបស់ NEP បានសុំការអនុញ្ញាតពីគ្រប់អ្នកចូលរួមទាំងអស់ មុនពេលសម្ភាសន៍ពួកគេ ដើម្បីទទួលបានការចូលរួមដោយស្ម័គ្រចិត្តក្នុងការផ្តល់ព័ត៌មាន។

**តារាងទី៣ ៖ ចំនួនអ្នកផ្តល់ចម្លើយនៅក្នុងតំបន់ដែលបានធ្វើការសិក្សាស្រាវជ្រាវ**

| វិធីសាស្ត្រប្រមូលទិន្នន័យ | ចំនួន FGD/ សម្ភាសន៍ ក្នុងខេត្តសៀមរាប | ចំនួន FGD/ សម្ភាសន៍ ក្នុងខេត្តកំពត | ចំនួន FGD/ សម្ភាសន៍ ក្នុងខេត្តរតនគិរី | សរុប |
|---|---|---|---|---|
| ក្រុមពិភាក្សា(FGD) ជាមួយឪពុកម្តាយរបស់សិស្សបឋមសិក្សា | 4 | 4 | 4 | 12 |
| ក្រុមពិភាក្សា(FGD) ជាមួយឪពុកម្តាយ របស់អនុវិទ្យាល័យ | 4 | 4 | 4 | 12 |
| ក្រុមពិភាក្សា(FGD) ជាមួយសិស្សបឋមសិក្សា | 4 | 4 | 4 | 12 |
| ក្រុមពិភាក្សា(FGD) ជាមួយសិស្សអនុវិទ្យាល័យ | 4 | 4 | 4 | 12 |
| កិច្ចសម្ភាសន៍ជាមួយសិស្សបោះបង់ការសិក្សា | 9 | 12 | 16 | 37 |
| កិច្ចសម្ភាសន៍ជាមួយកុមារដែលមិនធ្លាប់បានចូលរៀន | 0 | 1 | 1 | 2 |
| កិច្ចសម្ភាសន៍ជាមួយគ្រូបឋមសិក្សា | 14 | 16 | 13 | 43 |
| កិច្ចសម្ភាសន៍ជាមួយគ្រូអនុវិទ្យាល័យ | 14 | 12 | 15 | 41 |

ក្រោយពេលដែលសេចក្តីព្រាងទី១ នៃរបាយការណ៍ត្រូវបានបញ្ចប់សិក្ខាសាលាពិគ្រោះយោបល់មួយត្រូវបានរៀបចំឡើងដើម្បីប្រមូលព័ត៌មានបន្ថែមទៀត ជាពិសេសព័ត៌មានពីកុមារពិការ កុមារជនជាតិដើមភាគតិច ឪពុកម្តាយរបស់ពួកគេ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើវិស័យពិការភាព និងជនជាតិដើមភាគតិច។ មានកុមារជនជាតិដើមភាគតិចចំនួន៦នាក់មកពីខេត្តកំពត និងខេត្តរតនគិរី កុមារពិការ១០នាក់មកពីខេត្តសៀមរាប កំពត និងរាជធានីភ្នំពេញ ឪពុកម្តាយ៣នាក់ ជាក្រុមជនជាតិដើមភាគតិចមកពីខេត្តរតនគិរី ឪពុកម្តាយកុមារពិការចំនួន១០នាក់មកពីខេត្តសៀមរាប កំពត និងរាជធានីភ្នំពេញ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន៥នាក់មកពីខេត្តកំពត សៀមរាប រតនគិរី និងរាជធានីភ្នំពេញ។

### ២.៣. ក្រុមប្រឹក្សាយោបល់សម្រាប់ការស្រាវជ្រាវ

NEP បានរៀបចំបង្កើតក្រុមប្រឹក្សាយោបល់សម្រាប់ការស្រាវជ្រាវមួយដែលរួមមានសមាជិកចំនួន៦រូប តំណាងឱ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ អង្គការយូណេស្កូ ប្រចាំប្រទេសកម្ពុជា អង្គការ VSO ប្រចាំប្រទេសកម្ពុជា អង្គការ Action Aid និងគ្រូបង្រៀន។ សមាជិកក្រុមប្រឹក្សាយោបល់បានផ្តល់មតិ និងយោបល់ត្រឡប់នៅរាល់គ្រប់ដំណាក់កាលសំខាន់ៗទាំងអស់នៃការស្រាវជ្រាវ ដើម្បីធានាថាការស្រាវជ្រាវនេះមានល័ក្ខខ័ណ្ឌស្របតាមការតម្រូវរបស់ អង្គការយូណេស្កូ និងអង្គការ VSO ប្រចាំប្រទេសកម្ពុជា។ ក្រុមប្រឹក្សាយោបល់សម្រាប់ការស្រាវជ្រាវបានជួបប្រជុំចំនួន៥លើក ហើយសមាជិកមួយចំនួនបានផ្តល់ព័ត៌មានបន្ថែម និងអនុសាសន៍ក្រៅកិច្ចប្រជុំទាំងនោះ។

## ៣. ការវិភាគទៅលើស្ថានភាពបច្ចុប្បន្ន និងភស្តុតាងដែលមានស្រាប់

### ៣.១. ការទទួលបានការអប់រំ

អត្រាចុះឈ្មោះចូលរៀនពិតនៅកម្រិតបឋមសិក្សាបានកើនឡើងពី៩៥,៨% ក្នុងឆ្នាំសិក្សា២០០៩-២០១០ទ៩៧% ក្នុងឆ្នាំសិក្សា២០១២-២០១៣[14]។ បើទោះជាដូច្នេះក្តីព័ត៌មានដែលទទួលបានពីការអង្កេតសង្គមសេដ្ឋកិច្ចនៅកម្ពុជា (CSES) និងមូលដ្ឋានទិន្នន័យឃុំសម្រាប់រយៈពេលដូចគ្នានេះបង្ហាញឱ្យឃើញថាការចូលរួមនៅក្នុងការអប់រំកម្រិតបឋមសិក្សាអាចពុំមានកម្រិតខ្ពស់បែបនេះឡើយ[15]។

**រូបភាពទី១ ៖ អត្រាចុះឈ្មោះចូលរៀនពិតក្នុងកម្រិតបឋមសិក្សា**




[14]នាយកដ្ឋានផែនការ (២០១៣) *ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣*។ ក្រសួងអប់រំ យុវជន និងកីឡា ៖ ភ្នំពេញ។ តួលេខពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ត្រូវបានដកស្រង់ពី EMIS 2009/10, EMIS 2010/11 និង EMIS 2011/12

[15]តួលេខ CSES និងតួលេខមូលដ្ឋានទិន្នន័យឃុំ ត្រូវបានប្រមូលដោយក្រសួងផែនការ។ តួលេខសម្រាប់ឆ្នាំ២០០៩ និងឆ្នាំ២០១០ ពីមូលដ្ឋានទិន្នន័យឃុំ ត្រូវបានដោនឡូតនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ ពីវិបសាយ ៖ http://db.ncdd.gov.kh/cdbonline/home/index.castle។ តួលេខឆ្នាំ២០១១ ត្រូវបានដកស្រង់ពីបទបង្ហាញមួយ ដែលធ្វើឡើងដោយ Peter De Vries ប្រធានផ្នែកអប់រំនៃអង្គការយូនីសេហ្វ ប្រចាំប្រទេសកម្ពុជា នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ នៅក្នុងកិច្ចប្រជុំមួយរបស់ក្រុមការងារវិស័យអប់រំ។ តួលេខ CSES ត្រូវបានដោនឡូតនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ពីវិបសាយ ៖ http://www.nis.gov.kh/index.php/social-statistics/cses/cses-tables ។

អត្រាចុះឈ្មោះចូលរៀនសម្រាប់អនុវិទ្យាល័យមានកម្រិតទាប ដែលបណ្តាលមកពីកុមារជាច្រើនអាយុចន្លោះពី១២-១៤ឆ្នាំ កំពុងសិក្សានៅកម្រិតបឋមសិក្សានៅឡើយក្រោយពេលដែលពួកគេចាប់ផ្តើមចូលរៀនយឺតនៅកម្រិតបឋមសិក្សាឬរៀនត្រួតថ្នាក់។ EMIS និងCSES បានផ្តល់ស្ថិតិដែលមានលក្ខណៈខុសគ្នាបន្តិចបន្តួចពីឆ្នាំសិក្សា ២០០៩-២០១០ រហូតដល់ឆ្នាំសិក្សា២០១២-២០១៣ ដូចមានបង្ហាញនៅក្នុងរូបភាពទី២។

**រូបភាពទី២ ៖ អត្រាចុះឈ្មោះចូលរៀនពិតនៅកម្រិតមធ្យមសិក្សាបឋមភូមិ**




ក្នុងរយៈពេលដូចគ្នានេះ កុមារជាមធ្យមចំនួន១១៨.០០០នាក់ក្នុងមួយឆ្នាំបានចូលរៀនថ្នាក់ទី១ក្រោយអាយុ៦ឆ្នាំដែលជាអាយុដែលពួកគេគួរចាប់ផ្តើមចូលរៀន[16]។ ចំណុចនេះបង្ហាញឱ្យដឹងថាមានកុមារជាច្រើនគួរឱ្យកត់សម្គាល់មិនបានចូលរៀនកម្រិតបឋមសិក្សានៅពេលដែលពួកគេអាចចូលរៀនបាន និងនៅតែមានបញ្ហាទាក់ទងទៅនឹងលទ្ធភាពទទួលបានសេវា។ បន្ថែមពីលើអត្រាបោះបង់ការសិក្សាគួរឱ្យកត់សម្គាល់ក្នុងគ្រប់ថ្នាក់ទាំងអស់នៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យវាបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថាការសម្រេចឱ្យបាននូវការអប់រំសម្រាប់ទាំងអស់គ្នា (EFA) នៅតែជាបញ្ហាប្រឈម បើទោះបីជាអត្រាទាំងនេះបានធ្លាក់ចុះចាប់តាំងពីមុនឆ្នាំ២០០៦ ក៏ដោយ។

[16]នាយកដ្ឋានផែនការ (២០១៣) *ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣*។ ភ្នំពេញ ៖ ក្រសួងអប់រំ យុវជន និងកីឡា និងឯកសារដែលត្រូវបានបោះពុម្ពនៅចន្លោះឆ្នាំ២០០៩-២០១២។ សូមមើលឧបសម្ព័ន្ធ១ អំពីការវិភាគចំនួនកុមារ ចាប់ផ្តើមចូលរៀនថ្នាក់ទី១ ក្រោយអាយុ៦ឆ្នាំ ដែលបង្ហាញថាអត្រាចុះឈ្មោះចូលរៀនសុទ្ធអាចមានចំនួនទាបជាង ៩៧%។

**រូបភាពទី៣ ៖ អត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា (EMIS)[17]**




ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងសាងសង់សាលារៀនគ្រប់កម្រិតទាំងអស់ក្នុងនោះរួមមានសាលាបឋមសិក្សាថ្មីចំនួន ៣៨៥ និងអនុវិទ្យាល័យចំនួន ៨២នៅចន្លោះឆ្នាំសិក្សា ២០០៩-២០១០ និងឆ្នាំសិក្សា ២០១២-២០១៣ ក្នុងនោះសាលារៀនប្រមាណពាក់កណ្តាលនៃប្រភេទសាលានីមួយៗ ត្រូវបានសាងសង់នៅតំបន់ជនបទ និងពាក់កណ្តាលទៀតនៅតំបន់ទីក្រុង។ បើទោះជាដូច្នេះក្តី សាលាអនុវិទ្យាល័យនៅតែមានចំនួនទាបជាងក្នុងឆ្នាំសិក្សា២០១២-២០១៣ បើធៀបទៅនឹងឆ្នាំសិក្សា ២០១០-២០១១[18]។

ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់អាហារូបករណ៍ដើម្បីជួយដល់ការទទួលបានការអប់រំ និងកាត់បន្ថយការបោះបង់ការសិក្សា ជាពិសេសក្នុងចំណោមកុមារក្រីក្រ។ នៅក្នុងឆ្នាំសិក្សា២០១៣-២០១៤ អាហារូបករណ៍ចំនួន៥៦.៤៧៧នាក់ ដែលមានតម្លៃជាទឹកប្រាក់ចំនួន៤៥ដុល្លាក្នុងមួយឆ្នាំត្រូវបានផ្តល់ជូនសិស្សអនុវិទ្យាល័យជាទឹកប្រាក់ចំនួន ៤៥ដុល្លា[19]។ អត្រាបោះបង់ការសិក្សាក្នុងចំណោមសិស្សអាហារូប-ករណ៍នៅថ្នាក់ទី៧ និងថ្នាក់ទី៨ ក្នុងឆ្នាំសិក្សា២០១២-២០១៣ មានកម្រិតទាបជាង គួរឱ្យកត់សម្គាល់បើធៀបទៅ នឹងចំនួនសិស្សទាំងអស់ដែលរៀនថ្នាក់ដូចគ្នា ក្នុងឆ្នាំសិក្សា ២០១១-២០១២ ដែលបង្ហាញឱ្យឃើញអំពីការរួមចំណែកគួរឱ្យកត់សម្គាល់របស់អាហារូបករណ៍ ក្នុងការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ។ បើទោះជាដូច្នេះក្តី អត្រាបោះបង់ការសិក្សារបស់សិស្សអាហារូបករណ៍នៅថ្នាក់ទី៩ នៅតែបន្តមានកម្រិតខ្ពស់ដូចគ្នាទៅនឹងសិស្សទូទៅដែរ។

---

[17]នាយកដ្ឋានផែនការ (២០១៣) *ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣*។ ក្រសួងអប់រំ យុវជន និងកីឡា ៖ ភ្នំពេញ។ តួលេខពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ ត្រូវបានដកស្រង់ចេញពី EMIS 2009/10, EMIS 2010/11 និង EMIS 2011/12។ សូមមើឧបសម្ព័ន្ធ២ សម្រាប់ការពិភាក្សាអំពីអត្រាបោះបង់ការសិក្សាដែលត្រូវបានរាយការណ៍ និងមូលហេតុដែលអត្រានេះទំនងនឹងមានកម្រិតខ្ពស់ជាងច្រើន ដែលមានចំនួនប្រមាណ ៧,៦%។

[18]នាយកដ្ឋានផែនការ (២០១៣) *ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣*។ ភ្នំពេញ ៖ ក្រសួងអប់រំ យុវជន និងកីឡា និងឯកសារដែលត្រូវបានបោះពុម្ពចន្លោះពីឆ្នាំ២០០៩-២០១២។ រាល់ព័ត៌មានទាំងអស់នៅក្នុងរូបភាព ៥,៦,៧,៨ និង ៩ ត្រូវបានដកស្រង់ចេញពីប្រភពនេះ។

[19]ក្រសួងអប់រំ យុវជន និងកីឡា បទបង្ហាញដែលមានចំណងជើងថា *កម្មវិធីអាហារូបករណ៍សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា* ដែលត្រូវបានបង្ហាញនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី២៣-២៥ ខែមករា ឆ្នាំ២០១៤។

តារាងទី៤ ៖ អត្រាបោះបង់ការសិក្សាក្នុងចំណោមសិស្សអាហារូបករណ៍

| | ថ្នាក់ទី៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ |
|---|---|---|---|
| អត្រាបោះបង់ការសិក្សាក្នុងចំណោមសិស្សអាហារូបករណ៍ (២០១២/២០១៣) | 5.01% | 11.90% | 23% |
| អត្រាបោះបង់ការសិក្សាទូទាំងប្រទេស (២០១១/២០១២) | 24.21% | 22.3% | 22.7% |

អង្គការមិនមែនរដ្ឋាភិបាលក៏បានផ្តល់អាហារូបករណ៍ផងដែរ។ ក្នុងឆ្នាំ២០១០ អង្គការមិនមែនរដ្ឋាភិបាលចំនួន៤៩ បានផ្តល់សម្ភារៈសិក្សាជូនដល់សិស្សបឋមសិក្សាចំនួន ១៩.៥២៤នាក់ ក្នុងខេត្តចំនួន ១៨ និងរាជធានីភ្នំពេញ។ អង្គការមិនមែនរដ្ឋាភិបាលចំនួន ២៤ បានផ្តល់អាហារូបករណ៍ជាសាច់ប្រាក់ជូនដល់សិស្សបឋមសិក្សា និងមធ្យមសិក្សាចំនួន ២.៣១៣នាក់ ក្នុងខេត្តចំនួន៩ និងរាជធានីភ្នំពេញ។ អង្គការមិនមែនរដ្ឋាភិបាលចំនួន៣ បានផ្តល់សម្ភារៈសិក្សា និងថវិកាជូនដល់សិស្សបឋមសិក្សាចំនួន ២១៥នាក់ក្នុងខេត្តចំនួន៣ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន១៣បានផ្តល់កង់ ជូនដល់សិស្សមធ្យមសិក្សាចំនួន ៥.០០៤នាក់ ក្នុងខេត្តចំនួន១១[20]។

កម្មវិធីស្បៀងអាហារពិភពលោកបាន នឹងកំពុងដំណើរការកម្មវិធីអាហារូបករណ៍អស់រយៈពេលជិត ១០ឆ្នាំ មកហើយ។ កម្មវិធីអាហារូបករណ៍ទាំងនេះ (ស្បៀងអាហារ ឬ សាច់ប្រាក់) ត្រូវបានផ្តល់ជូនដល់គ្រួសារក្រីក្រខ្លាំងដែលមានកូនកំពុងរៀនថ្នាក់ទី៤ ទៅ ថ្នាក់ទី៦។ ប្រព័ន្ធ "អត្តសញ្ញាណកម្មគ្រួសារក្រីក្រ" (ID Poor) របស់រដ្ឋាភិបាលត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើសគ្រួសារក្រីក្រ។ អាហារូបករណ៍ជាស្បៀងប្រចាំខែផ្តល់នូវអង្ករចំនួន១០គីឡូក្រាមក្នុងមួយខែសម្រាប់រយៈពេល១០ខែដែលសិស្សរៀននៅឯសាលា ដោយឡែកអាហារូបករណ៍ជាសាច់ប្រាក់ផ្តល់នូវចំនួនទឹកប្រាក់សមមាត្រមួយ ដោយផ្អែកលើតម្លៃទីផ្សារអង្ករក្នុងស្រុក ឧទាហរណ៍ដូចជា ២០.០០០ រៀលក្នុងមួយខែ (២០០.០០០រៀល ឬ ៥០ដុល្លា ក្នុងមួយឆ្នាំសិក្សា) ជាមួយនឹងល័ក្ខខ័ណ្ឌថា កុមារដែលទទួលបានអាហារូបករណ៍ត្រូវរក្សាអត្រាវត្តមានយ៉ាងហោចណាស់ឱ្យបាន ៨០% ដែលអត្រានេះត្រូវបានគណនាប្រចាំខែ។

កម្មវិធីអាហារូបករណ៍ជាស្បៀងអាហារបាននឹងកំពុងដំណើរការចាប់តាំងពីឆ្នាំ២០០៤ ហើយកម្មវិធីអាហារូបករណ៍ជាសាច់ប្រាក់ត្រូវបានណែនាំ ជាលើកដំបូងនៅចុងឆ្នាំ២០១១។ ក្នុងឆ្នាំសិក្សា ២០១២-២០១៣ កម្មវិធីទាំងនេះបានគ្របដណ្តប់សិស្សចំនួន៩៧.០០០នាក់ (៨៨.០០០នាក់ទទួលបានអាហារូប-ករណ៍ជាស្បៀងអាហារ និង៩.០០០នាក់ទទួលបានអាហារូបករណ៍ជាសាច់ប្រាក់) នៅក្នុងសាលាបឋមសិក្សាចំនួន៤.២៧៥ (៦២%) ក្នុងខេត្តចំនួន១៥។ អត្រាបោះបង់ការសិក្សាសម្រាប់កម្មវិធីអាហារូបករណ៍ជាសាច់ប្រាក់មានចំនួន២,៣៧% ដែលទាបជាងអត្រាបោះបង់ការសិក្សាកម្រិតថ្នាក់ជាតិ បើទោះបីជាក្រុម

[20]NEP, របាយការណ៍អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារលើវិស័យអប់រំ ឆ្នាំ២០១០, ២០១១ ភ្នំពេញ កម្ពុជា។

នេះស្ថិតនៅក្នុងចំណោមក្រុមកុមារដែល គេរំពឹងថាមានអត្រាបោះបង់ការសិក្សាខ្ពស់ជាងកម្រិតមធ្យមភាគ ក៏ដោយ[21]។

បើទោះបីជាសិស្សដែលទទួលបានអាហារូបករណ៍ជាសាច់ប្រាក់ ត្រូវបានលើកទឹកចិត្តឱ្យចំណាយថវិការបស់ពួកគេទៅលើស្បៀងអាហារដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងគ្រួសារក៏ដោយ ប៉ុន្តែពួកគេមានសេរីភាពក្នុងការជ្រើសរើសចំណាយថវិការបស់ពួកគេទៅលើខ្ទង់ចំណាយដទៃទៀត។ កុមារចំនួន ៤១នាក់ និងអាណាព្យាបាលរបស់ពួកគេត្រូវបានសម្ភាសន៍ក្នុងអំឡុងពេលធ្វើការវាយតម្លៃកម្មវិធី ហើយពួកគេបានផ្តល់ព័ត៌មានអំពីអ្វីដែលពួកគេបានទិញ ដោយប្រើប្រាស់សាច់ប្រាក់អាហារូបករណ៍[22]។ កុមារ/ អាណាព្យាបាលគ្រប់រូបបានប្រើប្រាស់ថវិកា ដើម្បីទិញសម្ភារៈរៀនសូត្រដែលចំណុចនេះមានលក្ខណៈគួរឱ្យចាប់អារម្មណ៍អាស្រ័យដោយកង្វះសម្ភារៈទាំងនេះរមែងតែងត្រូវបានគូសបញ្ជាក់នៅក្នុងការសិក្សាស្រាវជ្រាវនេះថា ជាមូលហេតុមួយដែលធ្វើឱ្យកុមារបោះបង់ការសិក្សាមុនថ្នាក់ទី៩។

**តារាងទី៥ ៖ ភាគរយនៃការបែងចែកចំណាយប្រាក់អាហារូបករណ៍**

| ខ្ទង់ចំណាយ | ភាគរយនៃអ្នកផ្តល់សម្ភាសន៍ដែលបានចំណាយថវិកាទៅលើខ្ទង់ចំណាយនោះ | ចំនួនថវិកាដែលបានចំណាយទៅលើខ្ទង់ចំណាយនោះ គិតជាភាគរយនៃចំនួនថវិកាសរុបដែលបានចំណាយ |
|---|---|---|
| **សម្ភារៈសិក្សា** | 100% | 20% |
| **ឯកសណ្ឋានសាលារៀន** | 90% | 21% |
| **អាហារ** | 83% | 56% |
| **ការថែទាំសុខភាព** | 22% | 3% |
| **ផ្សេងៗ** | 12% | 1% |

ដោយពង្រឹងបន្ថែមទៅលើគម្រោងអាហារូបករណ៍ដែលមានស្រាប់ នៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើតឱ្យមានកម្មវិធីអាហារូបករណ៍ថ្នាក់ជាតិមួយសម្រាប់ថ្នាក់ទី៤ដល់ថ្នាក់ទី៩ ដែលនឹងគាំទ្រដល់កុមារចំនួន ១៣៣.០០០នាក់ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៧។ សម្រាប់ថ្នាក់ទី៤ រហូតដល់ថ្នាក់ទី៦សិស្សចំនួន ៧០.០០០នាក់ ពីសាលាបឋមសិក្សាចំនួន១.០០០ ពីគ្រប់ខេត្តទាំងអស់ [23] នឹងមានល័ក្ខខ័ណ្ឌសមស្របដើម្បីទទួលបានអាហារូបករណ៍ប្រចាំឆ្នាំចំនួន៣០ដុល្លាសហរដ្ឋអាមេរិក និងសិស្សអនុវិទ្យាល័យចំនួន ៦៣.០០០នាក់ មកពីសាលាអនុវិទ្យាល័យ

---

[21]ការឆ្លើយឆ្លងតាមអ៊ីម៉ែល រវាង គង់ កន្និដ្ឋា នៃអង្គការស្បៀអាហារពិភពលោក និង Gordon Conochie ទីប្រឹក្សា VSO របស់អង្គការ NEP នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៤។

[22]កម្មវិធីស្បៀងអាហារពិភពលោក ៖ *គំហើញពីការវាយតម្លៃឆាប់រហ័សមួយទៅលើការអនុវត្តន៍សាកល្បងកម្មវិធីអាហារូបករណ៍សាច់ប្រាក់ថ្មីមួយ ជាមួយ AMK។ មិនត្រូវបានបោះពុម្ពផ្សាយ។*

[23]ពុំមានការត្រួតស៊ីគ្នាជាមួយសិស្សដែលទទួលបានអាហារូបករណ៍តាមរយៈកម្មវិធីស្បៀងអាហារពិភពលោកឡើយ។

ចំនួន១.៧០០ ពីគ្រប់ខេត្តទាំងអស់ នឹងមានល័ក្ខខ័ណ្ឌសមស្របដើម្បីទទួលបានអាហារូបករណ៍ប្រចាំឆ្នាំចំនួន៦០ដុល្លាសហរដ្ឋអាមេរិក។ នៅក្នុងករណីទាំងពីរនេះសិស្សនឹងទទួលបានអាហារូបករណ៍លុះត្រាណាតែពួកគេបន្តចូលរៀននិងទទួលបានពិន្ទុគ្រប់គ្រាន់នៅឯសាលារៀន[24]។ សិស្សនឹងត្រូវបានជ្រើសរើស ដោយផ្អែកលើពិន្ទុរបស់ពួកគេនៅក្នុងសន្ទស្សន៍ហានិភ័យបោះបង់ការសិក្សា។

សម្ភារៈបរិក្ខារដែលមាននៅឯសាលារៀន ក៏អាចប៉ះពាល់ដល់ការចូលរៀនផងដែរ ដូចជាការគ្មានបង្គន់ ឬទឹកស្អាតអាចធ្វើឱ្យសិស្សមិនទៅសាលារៀន និងជួនកាលពួកគេត្រូវត្រឡប់មកផ្ទះវិញនៅពេល ដែលពួកគេត្រូវការប្រើប្រាស់សម្ភារៈបរិក្ខារទាំងនោះក្នុងម៉ោងរៀន និងមិនត្រឡប់មកសាលារៀនវិញ។ វាគឺជារឿងដែលគួរឱ្យព្រួយបារម្ភអាស្រ័យដោយស្ថិតិរបស់រដ្ឋាភិបាលបង្ហាញឱ្យដឹងថា មានសាលារៀនដែលពុំមានទឹកស្អាត និងបង្គន់ក្នុងកម្រិតភាគរយខ្ពស់ជាងក្នុងឆ្នាំសិក្សា២០១២-២០១៣ បើធៀបទៅនឹងឆ្នាំសិក្សា២០០៩-២០១០[25]។ នៅក្នុងបណ្តាខេត្តដែលយើងធ្វើការសិក្សាសម្រាប់របាយការណ៍នេះខេត្តរតនគិរី គឺជាខេត្តដែលមានទំនោរខ្ពស់ជាងគេដែលមានសាលារៀនគ្មានទឹកស្អាត និងបង្គន់ បើធៀបទៅនឹង មធ្យមភាគទូទាំងប្រទេស។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺពុំមានគម្លាតច្រើនគួរឱ្យកត់សម្គាល់រវាងតំបន់ជនបទ និងតំបន់ទីក្រុងឡើយ

**រូបភាពទី៤ ៖ ភាគរយនៃសាលារៀនដែលមានការផ្គត់ផ្គង់ទឹក**




[24]ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) នឹងគាំទ្រដល់កម្មវិធីអាហារូបករណ៍សម្រាប់ការអប់រំបឋមសិក្សា ក្នុងឆ្នាំសិក្សា ២០១៤-២០១៥។ កម្មវិធីអាហារូបករណ៍ជាតិសម្រាប់ថ្នាក់ទី៤ រហូតដល់ថ្នាក់ទី៦ នឹងទទួលបានហិរញ្ញប្បទានគាំទ្រពីថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីឆ្នាំ២០១៥តទៅ។ GPE នឹងផ្តល់ថវិកាបន្ថែមចំនួន ១៥ដុល្លាសហរដ្ឋអាមេរិក ពីលើថវិកាបច្ចុប្បន្នចំនួន ៤៥ដុល្លា សម្រាប់សិស្សមួយនាក់ ដែលទទួលបានមូលនិធិគាំទ្រពីថវិកាកម្មវិធីអាហារូបករណ៍ជាតិសម្រាប់អនុវិទ្យាល័យ (សរុបទឹកប្រាក់មានចំនួន ៦០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ)។ មូលនិធិគាំទ្រសរុបរបស់ GPE មានចំនួន៤លានដុល្លា។ កម្មវិធីអាហារូបករណ៍ជាតិសម្រាប់អនុវិទ្យាល័យ នឹងទទួលបានហិរញ្ញប្បទានគាំទ្រពីថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡាចាប់ពីឆ្នាំ២០១៧ តទៅ។

[25]នាយកដ្ឋានផែនការ (២០១៣) *ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣*។ ក្រសួងអប់រំ យុវជន និងកីឡា ៖ ភ្នំពេញ។ តួលេខពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ ត្រូវបានដកស្រង់ចេញពី EMIS 2009/10, EMIS 2010/11 និង EMIS 2011/12។

### រូបភាពទី៥ ៖ ភាគរយនៃសាលារៀនដែលមានបង្គន់




ឧបសគ្គមួយដែលអាចរាំងស្ទះដល់ការទទួលបានការអប់រំ អាចជាវត្តមាននៃការបង់ថ្លៃសាលារៀនក្រៅផ្លូវការ។ បើទោះបីជាកុមារមានសិទ្ធិទទួលបានការអប់រំឥតគិតថ្លៃរយៈពេល៩ឆ្នាំក្នុងប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែការស្រាវជ្រាវរបស់ NEP ក្នុងឆ្នាំ២០១២បានរកឃើញថា សិស្សដែលបានផ្តល់ចម្លើយចំនួន ៥៣% ត្រូវបង់ប្រាក់នៅពេលដែលពួកគេចូលរៀននៅឯសាលា និងឪពុកម្តាយដែលត្រូវបានសម្ភាសន៍ចំនួន ៦៧% បានប្រាប់ឱ្យដឹងថា ពួកគេត្រូវចំណាយប្រាក់នៅពេលដែលកូនរបស់ពួកគេទៅរៀននៅឯសាលា។ ជាញឹកញាប់ទាំងនោះគឺជាខ្ទង់ចំណាយដែលអ្នករំពឹងថា ជាការទទួលខុសត្រូវរបស់សាលារៀន និងក្រសួងអប់រំ យុវជន និងកីឡា[26]។

### តារាងទី៦ ៖ ភាពញឹកញាប់នៃការបង់ថ្លៃសាលារៀនក្រៅផ្លូវការ បែងចែកទៅតាមទីតាំង

| ប្រភេទចំណាយ | ភាគរយនៃសិស្សដែលបង់ប្រាក់ (តំបន់ទីក្រុង) | ភាគរយនៃសិស្សដែលបង់ប្រាក់ (តំបន់ជនបទ) | ភាគរយនៃសិស្សដែលបង់ប្រាក់ (តំបន់ទីដាច់ស្រយាល) |
|---|---|---|---|
| សម្ភារៈបង្រៀនសម្រាប់គ្រូបង្រៀន | 23% | 15% | 18% |
| អំណោយសម្រាប់គ្រូបង្រៀន | 21% | 7% | 3% |
| ថ្លៃប្រឡង | 22% | 13% | 22% |
| ក្រដាសមេរៀនរបស់គ្រូ | 20% | 12% | 10% |
| ថ្លៃបង្រៀនប្រចាំថ្ងៃ | 25% | 8% | 3% |
| សៀវភៅតាមដានការសិក្សា | 41% | 22% | 11% |
| ថ្លៃរៀនគួក្រៅសាលារៀន | 32% | 14% | 11% |
| ថ្លៃរៀនគួក្នុងសាលារៀន | 56% | 22% | 16% |

[26]Ang, S. & Conochie, G. (2012). *ការលើកកម្ពស់សិទ្ធិនៅក្នុងសាលារៀន* NEP: ភ្នំពេញ។

**តារាងទី៧ ៖ ចំនួនទឹកប្រាក់ដែលបង់ដោយឪពុកម្តាយ និងសិស្ស**

| ប្រភេទចំណាយ | ការឆ្លើយតបរបស់សិស្ស៖ ចំណាយជាមធ្យម(រៀល) | ការឆ្លើយតបរបស់ឪពុកម្តាយ៖ ចំណាយជាមធ្យម(រៀល) |
|---|---|---|
| សម្ភារៈបង្រៀនរបស់គ្រូបង្រៀន | 1400 ក្នុងមួយពេល | 6870 ក្នុងមួយពេល |
| អំណោយសម្រាប់គ្រូបង្រៀន | 6800 ក្នុងមួយឆ្នាំ | |
| ថ្លៃប្រឡង | 2300 ក្នុងមួយពេល | 2500 ក្នុងមួយពេល |
| ក្រដាសមេរៀនរបស់គ្រូ | 1800 ក្នុងមួយពេល | 3090 ក្នុងមួយពេល |
| ថ្លៃគ្រូបង្រៀន | 13200 ក្នុងមួយខែ | 16200 ក្នុងមួយខែ |
| សៀវភៅតាមដានការសិក្សា | 1200 ក្នុងមួយខែ | 1100 ក្នុងមួយខែ |
| ថ្លៃរៀនគួក្នុងសាលារៀន | 12500 ក្នុងមួយខែ | 12,480 ក្នុងមួយខែ |
| ថ្លៃរៀនគួក្រៅសាលារៀន | 18400 ក្នុងមួយខែ | 16410 ក្នុងមួយខែ |

អ្វីដែលមិនគួរឱ្យភ្ញាក់ផ្អើលនោះ គឺការស្រាវជ្រាវដដែលនេះបានរកឃើញថា សិស្សនៅតំបន់ទីក្រុងមានទំនោរខ្ពស់ជាងក្នុងការបង់ថ្លៃសាលារៀនក្រៅផ្លូវការ ដែលទំនងនឹងមានតម្លៃខ្ពស់ជាងផងដែរ។ ឧទាហរណ៍ចំណាយជាមធ្យមដែលត្រូវបង់សម្រាប់ថ្លៃប្រឡងមានតម្លៃ ៣.៥០០រៀល ក្នុងមួយដងសម្រាប់សិស្សនៅតំបន់ទីក្រុងនិងមានតម្លៃ ៩៥០រៀល ប៉ុណ្ណោះសម្រាប់សិស្សនៅតំបន់ជនបទ។ បន្ថែមពីនេះទៀតនៅរាជធានីភ្នំពេញសិស្សជិត៩០%បានរាយការណ៍ឱ្យដឹងថា ពួកគេបង់ប្រាក់ប្រចាំថ្ងៃទៅឱ្យគ្រូបង្រៀនដែលការបង់ប្រាក់បែបនេះ គឺជាករណីកម្រនៅក្នុងខេត្តដទៃទៀត។ បន្ថែមពីនេះទៀតសិស្សជាង ៩០% នៅរាជធានីភ្នំពេញត្រូវបានសូមឱ្យបង់ថ្លៃសៀវភៅតាមដានការសិក្សាប្រចាំខែដែលមានតម្លៃខ្ពស់ជាងផងដែរ បើធៀបទៅនឹងខេត្តដទៃទៀត។

### ៣.២. គុណភាពនៃការអប់រំ

នៅក្នុងការត្រួតពិនិត្យឡើងវិញនេះ យើងពិចារណាទៅលើសូចនាករដូចតទៅ៖ អត្រាត្រួតថ្នាក់ ផលធៀបរវាងចំនួនគ្រូបង្រៀន និងចំនួនសិស្ស និងសាវតាអប់រំរបស់គ្រូបង្រៀន ការបណ្តុះបណ្តាលគរុកោសល្យព្រមទាំងការបណ្តុះបណ្តាលខណៈពេលកំពុងបម្រើការងារ សម្រាប់ជាសូចនាករវាស់ស្ទង់គុណភាពអប់រំ។

សូចនាករមួយដែលបញ្ជាក់ថា ប្រទេសកម្ពុជាមានបញ្ហាប្រឈមទាក់ទង នឹងគុណភាពអប់រំគឺអត្រាត្រួតថ្នាក់ដែលមានកម្រិតខ្ពស់នៅសាលាបឋមសិក្សា ព្រមទាំងអត្រាត្រួតថ្នាក់ក្នុងកម្រិតមួយជាក់លាក់នៅអនុវិទ្យាល័យ។

មូលហេតុដែលសិស្សទទួលបានការអប់រំមិនល្អ អាចបណ្តាលមកពីកង្វះគ្រូបង្រៀន និងការដែលប្រទេសកម្ពុជាជួបប្រទះបញ្ហាខ្វះគ្រូបង្រៀនចាប់តាំងពីទសវត្សឆ្នាំ១៩៨០។ ផលធៀបរវាងចំនួនគ្រូបង្រៀន

និងសិស្សដែលមានចំនួនច្រើនជាពិសេសនៅតំបន់ជនបទអាចបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើការរៀនសូត្រ។

អង្គការយូណេស្កូបានផ្តល់ដំបូន្មានថា ផលធៀបគ្រូសិស្សដែលលើសពី៤០:១ អាចបង្ហាញថាហួសពីលទ្ធភាពគ្រប់គ្រងរបស់គ្រូបង្រៀន[27]។ នៅក្នុងប្រទេសកម្ពុជាផលធៀបរវាងចំនួនសិស្ស និងចំនួនគ្រូបង្រៀននៅកម្រិតបឋមសិក្សា គឺ៤៨,៥:១[28] ដែលផលធៀបនេះ មានកម្រិតខ្ពស់ជាងគេបំផុតលំដាប់លេខរៀងទី១៦ក្នុងចំណោមប្រទេសចំនួន២០២ បើផ្អែកលើព័ត៌មានដែលអង្គការយូណេស្កូមាន និងមានកម្រិតខ្ពស់ជាងគេបំផុតនៅក្រៅទ្វីបអាហ្វ្រិក[29]។

**រូបភាពទី៦ ៖ អត្រាត្រួតថ្នាក់នៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ (EMIS)**




**រូបភាពទី៧ ៖ ផលធៀបរវាងចំនួនគ្រូបង្រៀន និងចំនួនសិស្សនៅសាលាបឋមសិក្សា**




[27] វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ (n.d). *Education-Teachers.* ទទួលបាននៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៣ ពី http:www.uis.unesco.org/Education/Pages/Teacher-statistics.aspx.

[28] នាយកដ្ឋានផែនការ (២០១៣) *ស្ថិតិ និងសូចនាករអប់រំ ២០១២-២០១៣*។ ក្រសួងអប់រំ យុវជន និងកីឡា ៖ ភ្នំពេញ។

[29] វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ (n.d.). UNESCO eAtlas of Teachers. ទទួលបាននៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៣ ពីវិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ៖ http://www.app.collinsindicate.com/uis-atlas-teachers/en-us

របាយការណ៍កន្លងមកមួយរបស់អង្គការ NEP ក៏បានគូសបញ្ជាក់អំពីចំនួនគ្រូបង្រៀនបឋមសិក្សាដែលបានធ្លាក់ចុះចំនួន៦៧១នាក់ចាប់តាំងពីឆ្នាំសិក្សា ២០០៨-២០០៩ អាស្រ័យដោយគ្រូបង្រៀនដែលចាកចេញពីវិជ្ជាជីវៈនេះមានចំនួនច្រើនជាងគ្រូបង្រៀនដែលត្រូវបានជ្រើសរើស[30]។ ការសិក្សាស្រាវជ្រាវនេះបានព្យាករណ៍ថាក្រសួងអប់រំ យុវជន និងកីឡា នឹងត្រូវការគ្រូបង្រៀនបឋមសិក្សាចំនួន ៥៤.៣៣៥នាក់ដើម្បីសម្រេចឱ្យបាននូវផលធៀបសិស្សចំនួន៤០នាក់សម្រាប់គ្រូមួយនាក់ក្នុងឆ្នាំ២០១៣។ ដូច្នេះមានន័យថាក្រសួងអប់រំ យុវជន និងកីឡា ត្រូវការគ្រូបង្រៀនចំនួន ៩.៤៩៥នាក់ទៀតបន្ថែមពីលើអ្វីដែលពួកគេមានក្នុងឆ្នាំ២០១៣។

បច្ចុប្បន្នមានវិធីចំនួន៤ សម្រាប់គ្រប់គ្រងបញ្ហាកង្វះគ្រូបង្រៀននេះដែលវិធីទាំងអស់នោះកំពុងត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជា និងសុទ្ធសឹងតែមានផលប៉ះពាល់អវិជ្ជមានទៅលើការរៀនសូត្ររបស់កុមារ ៖

- ផលធៀបរវាងចំនួនគ្រូបង្រៀន និងសិស្សដែលមានចំនួនច្រើននៅក្នុងថ្នាក់។
- គ្រូបង្រៀនពីរថ្នាក់ក្នុងមួយថ្ងៃ (ពីរវេន) ៖ ការស្រាវជ្រាវរបស់ NEP បានរកឃើញថា ១៨,៥% នៃ គ្រូបង្រៀនដែលត្រូវបានអង្កេតនៅសាលាបឋមសិក្សាបង្រៀនពីរវេន[31]។
- គ្រូបង្រៀនច្រើនកម្រិត៖ ស្ថិតិដែលទទួលបានពីនាយកដ្ឋានបុគ្គលិកក្នុងឆ្នាំ២០១២ បានបង្ហាញឱ្យថាគ្រូបឋមសិក្សាចំនួន ៣,៨% បង្រៀនថ្នាក់ច្រើនកម្រិត[32]។
- ការជ្រើសរើសគ្រូកិច្ចសន្យា៖ ក្នុងឆ្នាំ២០១៣ របស់ក្រសួងអប់រំ បានប្រើប្រាស់គ្រូកិច្ចសន្យាចំនួន ៣.៤៥៥នាក់ ក្នុងនោះ១.៨៥២នាក់ បង្រៀននៅក្នុងសាលារៀន និង១.១៨៤នាក់ទៀតបង្រៀនថ្នាក់អក្ខរកម្ម។ ចំនួនគ្រូកិច្ចសន្យាដែលបង្រៀននៅក្នុងសាលារៀនបានកើនឡើងពី១.៤២៩នាក់ក្នុងឆ្នាំសិក្សា ២០១០-២០១១[33]។

បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡា តម្រូវឱ្យបេក្ខភាពគរុសិស្សបឋមសិក្សា និងអនុវិទ្យាល័យត្រូវបញ្ចប់ការអប់រំថ្នាក់ទី១២ ដោយឡែកខេត្តរតនគិរី និងមណ្ឌលគិរី មានករណីលើកលែងពិសេសដែលអនុញ្ញាតឱ្យខេត្តទាំងពីរនេះទទួលយកបេក្ខភាពគរុសិស្សបឋមសិក្សាដែលបានបញ្ចប់ការអប់រំត្រឹមថ្នាក់ទី៩។ ករណីលើកលែងនេះ នឹងត្រូវបញ្ចប់ក្នុងឆ្នាំ២០១៥។ បើទោះជាដូច្នេះក្តី មានគ្រូបង្រៀនបឋមសិក្សាដែលមានស្រាប់ចំនួន៥៤% ប៉ុណ្ណោះបានបញ្ចប់ការអប់រំថ្នាក់ទី១២ និងគ្រូបង្រៀនបឋមសិក្សាចំនួន ៣% បានបញ្ចប់ការអប់រំកម្រិតបឋមសិក្សាប៉ុណ្ណោះ។ គ្រូបង្រៀនបឋមសិក្សាប្រមាណ ១២% គឺជាអ្នកដែលបានបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រឬបរិញ្ញាបត្រជាន់ខ្ពស់ ហើយក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសថាពួកគេគ្រោងតម្រូវឱ្យគ្រូបង្រៀនបឋមសិក្សា និងអនុវិទ្យាល័យទាំងអស់ត្រូវមានបរិញ្ញាបត្រនៅពេលអនាគត។

---

[30] Leng, T. & Conochie, G. (2013), *កុមារគ្រប់រូបត្រូវការគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់* ភ្នំពេញ NEP

[31] Ang, S ; Friend-Pereira, J ; Nsubuga, D and Chhum, S. (2012), ការប៉ាន់ប្រមាណផលប៉ះពាល់នៃគ្រឿងលើកទឹកចិត្តទៅលើទឹកចិត្តគ្រូបង្រៀន NEP : ភ្នំពេញ។

[32] Leng, T. & Conochie, G. (2013), *កុមារគ្រប់រូបត្រូវការគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់* ភ្នំពេញ NEP

[33] របាយការណ៍សង្ខេបអំពីការបំពេញការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំសិក្សា ២០១២-២០១៤។

តារាងទី៨ ៖ កម្រិតការអប់រំរបស់គ្រូបង្រៀនបឋមសិក្សា (2012/13)

| | កម្រិតបឋមសិក្សា | កម្រិតអនុវិទ្យាល័យ | កម្រិតវិទ្យាល័យ | បរិញ្ញាបត្រ/ បរិញ្ញាបត្រជាន់ខ្ពស់ |
|---|---|---|---|---|
| ខេត្តកំពត | 1% | 30% | 65% | 4% |
| ខេត្តរតនគិរី | 20% | 46% | 33% | 1% |
| ខេត្តសៀមរាប | 5% | 39% | 55% | 2% |
| ទូទាំងប្រទេស | 3% | 42% | 52% | 3% |
| តំបន់ទីក្រុង | 2% | 36% | 57% | 5% |
| តំបន់ជនបទ | 4% | 44% | 50% | 2% |

តារាងទី៩ ៖ កម្រិតការអប់រំរបស់គ្រូបង្រៀនមធ្យមសិក្សា (2012/13)

| | កម្រិតបឋមសិក្សា | កម្រិតអនុវិទ្យាល័យ | កម្រិតវិទ្យាល័យ | បរិញ្ញាបត្រ/ បរិញ្ញាបត្រជាន់ខ្ពស់ |
|---|---|---|---|---|
| ខេត្តកំពត | 0% | 14% | 55% | 31% |
| ខេត្តរតនគិរី | 0% | 2% | 68% | 30% |
| ខេត្តសៀមរាប | 1% | 14% | 57% | 28% |
| ទូទាំងប្រទេស | 1% | 17% | 55% | 27% |
| តំបន់ទីក្រុង | 1% | 15% | 46% | 38% |
| តំបន់ជនបទ | 1% | 17% | 60% | 21% |

# ៤. លទ្ធផលរកឃើញ និងការវិភាគ

## ៤.១. វត្តមាន និងលទ្ធភាពទទួលបានសេវាអប់រំ

នៅកម្រិតមូលដ្ឋានភាគច្រើនលទ្ធភាពទទួលបានសេវាត្រូវបានរាំងស្ទះដោយសារតែដំណើរការចុះឈ្មោះចូលរៀនមានការពិបាកឬត្រូវចំណាយថវិកាច្រើន។ ឪពុកម្ដាយច្រើនលើសលប់បានរាយការណ៍ឱ្យដឹងថាការចុះឈ្មោះចូលរៀននៅឯសាលារៀនគឺជាដំណើរការមួយដ៏ងាយស្រួល។ គ្រប់ក្រុមទាំងអស់បានប្រាប់ឱ្យដឹងថាគេត្រូវការឱ្យមានសំបុត្រកំណើត ហើយបុគ្គលមួយចំនួនបាននិយាយថាគេក៏ត្រូវការសៀវភៅគ្រួសារផងដែរ ឬសៀវភៅគ្រួសារអាចប្រើប្រាស់ជំនួសសំបុត្រកំណើត។ ឪពុកម្ដាយជាច្រើនបានប្រាប់ឱ្យដឹងថាគ្រូបង្រៀន ឬនាយកសាលាបានជួយបំពេញទម្រង់ ដែលធ្វើឱ្យដំណើរការមានភាពងាយស្រួល។

ឪពុកម្តាយមិនបានប្រាប់ឱ្យដឹងថា ការដែលត្រូវផ្តល់សំបុត្រកំណើតគឺជាបញ្ហាឡើយ ដោយឡែកសិស្សនៅក្នុងក្រុមពិភាក្សាមួយបានលើកឡើងអំពីចំណុចនេះថាជាបញ្ហា ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ ពុំមានរបាយការណ៍ណាមួយដែលបញ្ជាក់ថា ឪពុកម្តាយត្រូវបង់ប្រាក់ដើម្បីចុះឈ្មោះកូនចូលរៀនឡើយ។ បន្ថែមពីនេះទៀតមានគ្រូបង្រៀនចំនួន ៧% ប៉ុណ្ណោះនិយាយថាមានការបង់ថ្លៃសេវាពាក់ព័ន្ធមួយចំនួនក្នុងអំឡុងពេលចុះឈ្មោះចូលរៀន។

*៤.១.១. កត្តាដែលបង្កផលប៉ះពាល់ទៅលើលទ្ធភាពទទួលបានសេវា*

តារាងខាងក្រោមបង្ហាញអំពីកត្តានានាដែលត្រូវបានដកស្រង់ញឹកញាប់ពីឪពុកម្តាយ និងសិស្សថាជាកត្តាដែលមានសារៈសំខាន់ ដើម្បីធ្វើឱ្យកុមារមានភាពងាយស្រួលក្នុងការចូលរៀន។ កត្តាទាំងនេះត្រូវបានដកស្រង់ទៅតាមលំដាប់លំដោយនៃភាពញឹកញាប់ដែលបានលើកឡើង។

**តារាងទី១០ ៖ កត្តាបង្កឱ្យមានផលប៉ះពាល់ទៅលើលទ្ធភាពទទួលបានសេវា ដែលត្រូវបានលើកឡើងញឹកញាប់បំផុត**

| ឪពុកម្តាយ | សិស្ស |
|---|---|
| សម្ភារៈរៀនសូត្រ (សៀវភៅ ប៊ិច) | សម្ភារៈរៀនសូត្រ (សៀវភៅ ប៊ិច) |
| សិស្សមានមធ្យោបាយធ្វើដំណើរ | សិស្សមានមធ្យោបាយធ្វើដំណើរ |
| សាលារៀននៅជិតផ្ទះរបស់សិស្ស | សាលារៀននៅជិតផ្ទះរបស់សិស្ស |
| មានគ្រូបង្រៀនគ្រប់គ្រាន់ | ឥរិយាបថ និងការលើកទឹកចិត្តរបស់ឪពុកម្តាយ |
| មានទឹកស្អាត និងបង្គន់ | ឥរិយាបថគ្រូបង្រៀន ៖ វត្តមាន ការទទួលយកប្រាក់ ការប្រព្រឹត្តទៅលើសិស្ស |
| សិស្សមានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយនៅឯសាលារៀន | គុណភាពគ្រូបង្រៀន |
| សិស្សមានឯកសណ្ឋានសាលារៀន | សិស្សមានឯកសណ្ឋានសាលារៀន |

គួរកត់សម្គាល់ទៅលើការឯកភាពគ្នារវាងឪពុកម្តាយ និងសិស្សទៅលើកត្តាសំខាន់បំផុតទាំង៣ដែលស្ថិតនៅលើគេ។ ខណៈពេលដែលឪពុកម្តាយចាត់ទុកថាការមានគ្រូបង្រៀនគ្រប់គ្រាន់ជាបញ្ហាសំខាន់ចំណុចនេះមិនត្រូវបានសិស្សលើកឡើងញឹកញាប់ឡើយដោយឡែកសិស្សផ្តោតសំខាន់ទៅលើឥរិយាបថគ្រូបង្រៀន និងគុណភាពគ្រូបង្រៀន។ សិស្សស្ទើរតែមិនបានលើកឡើងអំពីការមានទឹកស្អាត និងបង្គន់អនាម័យ។

កត្តាដទៃទៀតដែលត្រូវបានលើកឡើងរួមមានសម្ភារៈបរិក្ខារគ្រប់គ្រាន់នៅឯសាលារៀន (សៀវភៅមេរៀន តុ កៅអី) និងផ្លូវថ្នល់ល្អ។ ផ្លូវថ្នល់គឺជាបញ្ហាព្រួយបារម្ភមួយខ្លាំងនៅរដូវវស្សាក្នុងខេត្តរតនគិរីជួនកាលមិនអាចជិះកង់បានឡើយដោយសារតែផ្លូវមានភក់ច្រើនពេក។ ក្រុមពិភាក្សាមួយចំនួនដែលមានសមាសភាព

ឪពុកម្តាយចូលរួមបានរៀបរាប់អំពីសារៈសំខាន់នៃការលើកទឹកចិត្តពីឪពុកម្តាយហើយសិស្សមួយចំនួនគិតថា ការមានកន្លែងក្មេងលេង ទោង និង វត្ថុក្មេងលេង គឺជាកត្តាសំខាន់។

ឪពុកម្តាយ និងគ្រូបង្រៀននៅខេត្តរតនគិរីក៏បានរៀបរាប់អំពីអន្តេវាសិកដ្ឋាន និងអាហារូបករណ៍ថា ជាកត្តាដែលមានសារៈសំខាន់ផងដែរ ប្រហែលជាដោយសារតែដង់ស៊ីតេប្រជាជនមានកម្រិតទាបនិងបញ្ហារយៈចម្ងាយពីសាលារៀន ដោយឡែកឪពុកម្តាយនៅខេត្តដទៃទៀត មិនបានរៀបរាប់អំពីបញ្ហាទាំងនេះឡើយ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺកុមារជនជាតិភាគតិច ដូចជាកុមារជនជាតិឥស្លាមដែលមកពីខេត្តកំពត និង កុមារជនជាតិគ្រឹងមកពីខេត្តរតនគិរី ដែលបានចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់បានកំណត់រកឃើញកត្តាស្រដៀងគ្នាទៅនឹងកុមារដទៃទៀត ដូចមានកត់សម្គាល់នៅក្នុងតារាងទី១០ដូច្នោះដែរ ៖ *កត្តាបង្កឱ្យមានផលប៉ះពាល់ទៅលើលទ្ធភាពទទួលបានសេវា ដែលត្រូវបានលើកឡើងញឹកញាប់បំផុត*។ កត្តាទាំង៥ ដែលត្រូវបានកំណត់រកឃើញនៅក្នុងសិក្ខាសាលានោះរួមមាន ៖

- សិស្សមានមធ្យោបាយធ្វើដំណើរទៅសាលារៀន
- សម្ភារៈរៀនសូត្រ
- សាលារៀននៅជិតផ្ទះសិស្ស
- សាលារៀនមានទឹកស្អាត បង្គន់ និងអនាម័យ
- គ្រូបង្រៀនល្អដែលមកបង្រៀនទៀងទាត់ និងពន្យល់សិស្សបានច្បាស់លាស់។

កុមារពិការបានកំណត់រកឃើញកត្តាចំនួន៥ ដែលធ្វើឱ្យពួកគេងាយស្រួលទៅរៀនក្នុងនោះកត្តាចំនួន៣ គឺដូចគ្នាទៅនឹងកត្តា៣ដំបូងគេដែលកុមារជនជាតិភាគតិចបានកំណត់រកឃើញ។ កត្តាចំនួន២ ដទៃទៀត គឺជាការលើកទឹកចិត្តពីឪពុកម្តាយ និងការលើកទឹកចិត្តពីសង្គម។ ការលើកទឹកចិត្តពីសង្គមអាចជាការលើកទឹកចិត្តពីគ្រូបង្រៀន និងសិស្សព្រមទាំងបរិយាកាសមិនរើសអើង។



ក្រុមពិភាក្សារបស់សិស្សនៅស្រុក ឈូក ខេត្តកំពត

### *៤.១.២. សម្ភារៈរៀនសូត្រ*

ឪពុកម្តាយ ជាពិសេសឪពុកម្តាយនៅស្រុកបន្ទាយស្រី (តំបន់ជនបទនៃខេត្តសៀមរាប) បានប្រាប់ឱ្យដឹងអំពីបញ្ហាកង្វះសម្ភារៈរៀនសូត្រ ហើយសិស្សបានលើកឡើងអំពីបញ្ហាកង្វះសម្ភារៈរៀនសូត្រនេះ ញឹកញាប់ជាងកត្តាជាច្រើនដទៃទៀតនៅពេលដែលពួកគេពិចារណាអំពីកត្តាដែលធ្វើឱ្យកុមារមានការលំបាកក្នុងការទៅសាលារៀន។ ក្រុមពិភាក្សានីមួយៗដែលមានសមាសភាពសិស្សចូលរួមក្នុងខេត្តរតនគិរីបានរៀបរាប់អំពីចំណុចនេះដូចគ្នាទៅនឹងក្រុមពិភាក្សានៅតំបន់ជាយទីក្រុង និងតំបន់ជនបទខេត្តកំពតផងដែរ។ គួរកត់សម្គាល់ថា គ្រូបង្រៀនភាគច្រើនបានកំណត់ថា សម្ភារៈរៀនសូត្រ គឺជាកត្តាសំខាន់មួយដែលរួមចំណែកបង្កឱ្យមានផលប៉ះពាល់ទៅលើលទ្ធភាពក្នុងការទទួលបានការអប់រំ។ គ្រូបង្រៀនចំនួន៤២នាក់បានឱ្យដឹងថាមានសម្ភារៈរៀនសូត្រ ដោយឡែកគ្រូបង្រៀនចំនួន១៥នាក់ផ្សេងទៀតបាននិយាយថា ពុំមានសម្ភារៈរៀនសូត្រឡើយ។

បើទោះជាដូច្នេះក្តី នៅពេលដែលសិស្សត្រូវបានសួរសំនួរថា ហេតុអ្វីបានជាកុមារមួយចំនួនបោះបង់ការសិក្សា ឬមិនធ្លាប់បានចូលរៀនពួកគេមិនដែលលើកឡើងឱ្យបានច្បាស់លាស់អំពីបញ្ហាកង្វះសម្ភារៈរៀនសូត្រឡើយ។ ចំណុចនេះផ្ទុយទៅនឹងទស្សនៈរបស់ឪពុកម្តាយ និងកុមារដែលបានបោះបង់ការសិក្សា។ កុមារចំនួន៨នាក់ក្នុងចំណោមកុមារចំនួន ៣៧នាក់ ត្រូវបានសម្ភាសន៍ ដែលបានបោះបង់ការសិក្សាមុនថ្នាក់ទី៩ បាននិយាយថា ការដែលគ្មានសម្ភារៈរៀនសូត្រ គឺជាមូលហេតុមួយ ហើយកង្វះសម្ភារៈរៀនសូត្រ គឺជាមូលហេតុដែលឪពុកម្តាយបានលើកឡើងញឹកញាប់ ក្នុងចំណោមបណ្តាមូលហេតុនានា ដែលបណ្តាលឱ្យកុមារបោះបង់ការសិក្សា។ ឪពុកម្តាយបាននិយាយថា កង្វះសម្ភារៈរៀនសូត្របានធ្វើឱ្យកុមារមានការលំបាកក្នុងការទៅរៀនឱ្យបានទៀងទាត់។

*៤.១.៣ ឯកសណ្ឋានសាលារៀន*

ឪពុកម្តាយមួយចំនួនតូចជាពិសេសនៅខេត្តរតនគិរីបានឱ្យដឹងថា ការតម្រូវឱ្យកុមារស្លៀកពាក់ឯកសណ្ឋានសាលារៀនធ្វើឱ្យកុមារមួយចំនួនពិបាកទៅរៀន ហើយនោះក៏ជាមូលហេតុមួយដែលធ្វើឱ្យកុមារមួយចំនួនបោះបង់ការសិក្សាផងដែរ។

កង្វះឯកសណ្ឋានសាលារៀនត្រូវបានលើកឡើងនៅក្នុងក្រុមពិភាក្សា ដែលមានសមាសភាពសិស្សចូលរួម ជាពិសេសនៅតំបន់ជនបទក្នុងខេត្តរតនគិរី ហើយកុមារមួយចំនួនមានបទពិសោធន៍ផ្ទាល់ខ្លួន អំពីការដែលពួកគេមានការលំបាកក្នុងការទៅសាលារៀនដោយសារតែបញ្ហានេះ។ យ៉ាងណាមិញសិស្សមិនបានកំណត់ថាកង្វះឯកសណ្ឋានសាលារៀន គឺជាមូលហេតុចម្បងមួយដែលធ្វើឱ្យកុមារមិនទៅរៀនបានទៀងទាត់ទេ ឬ បោះបង់ការសិក្សាឡើយ។ បន្ថែមពីនេះទៀតមានតែកុមារម្នាក់ប៉ុណ្ណោះ ដែលបានបោះបង់ការសិក្សាមុនថ្នាក់ទី៩បាននិយាយថាការដែលគ្មានឯកសណ្ឋានសាលារៀន គឺជាមូលហេតុមួយដែលធ្វើឱ្យគាត់ទៅរៀនមិនបានទៀងទាត់ និងបោះបង់ការសិក្សា។

*៤.១.៤. មធ្យោបាយធ្វើដំណើរ និងរយៈចម្ងាយទៅសាលារៀន*

យើងពិចារណាទៅលើកត្តាទាំងពីរនេះរួមគ្នាអាស្រ័យដោយកត្តាទាំងពីរនេះមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។ សិស្សដែលបានពិភាក្សាអំពីបទពិសោធន៍ដែលពួកគេបានជួបប្រទះ បានប្រាប់ឱ្យដឹងថា កង្វះមធ្យោបាយធ្វើដំណើរ គឺជាការលំបាកធំជាងគេដែលពួកគេជួបប្រទះក្នុងការទៅរៀនឱ្យបានទៀងទាត់ ហើយការដែលសាលារៀនស្ថិតនៅឆ្ងាយពេកក៏ត្រូវបានគូសបញ្ជាក់ញឹកញាប់ថាជាឧបសគ្គមួយដែលរាំងស្ទះដល់ការទៅរៀនផងដែរ។ ឪពុកម្តាយបានកំណត់រកឃើញថា កង្វះមធ្យោបាយធ្វើដំណើរ និងការដែលសាលារៀនស្ថិតនៅឆ្ងាយពេកគឺជាមូលហេតុចំនួនពីរក្នុងចំណោមបណ្តាមូលហេតុនានា ដែលគេបានលើកឡើងញឹកញាប់ជាងគេបំផុតថាបានធ្វើឱ្យកុមារមានការលំបាកក្នុងការទៅរៀន។ គ្រូបង្រៀនចំនួន ៣៩% បានប្រាប់ឱ្យដឹងថា មធ្យោបាយធ្វើដំណើរមានសារៈសំខាន់ចំពោះសិស្ស និងគ្រូបង្រៀនចំនួន១៨% បានរៀបរាប់ឱ្យដឹងថាសិស្សរបស់ពួកគេមួយចំនួនខ្វះមធ្យោបាយធ្វើដំណើរ។

អ្វីដែលមិនគួរឱ្យភ្ញាក់ផ្អើលនោះ គឺកត្តាទាំងពីរនេះត្រូវបានលើកឡើងញឹកញាប់ជាង នៅតំបន់ជនបទ។ ឪពុកម្តាយក្នុងខេត្តកំពតទំនងនឹងធ្វើការលើកឡើងជាក់លាក់អំពីកង្វះមធ្យោបាយធ្វើដំណើរថាជាបញ្ហាដោយ ឡែកឪពុកម្តាយនៅខេត្តរតនគិរីទំនងនឹងលើកឡើងអំពីរយៈចម្ងាយទៅសាលារៀនថាជាបញ្ហា។ សាលារៀនអនុវិទ្យាល័យមួយចំនួននៅខេត្តរតនគិរីបានបង្កើតអន្តេវាសិកដ្ឋាន ដែលផ្តល់អាហារពេលព្រឹក និងបាយជូនដល់កុមារដែលរស់នៅឆ្ងាយខ្លាំងពីសាលារៀន។ សិស្សនិងឪពុកម្តាយបានផ្តល់តម្លៃនៅពេលដែលមានការរៀបចំបែបនេះ។

រយៈចម្ងាយទៅសាលារៀន និងកង្វះមធ្យោបាយធ្វើដំណើរក៏ទំនងនឹងត្រូវបានលើកឡើងផងដែរ សំដៅចំពោះសាលារៀនអនុវិទ្យាល័យ ជាជាងសាលាបឋមសិក្សាអាស្រ័យដោយសាលារៀនអនុវិទ្យាល័យមួយចំនួនមានចម្ងាយជាង២០គីឡូម៉ែត្រ។ បើទោះបីជាវាមានភាពច្បាស់លាស់ថារយៈចម្ងាយទៅសាលារៀននិងកង្វះមធ្យោបាយធ្វើដំណើរ គឺជាបញ្ហាពិតប្រាកដសម្រាប់មនុស្សមួយចំនួនក៏ដោយ ប៉ុន្តែគួរកត់សម្គាល់ថា មនុស្សមួយចំនួនបានលើកឡើងថា ការដែលសាលារៀនស្ថិតនៅ ១,៥គីឡូម៉ែត្រពីផ្ទះរបស់ពួកគេគឺជារយៈចម្ងាយដែលឆ្ងាយខ្លាំងពេក និងការដែលសាលារៀនអនុវិទ្យាល័យពុំមានរថយន្តសម្រាប់ដឹកកុមារទៅសាលារៀនត្រូវបានចាត់ទុកថាជាកង្វះមធ្យោបាយធ្វើដំណើរ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺសិស្ស និងឪពុកម្តាយមិនឯកភាពអំពីការដែលរស់នៅឆ្ងាយពីសាលារៀន និងគ្មានមធ្យោបាយធ្វើដំណើរ គឺជាមូលហេតុដែលនាំឱ្យសិស្សបោះបង់ការសិក្សា។ សិស្សមិនសូវបានរៀបរាប់អំពីកត្តាទាំងនេះញឹកញាប់ដូចកត្តាដទៃទៀតឡើយ ប៉ុន្តែឪពុកម្តាយបានលើកឡើងអំពីមូលហេតុទាំងពីរនេះញឹកញាប់ជាងមូលហេតុដទៃទៀត។ កុមារដែលឈប់រៀនមុនថ្នាក់ទី៩ បានឯកភាពជាមួយឪពុកម្តាយរបស់ពួកគេថាកង្វះមធ្យោបាយធ្វើដំណើរនិងការដែលសាលារៀនស្ថិតនៅឆ្ងាយខ្លាំងពេក គឺជាកត្តាដ៏សំខាន់ដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សា។ កុមារចំនួន១២នាក់ (ក្នុងចំណោម ៣៧នាក់) បានប្រាប់ឱ្យដឹងថាការដែលសាលារៀនស្ថិតនៅឆ្ងាយខ្លាំងពេក គឺជាមូលហេតុមួយដែលធ្វើឱ្យពួកគេបោះបង់ការសិក្សា ជាពិសេសចំពោះកម្រិតអនុវិទ្យាល័យហើយកុមារចំនួន១១នាក់បានប្រាប់ឱ្យដឹងថាកង្វះមធ្យោបាយធ្វើដំណើរ គឺជាមូលហេតុមួយដែលធ្វើឱ្យពួកគេបោះបង់ការសិក្សា។

ក្រុមពិភាក្សាដែលមានសមាសភាពចូលរួមពីឪពុកម្តាយចំនួន៥ក្រុមបានប្រាប់ឱ្យដឹងថា កង្វះផ្លូវថ្នល់មិនល្អបានធ្វើឱ្យកុមារមួយចំនួនមានការលំបាកក្នុងការទៅរៀន ប៉ុន្តែកុមារមិនដែលបានលើកឡើងថាចំណុចនេះ គឺជាមូលហេតុដែលធ្វើឱ្យពួកគេបោះបង់ការសិក្សាឡើយ។ ឪពុកម្តាយនៅខេត្តសៀមរាប និងខេត្តកំពតបានសម្តែងអំពីការព្រួយបារម្ភរបស់ពួកគេអំពីគ្រោះថ្នាក់ដែលអាចកើតមានចំពោះកូនរបស់ពួកគេ អាស្រ័យដោយសាលារៀនមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវដែលមានចរាចរណ៍ច្រើន។ ឪពុកម្តាយបានផ្តល់មតិយោបល់ថាគួរមានឆ្មាំមួយនាក់ដើម្បីធ្វើចរាចរណ៍និងជួយសិស្សឆ្លងថ្នល់។ សិស្សក្នុងខេត្តរតនគិរីបាននិយាយអំពីការលំបាកផ្ទាល់ខ្លួនរបស់ពួកគេក្នុងការប្រើប្រាស់ផ្លូវថ្នល់នៅរដូវវស្សា។ បើទោះជាដូច្នេះក្តី ក៏ដូចគ្នាទៅនឹងក្រុមឪពុកម្តាយដែរ ពុំមានក្រុមសិស្សណាមួយបានប្រាប់ឱ្យដឹងថា ផ្លូវថ្នល់មិនល្អគឺជាមូលហេតុដែលធ្វើឱ្យសិស្សបោះបង់ការសិក្សានោះឡើយ។

### ៤.១.៥. គ្រូបង្រៀនគុណភាព និងឥរិយាបថ ៖ បរិមាណ

សិស្សបានលើកឡើងអំពីភាពគ្រប់គ្រាន់នៃគ្រូបង្រៀន គុណភាព និងឥរិយាបថរបស់គ្រូបង្រៀនទាក់ទងទៅនឹងការបង់ថ្លៃសាលារៀនក្រៅផ្លូវការ និងការចុះវត្តមាន គឺជាកត្តាសំខាន់ដែលអាចប៉ះពាល់ដល់ការទៅរៀនរបស់កុមារ។ បើទោះជាដូច្នេះក្តីមានតែសិស្សមួយចំនួនតូចប៉ុណ្ណោះ ដែលបានលើកឡើងអំពីចំណុចណាមួយក្នុងចំណោមចំណុចទាំងនេះថាជាមូលហេតុសំខាន់ដែលរារាំងសិស្សមិនឱ្យទៅរៀនបានទៀងទាត់។

សិស្សចំនួនពីក្រុមបានរៀបរាប់ឱ្យដឹងថា កង្វះគ្រូបង្រៀន និងការដែលគ្រូមិនគោរពបទបញ្ជាធ្វើឱ្យកុមារមួយចំនួនមិនអាចចុះឈ្មោះចូលរៀនបាន។ មានតែសិស្សមួយក្រុមប៉ុណ្ណោះ ដែលបានប្រាប់ឱ្យដឹងថាការដែលគ្រូបង្រៀនប្រមូលប្រាក់នៅពេលបង្រៀន គឺជាមូលហេតុដែលធ្វើឱ្យកុមារមិនទៅរៀន។ ការដែលគ្រូបង្រៀន ប្រើប្រាស់អំពើហិង្សា (នៅក្នុងករណីនេះសំដៅ ចំពោះការប្រើប្រាស់អំពើហិង្សាទៅលើសិស្សដែលរៀនយឺត) ត្រូវបានលើកឡើងចំនួនមួយដងទាក់ទងទៅនឹងមូលហេតុដែលធ្វើឱ្យកុមារមួយចំនួនមិនទៅរៀន។

សិស្សបានប្រាប់ឱ្យដឹងថាសិស្សដែលទៅរៀនយឺតរមែងតែងជ្រើសរើសមិនចូលរៀន ដោយសារតែពួកគេខ្លាចទទួលទណ្ឌកម្ម ដូចជាការដែលគ្រូឱ្យពួកគេឈរជើងមួយ ដងទឹក ឬរត់ជុំវិញអាគារសាលារៀន។ ជាក់ស្តែងសិស្សមករៀនយឺតដែលជ្រើសរើសមិនចូលរៀនគឺជាមូលហេតុដែលកុមារបានលើកឡើងញឹកញាប់បំផុតលំដាប់ទី៣ដែលធ្វើឱ្យកុមារចូលរៀនមិនបានទៀងទាត់។

ទស្សនៈរបស់ឪពុកម្តាយទាក់ទងទៅនឹងគ្រូបង្រៀនមានភាពខុសគ្នាពីសិស្ស។ ជាទូទៅឪពុកម្តាយតែងរអ៊ូរទាំអំពីការដែលគ្មានគ្រូបង្រៀនគ្រប់គ្រាន់ បើទោះបីជាពួកគេមិនបាននិយាយថា វាគឺជាកត្តាមួយដែលធ្វើឱ្យកុមារបោះបង់ការសិក្សាក៏ដោយ។ បើទោះជាដូច្នេះក្តីក្រុមពិភាក្សាដែលមានសមាសភាពចូលរួមពីឪពុកម្តាយចំនួន៣ក្រុមក្នុងខេត្តរតនគិរីបាននិយាយថា ការដែលគ្រូអវត្តមាន គឺជាមូលហេតុមួយដែលធ្វើឱ្យកុមារបោះបង់ការសិក្សា។ ឪពុកម្តាយក្នុងស្រុកបន្ទាយស្រី(ខេត្តសៀមរាប)បានរអ៊ូរទាំអំពីការដែលគ្រូបង្រៀនមិនបានល្អគ្រប់គ្រាន់ ហើយឪពុកម្តាយមួយចំនួននៅក្រុងសៀមរាបបានរអ៊ូរទាំថាការដែលគ្រូអនុវិទ្យាល័យប្រមូលប្រាក់ធ្វើឱ្យកុមារកាន់តែមានការលំបាកក្នុងការទៅរៀន។

ក្រុមពិភាក្សាមួយក្រុមបានប្រាប់ឱ្យដឹងថាការលំបាកធំបំផុតគឺការដែលគ្រូបង្រៀនទាមទារប្រាក់ចំនួន ២០០រៀលក្នុងមួយថ្ងៃពីសិស្ស និងការដែលសិស្សត្រូវបង់ប្រាក់ចំនួន១.០០០រៀលនៅចុងខែ។ លើសពីនេះទៀត ប្រសិនបើសិស្សឈប់រៀននៅពាក់កណ្តាលឆ្នាំសិក្សា ហើយមានបំណងចង់ចូលរៀនវិញសាលារៀនទាមទារឱ្យបង់ប្រាក់ចន្លោះពី៦០.០០០រៀលទៅ៨០.០០០រៀល។ យ៉ាងណាមិញមានតែក្រុមឪពុកម្តាយមួយក្រុមប៉ុណ្ណោះ បានប្រាប់ឱ្យដឹងថាការដែលគ្រូទាមទារឱ្យបង់ប្រាក់ គឺជាមូលហេតុដែលធ្វើឱ្យកុមារបោះបង់ការសិក្សា។ តាមរយៈក្រុមពិភាក្សាបានបង្ហាញឱ្យឃើញថា សិស្សឬឪពុកម្តាយមិនបានគិតថា គុណភាព បរិមាណ ឬឥរិយាបថរបស់គ្រូបង្រៀន គឺជាមូលហេតុចម្បងដែលធ្វើឱ្យកុមារ មិនទៅរៀនឡើយ។

វាពុំមានអ្វីគួរឱ្យភ្ញាក់ផ្អើលឡើយ ដែលគ្រូបង្រៀនមានទស្សនៈខុសពីក្រុមឪពុកម្តាយ និងសិស្ស ទាក់ទងទៅ នឹងក្រមសីលធម៌ និងការអនុវត្តន៍ការងាររបស់ពួកគេ។ គ្រូបង្រៀនភាគច្រើនបាននិយាយថា មានគ្រូបង្រៀន គ្រប់គ្រាន់ ហើយក្នុងចំណោមនោះគ្រូបង្រៀនជាច្រើនមានក្រមសីលធម៌ល្អមកបង្រៀន ទៀងទាត់ និងមាន សមត្ថភាព។

### *៤.១.៦. ទឹកស្អាត នឹងបង្គន់អនាម័យ បរិស្ថាន នឹងអគារសាលារៀន*

ជាញឹកញាប់ឪពុកម្តាយបានលើកឡើងអំពីបញ្ហាទឹកស្អាតនិងបង្គន់អនាម័យថាជាកត្តាសំខាន់ដែល ធ្វើឱ្យកុមារមានភាពងាយស្រួលក្នុងការទៅរៀន ហើយឪពុកម្តាយភាគច្រើនមានការពេញចិត្តចំពោះសាលា រៀនក្នុងមូលដ្ឋានរបស់ពួកគេដែលមានទឹកស្អាតនិងបង្គន់អនាម័យ។ មានតែនៅខេត្តរតនគិរីប៉ុណ្ណោះ ដែល ឪពុកម្តាយបានរាយការណ៍ឱ្យដឹងថាគ្មានទឹកស្អាត។ ពុំមានក្រុមពិភាក្សាណាមួយដែលមានសមាសភាពចូល រួមពីឪពុកម្តាយ ឬសិស្សបានលើកឡើងថាកង្វះទឹកស្អាត ឬបង្គន់អនាម័យ គឺជាកត្តាសំខាន់ដែលធ្វើឱ្យសិស្ស អវត្តមានជាទៀងទាត់ ឬ ធ្វើឱ្យកុមារបោះបង់ការសិក្សាឡើយ។

បរិស្ថានសាលារៀនក៏ត្រូវបានលើកយកមកពិភាក្សាជាមួយសិស្សផងដែរ ដោយពួកគេបានរៀបរាប់ អំពីការ ចង់បានកន្លែងក្មេងលេង និងកន្លែងលេងកីឡាមួយដ៏ល្អ ហើយសិស្សមួយចំនួនទៀតក៏ចង់បាន សួនច្បារនិង ដើមឈើដែលផ្តល់ម្លប់ផងដែរ។

### *៤.១.៧. ឥរិយាបថរបស់សិស្ស*

ឪពុកម្តាយ និងសិស្សបានគូសបញ្ជាក់អំពីឥរិយាបថរបស់សិស្សនៅពេលដែលពិភាក្សាអំពីមូលហេតុ ដែលកុមារមិនទៅរៀន។ សម្រាប់សិស្សកុមារដែលខ្ជិល ឬរៀនមិនចេះ គឺជាមូលហេតុទូទៅបំផុតទីពីរដែល ធ្វើឱ្យកុមារមិនទៅរៀន។ បើទោះបីជានៅពេលដែលប្រៀបធៀបបញ្ចូលគ្នានូវបញ្ហារយៈចម្ងាយទៅសាលារៀន និងកង្វះមធ្យោបាយធ្វើដំណើរក៏ដោយ សិស្សនៅតែជឿថាកង្វះការលើកទឹកចិត្ត និងលទ្ធភាពរបស់កុមារ គឺ ជាមូលហេតុធំជាងដែលធ្វើឱ្យកុមារនៅក្រៅសាលារៀន។

គ្រូបង្រៀននៅខេត្តរតនគិរី បានប្រាប់ឱ្យដឹងថាកុមារដែល "រៀនយឺត" ក៏មិនសូវទំនងថានឹងទៅរៀន ផងដែរ អាស្រ័យដោយពួកគេភាគច្រើនបោះបង់ការសិក្សានៅពេលដែលពួកគេមានអាយុចន្លោះពី ១៣ឆ្នាំ ទៅ ១៥ឆ្នាំ។

ឪពុកម្តាយបានដកស្រង់កត្តាដូចគ្នាទាំងនេះថា ជាមូលហេតុដែលធ្វើឱ្យកុមារនៅក្រៅសាលារៀន ហើយពួកគេមានអារម្មណ៍ថានេះគឺជាមូលហេតុទូទៅមួយដែលធ្វើឱ្យកុមារនៅក្រៅសាលារៀន និងពុំសូវទាក់ ទងទៅ នឹងឥរិយាបថរបស់ឪពុកម្តាយឡើយ។ បើទោះជាដូច្នេះក្តី សិស្សមិនសូវបានលើកឡើងទូទៅអំពី បញ្ហាឥរិយាបថរបស់សិស្សឡើយ។ ឪពុកម្តាយទំនងនឹងពិភាក្សាអំពីបញ្ហារយៈចម្ងាយទៅសាលារៀន កង្វះ មធ្យោបាយធ្វើដំណើរកង្វះថវិកា និងសម្ភារៈ។

### *៤.១.៨. ឥរិយាបថរបស់ឪពុកម្ដាយ*

កុមារចំនួន ៣០នាក់ ក្នុងចំណោមកុមារចំនួន៣៧នាក់ដែលបានបោះបង់ការសិក្សាមុនថ្នាក់ទី៩ បាននិយាយថា វាគឺជាការសម្រេចចិត្តរបស់ពួកគេក្នុងការបោះបង់ការសិក្សានិងមានតែកុមារចំនួន៧នាក់ប៉ុណ្ណោះដែលបាននិយាយថា ឪពុកម្ដាយរបស់ពួកគេគឺជាអ្នកសម្រេចចិត្តបែបនេះ។ កុមារមួយចំនួនថែមទាំងបាននិយាយថា ពួកគេបានសម្រេចចិត្តឈប់រៀន បើទោះបីជាឪពុកម្ដាយរបស់ពួកគេអនុញ្ញាត/មានបំណងឱ្យពួកគេទៅរៀនក៏ដោយ។ ការស្រាវជ្រាវនាពេលថ្មីៗនេះទៅលើក្រុមជនជាតិដើមភាគតិចក្នុងខេត្តរតនគិរីក៏បានរកឃើញករណីបែបនេះនៅក្នុងចំណោមក្រុមកុមារជនជាតិដើមភាគតិចផងដែរ ក្នុងនោះកុមារមួយចំនួនបាននិយាយថាឪពុកម្ដាយរបស់ពួកគេបានបង្ខំឱ្យពួកគេទៅរៀន[34]។

ឪពុកម្ដាយកម្ររៀបរាប់អំពីសារៈសំខាន់នៃឥរិយាបថរបស់ពួកគេខ្លាំងណាស់ដែលនេះ គឺជាចំណុចមួយគួរឱ្យព្រួយបារម្ភ ដោយឡែកក្រុមឪពុកម្ដាយចំនួន៣ក្រុមក្នុងចំណោម៤ក្រុម ក្នុងស្រុកបន្ទាយស្រីបានប្រាប់ឱ្យដឹងថា ឥរិយាបថរបស់ឪពុកម្ដាយបានធ្វើឱ្យកុមារស្ថិតនៅក្រៅសាលារៀន។ ក្រុមសិស្សចំនួនពាក់កណ្ដាលនៃចំនួនក្រុមសិស្សទាំងអស់ក្នុងខេត្តកំពតបានប្រាប់ឱ្យដឹងថាការលើកទឹកចិត្តពីឪពុកម្ដាយ គឺជាកត្តាមួយដ៏សំខាន់ដែលជះឥទ្ធិពលដល់វត្តមានរបស់សិស្សនៅឯសាលារៀន។ បើទោះបីជាពុំមានសិស្សណាម្នាក់និយាយថា កង្វះការលើកទឹកចិត្តពីឪពុកម្ដាយ គឺជាមូលហេតុមួយដែលធ្វើឱ្យសិស្សបោះបង់ការសិក្សា ក៏ដោយ ប៉ុន្តែបូករួមជាមួយនឹងការធ្វើការងារនៅឯផ្ទះ ឬ ការងារក្រៅផ្ទះ ឥរិយាបថរបស់ឪពុកម្ដាយ គឺជាមូលហេតុមួយដែលត្រូវបានលើកឡើងញឹកញាប់បំផុត ថាជាកត្តាដែលរារាំងកុមារមិនឱ្យទៅរៀនបានទៀង ទាត់។ ជាមួយនឹងការលើកទឹកចិត្តពីឪពុកម្ដាយ សិស្សក៏បានប្រាប់ឱ្យដឹងផងដែរថា អំពើហិង្សារបស់ឪពុកម្ដាយទៅលើពួកគេ គឺជាមូលហេតុមួយដែលធ្វើឱ្យកុមារមិនទៅរៀន។ នៅក្នុងក្រុមចំនួន២ សិស្សបាននិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេទាក់ទងនឹងបញ្ហានេះ។ សិស្សបានពន្យល់ឱ្យដឹងថា ចំណុចនេះអាចបំផ្លិចបំផ្លាញទំនុកចិត្ត និងការជឿជាក់លើខ្លួនឯងរបស់កុមារដែលធ្វើឱ្យពួកគេមានភាពស្ទាក់ស្ទើរក្នុងការទៅសាលារៀន។ ក្រុមពិភាក្សារបស់ឪពុកម្ដាយមួយក្រុមក៏បានពិចារណាផងដែរថា អំពើហិង្សារបស់ឪពុកម្ដាយទៅលើកូនបណ្ដាលឱ្យកូនបោះបង់ការសិក្សា។ គេបានពន្យល់ថាសិស្សនឹងមានអារម្មណ៍ខ្មាស់អៀននៅពេលដែលពួកគេទៅរៀនជាមួយនឹងស្នាមវាយដំលើរាងកាយរបស់ពួកគេ។

គ្រូបង្រៀនមួយចំនួនតូច (១៤នាក់)គិតថា ឪពុកម្ដាយដើរតួនាទីមួយដ៏សំខាន់នៅក្នុងការអប់រំកូនរបស់ពួកគេក្នុងនោះគ្រូបង្រៀន១១នាក់បាននិយាយថា ឪពុកម្ដាយពិតជាបានយកចិត្តទុកដាក់ចំពោះការអប់រំកូនរបស់ពួកគេ។

[34]Strickler, C (2012). *របាយការណ៍ស្ដីពីការវិភាគយេនឌ័រ និងអំណាច។* អង្គការយៃរអន្តរជាតិ ៖ មិនត្រូវបានបោះពុម្ពផ្សាយ។

*៤.១.៩. ធ្វើការនៅឯផ្ទះ ឬ ធ្វើការដើម្បីរកប្រាក់*

ឥទ្ធិពលរបស់ឪពុកម្ដាយក៏បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ផងដែរតាមរយៈចំនួនឪពុកម្ដាយ និង សិស្សដែលបានប្រាប់ឱ្យដឹងថា កុមារមិនទៅរៀនដោយសារតែមូលហេតុដែលតម្រូវឱ្យមានការបង្កប់អត្ថន័យ ផ្ដល់ការអនុញ្ញាត ឬ ការអនុញ្ញាតដោយផ្ទាល់ពីឪពុកម្ដាយ ៖

- ពួកគេត្រូវមើលប្អូន ឬ ថែទាំឪពុកម្ដាយ
- ពួកគេត្រូវធ្វើការជាមួយឪពុកម្ដាយរបស់ពួកគេ(រាប់បញ្ចូលទាំងការធ្វើចំណាកស្រុកជាមួយឪពុកម្ដាយផងដែរ)
- ពួកគេមានការងារធ្វើ។

សម្រាប់សិស្សការដែលត្រូវមើលប្អូនធ្វើការជាមួយឪពុកម្ដាយឬមានការងារធ្វើ គឺជាមូលហេតុដែលត្រូវបានលើកឡើងញឹកញាប់បំផុត ថាធ្វើឱ្យសិស្សស្ថិតនៅក្រៅសាលារៀន។ ជាទូទៅ សិស្សតែងប្រាប់ឱ្យដឹងថា កុមារមួយចំនួនត្រូវធ្វើការជា "គូលី" (កូនឈ្នួល) ឬជួយក្នុងសកម្មភាពធ្វើស្រែចម្ការ។ កត្តាទាំងនេះក៏ជាមូលហេតុដែលត្រូវបានលើកឡើងញឹកញាប់បំផុតផងដែរថា បានរារាំងសិស្សមិនឱ្យទៅរៀនបានទៀងទាត់។ សិស្សចំនួនពីរក្រុមនៅខេត្តរតនគិរី ក៏បាននិយាយផងដែរថា នៅរដូវវស្សាឪពុកម្ដាយដកកូនរបស់ពួកគេឱ្យទៅធ្វើការនៅឯស្រែ។ សិស្សមួយក្រុមបាននិយាយថា វត្តមាននៅឯសាលារៀនបានធ្លាក់ចុះពី ៧០% នៅរដូវប្រាំងមក ៥០% នៅរដូវវស្សា។

សម្រាប់កុមារដែលបានបោះបង់ការសិក្សាមុនថ្នាក់ទី៩ ការជួយធ្វើការងារនៅឯផ្ទះ គឺជាមូលហេតុដែលត្រូវបានលើកឡើងញឹកញាប់បំផុត ក្នុងលំដាប់លេខរៀងទី២ ដែលបានធ្វើឱ្យពួកគេបោះបង់ការសិក្សា ក្នុងនោះមានកុមារចំនួន១៥នាក់ ក្នុងចំណោម៣៧នាក់ បានលើកឡើងអំពីចំណុចនេះ។ កុមារចំនួន៧នាក់ ក្នុងចំណោមកុមារ១៥នាក់ទាំងនោះបាននិយាយថា ដោយសារតែឪពុកម្ដាយរបស់ពួកគេឈឺទើបពួកគេត្រូវជួយធ្វើការងារនៅឯផ្ទះជាជាងទៅសាលារៀន។ ដូចគ្នាទៅនឹងអ្វីដែលបានរំពឹងទុកផងដែរកុមារដែលបានបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យបានលើកឡើងអំពីមូលហេតុនេះច្រើនជាង កុមារដែលបានបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា។

កុមារចំនួន១០នាក់ ក៏បានប្រាប់ឱ្យដឹងផងដែរថាពួកគេបោះបង់ការសិក្សា អាស្រ័យដោយពួកគេបានចាប់ផ្ដើមធ្វើការងារក្នុងនោះកុមារចំនួន៦នាក់ធ្វើការងារជាមួយគ្រួសាររបស់ពួកគេ និងកុមារ ៤នាក់ទៀតបានស្វែងរកការងារធ្វើ។ បើទោះបីជាពួកគេបោះបង់ការសិក្សាមុនថ្នាក់ទី៩ ក៏ដោយកុមារជាច្រើនបានឈានដល់អាយុធ្វើការងាររួចទៅហើយ។ កុមារដែលយើងបានសម្ភាសន៍ ចំនួន១២នាក់ ក្នុងចំណោមកុមារ១៨នាក់ ដែលបានបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យមានអាយុចន្លោះពី ១៦ឆ្នាំ ទៅ១៩ឆ្នាំនៅពេលដែលពួកគេបោះបង់ការសិក្សា។ ពុំមានកុមារណាម្នាក់ដែលបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា មានអាយុលើស ១៦ឆ្នាំនៅពេលដែលពួកគេបោះបង់ការសិក្សាឡើយ ប៉ុន្តែកុមារជិតពាក់កណ្ដាលក្នុងចំណោមកុមារទាំងនោះមានអាយុចន្លោះពី ១៤ ឆ្នាំ ទៅ ១៦ឆ្នាំ ដែលស្ថិតក្នុងអាយុនេះ គឺជាពេលដែលពួកគេចាប់ផ្ដើមមានលទ្ធភាពកាន់តែច្រើនក្នុងការជួយ/រកប្រាក់ចំណូល។

ក្នុងចំណោមកុមារចំនួន២២នាក់ ដែលត្រូវបានសម្ភាសន៍ និងដែលបានបោះបង់ការសិក្សាក្នុងកម្រិតបឋមសិក្សាមានតែកុមារមួយនាក់ប៉ុណ្ណោះ បានចាប់ផ្តើមចូលរៀននៅអាយុ៦ឆ្នាំ។ កុមារចំនួនពាក់កណ្តាលដែលបានបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យ បានចូលរៀននៅអាយុលើស៦ឆ្នាំ។ ចំណុចនេះបង្ហាញឱ្យឃើញថា ការចាប់ផ្តើមចូលរៀនយឺតក្រោយអាយុ៦ឆ្នាំកាត់បន្ថយចំនួនថ្នាក់ដែលកុមារអាចបញ្ចប់ដែលជាថ្មីម្តងទៀតចំណុចនេះគូសបញ្ជាក់អំពីឥទ្ធិពលនៃឥរិយាបថរបស់ឪពុកម្តាយ។ ការស្រាវជ្រាវដទៃទៀតនៅតាមសាលារៀនជនបទក្នុងប្រទេសកម្ពុជាបានរកឃើញថា ការចូលរៀនយឺតមានទំនាក់ទំនងវិជ្ជមានទៅនឹងនិន្នាការនៃការបោះបង់ការសិក្សាក្នុងថ្នាក់ទី៥។ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា[35] ៖

***"រាល់គោលនយោបាយទាំងឡាយណាដែលត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាក្នុងតំបន់ជនបទប្រទេសកម្ពុជា គប្បីទាក់ទាញកុមារដែលគ្រប់អាយុចូលរៀន ឱ្យចូលរៀនបានឆាប់បំផុតដូចដែលអាចធ្វើទៅបានជាមុនសិន"។***

ឪពុកម្តាយបានឯកភាពថា ការមើលប្អូន ឬ ការធ្វើការងារជាមួយឪពុកម្តាយ គឺជាមូលហេតុញឹកញាប់បំផុតដែលធ្វើឱ្យកុមារមិនអាចទៅរៀនបានទៀងទាត់។ បើទោះជាដូច្នេះក្តីឪពុកម្តាយមិនសូវទំនងនឹងនិយាយថាមូលហេតុទាំងនេះ គឺជាកត្តាដែលធ្វើឱ្យកុមារបោះបង់ការសិក្សាឡើយ។ កត្តាដទៃទៀតដូចជារយៈចម្ងាយទៅសាលារៀននិងមធ្យោបាយធ្វើដំណើរកង្វះថវិកា និងសម្ភារៈរៀនសូត្រត្រូវបានលើកឡើងញឹកញាប់ជាង។ គួរកត់សម្គាល់ថា ការធ្វើចំណាកស្រុកដែលជាកត្តាជាក់លាក់មួយមិនត្រូវបានលើកឡើង នៅក្នុងស្រុកណាមួយឡើយក្រៅពីស្រុកបន្ទាយស្រី (ខេត្តសៀមរាប)។

### *៤.១.១០. ភាពក្រីក្រ*

ឪពុកម្តាយ និងសិស្សបានធ្វើការបែងចែករវាងភាពក្រីក្រ និងការដែលគ្មានប្រាក់សម្រាប់ចំណាយនៅឯសាលារៀន។ ចំណុចទាំងពីរនេះត្រូវបានសិស្សលើកឡើងជាទូទៅ ថាជាកត្តាដែលធ្វើឱ្យពួកគេមានការលំបាកក្នុងការទៅរៀនឱ្យបានទៀងទាត់ ក្នុងនោះមានសិស្សជាច្រើនបាននិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ យ៉ាងណាមិញសិស្សបាននិយាយតែពីរដងប៉ុណ្ណោះថា កង្វះថវិកាសម្រាប់ចំណាយនៅឯសាលារៀន គឺជាមូលហេតុមួយដែលធ្វើឱ្យកុមារនៅក្រៅសាលារៀន ហើយពួកគេមិនដែលបន្ទោសទៅលើភាពក្រីក្រជាទូទៅឡើយ។ ឪពុកម្តាយបានលើកឡើងអំពីកត្តាទាំងនេះជាញឹកញាប់ ហើយប្រសិនបើគេធ្វើការប្រៀបធៀបបញ្ចូលគ្នាវាបានបង្ហាញឱ្យឃើញថាកត្តានេះ គឺជាមូលហេតុទូទៅបំផុតលំដាប់លេខរៀងទី៣ ដែលធ្វើឱ្យកុមារស្ថិតនៅក្រៅសាលារៀន។

ស្ទើរតែពាក់កណ្តាលនៃកុមារ (១៨នាក់ ក្នុងចំណោម៣៧នាក់) ដែលបានបោះបង់ការសិក្សាមុនថ្នាក់ទី៩ បាននិយាយថា មូលហេតុដែលធ្វើឱ្យពួកគេបោះបង់ការសិក្សាបែបនេះ គឺបណ្តាលមកពីភាពក្រីក្រ។ នេះគឺ

[35]No, Sam & Kirakawa (2012), *ការពិនិត្យឡើងវិញទៅលើការបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា ក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា។* ទីក្រុងសេអ៊ូល ៖ ការត្រួតពិនិត្យឡើងវិញទៅលើវិស័យអប់រំនៅតំបន់អាស៊ីប៉ាស៊ីហ្វិក Vol. 13។

ជាមូលហេតុដែលពួកគេបានលើកឡើងជាទូទៅបំផុត។ អាស្រ័យដោយកុមារចំនួន ១០នាក់ ដែលបាន បោះបង់ការសិក្សាបានលើកឡើងថា ពួកគេបានបោះបង់ការសិក្សាដោយសារតែមូលហេតុត្រូវធ្វើការងារ ដូច្នេះ វាបានបង្ហាញឱ្យឃើញថាសម្រាប់គ្រួសារមួយចំនួនតម្លៃកាលានុវត្តភាពនៃការទៅសាលារៀនមានកម្រិតខ្ពស់ពេកដោយសារតែតម្រូវការឱ្យមានប្រាក់ចំណូលបន្ថែមពីការងារ។

**ប្រអប់ទី១ ៖ ក្រខ្លាំងពេកដែលធ្វើឱ្យគ្មានលទ្ធភាពទៅសាលារៀន**

| |
|---|
| កុមារីម្នាក់ អាយុ១៧ឆ្នាំ រស់នៅក្រុងសៀមរាប ខេត្តសៀមរាប បានបោះបង់ការសិក្សានៅពេលដែលនាងអាយុ ១៣ឆ្នាំ ដោយសារតែនាងរៀនខ្សោយរួមផ្សំនឹងកត្តាក្រីក្រ។ នាងរស់នៅជាមួយម្តាយរបស់នាងជាស្ត្រីមេម៉ាយ ដែលព្យាយាមចិញ្ចឹម និងផ្តល់ការអប់រំដល់កូន៤នាក់។ នៅពេលដែលកុមារីរូបនេះរៀនថ្នាក់ ទី៤ នៅសាលាបឋមសិក្សាគោកតាចាន់ នាងពុំមានប្រាក់ទៅសាលារៀនឡើយ អាស្រ័យដោយម្តាយរបស់នាង ពុំមានប្រាក់ចំណូលពីប្រភពណាមួយឡើយ។ គ្រូបង្រៀនរបស់នាងបានប្រមូលប្រាក់ចំនួន២០០រៀល ក្នុងមួយថ្ងៃពីសិស្សដោយគ្មានការលើកលែង។ ប្រសិនបើកុមារីរូបនេះមិនបង់ប្រាក់ឱ្យគ្រូទេនោះ ចំនួនទឹកប្រាក់នោះនឹងត្រូវកើនឡើងនៅថ្ងៃបន្ទាប់។ បន្ថែមពីនេះទៀត គ្រូរបស់នាងតែងសរសេរមេរៀននៅលើក្តារខៀន ដោយផ្តល់ការពន្យល់តិចតួច ឬគ្មានផ្តល់ការពន្យល់ទាល់តែសោះ និងទុកឱ្យសិស្សចម្លងមេរៀនទាំងនោះ។ នាងមិនអាចអាន និងសរសេរបានល្អឡើយរហូតដល់នាងរៀនថ្នាក់ទី៦ដែលនៅពេលនោះគ្រូរបស់នាងបានខិតខំប្រឹងប្រែងកែលម្អការអាន និងការសរសេររបស់នាង។ នៅពេលដែលនាងរៀនចប់ថ្នាក់ទី៦នាងបានសម្រេចចិត្តបោះបង់ការសិក្សា អាស្រ័យដោយនាងដឹងថា ការរៀននៅសាលាអនុវិទ្យាល័យត្រូវចំណាយប្រាក់កាន់តែច្រើនជាងនៅសាលាបឋមសិក្សា។ |

នៅពេលដែលគ្រួសារកំពុងគណនាថ្លៃចំណាយសម្រាប់កូនទៅសាលារៀនការមានប្រាក់សម្រាប់ចំណាយនៅឯសាលារៀន ក៏សំខាន់ផងដែរ។ ឧបមាថាសេវាសាលារៀនត្រូវបានផ្តល់ជូនតាមច្បាប់ដោយឥតគិតថ្លៃយើងបានសួរថា តើកុមារត្រូវការប្រាក់ធ្វើអ្វីនៅពេលដែលពួកគេទៅរៀន។ យើងបានប្រមូលផ្តុំចម្លើយរបស់ពួកគេជា៤ក្រុម ៖

- តម្រូវការចាំបាច់របស់សិស្ស ៖ ឧ. ឯកសណ្ឋានសាលារៀន សម្ភារៈរៀនសូត្រ
- តម្រូវការបន្ទាប់បន្សំរបស់សិស្ស ៖ ឧ. អាហារនៅឯសាលារៀន
- តម្រូវការជាសក្តានុពលរបស់សិស្ស ៖ ឧ.មធ្យោបាយធ្វើដំណើរកន្លែងស្នាក់នៅក្បែរសាលារៀន
- ថ្លៃចំណាយមិនសមស្របទៅលើសិស្ស ៖ ឧ. គ្រូបង្រៀនតម្រូវឱ្យបង់ប្រាក់។

នៅពេលដែលគេធ្វើការវិភាគទៅលើកត្តាខាងលើទាំងអស់នេះ វាបានបង្ហាញឱ្យឃើញថាការស្វែងរកថវិកាសម្រាប់សម្ភារៈរៀនសូត្រ និងមធ្យោបាយធ្វើដំណើរ គឺជាបញ្ហាប្រឈមធំបំផុតចំនួនពីរដែលឪពុកម្តាយ/កុមារជួបប្រទះ និងជាកត្តាដែលធ្វើឱ្យកុមារស្ថិតនៅក្រៅសាលារៀន។

បើទោះបីជាល័ក្ខខ័ណ្ឌនៃភាពក្រីក្រកំពុងបង្កើតឱ្យមានផលប៉ះពាល់ដែលបណ្តាលឱ្យកុមារស្ថិតនៅក្រៅសាលារៀនក៏ដោយ ប៉ុន្តែដំណោះស្រាយចំពោះបញ្ហានេះមិនស្ថិតនៅក្នុងការគ្រប់គ្រងវិស័យអប់រំនោះទេ។ វាមានការលំបាកខ្លាំងណាស់សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការផ្លាស់ប្តូរល័ក្ខខ័ណ្ឌរបស់គ្រួសារដើម្បីឱ្យពួកគេឈប់តម្រូវឱ្យកូនរបស់ពួកគេជួយធ្វើការងារនៅឯផ្ទះ ឬធ្វើការងារដើម្បីរកប្រាក់។ ចំណុចនេះបង្ហាញថា ក្រសួងអប់រំ យុវជន និងកីឡា គួរផ្តោតយកចិត្តទុកដាក់លើការកាត់បន្ថយថ្លៃចំណាយនៃការទៅសាលារៀន។

វិធីសាស្រ្តមួយនៃការធ្វើយ៉ាងដូច្នេះ គឺជាការផ្តល់អាហារូបករណ៍ដែលឪពុកម្តាយ/សិស្សអាចប្រើប្រាស់ដើម្បីទិញកង់ឬសម្ភារៈរៀនសូត្រនិងដូចមានពិភាក្សានៅក្នុងផ្នែកទី៣ កម្មវិធីបច្ចុប្បន្នមានទំនាក់ទំនងទៅនឹងអត្រាបោះបង់ការសិក្សាដែលមានកម្រិតទាបជាងមុន នៅសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា។ក្នុងខេត្តរតនគិរីឪពុកម្តាយនៅក្នុងក្រុមពិភាក្សាចំនួន៦ក្រុមបានប្រាប់ឱ្យដឹងថា អាហារូបករណ៍ (ការផ្តល់អាហារនៅឯសាលារៀន ឬការផ្តល់ជាសាច់ប្រាក់) គឺជាកត្តាដ៏សំខាន់ដែលអាចជួយឱ្យកុមារ មានលទ្ធភាពក្នុងការទៅសាលារៀនបាន។ ឪពុកម្តាយមួយចំនួនបាននិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួន របស់ពួកគេ អំពីការទទួលបានអាហារូបករណ៍។

### *៤.១.១១. កុមារពិការ*

ក្រុមពិភាក្សានៅគ្រប់ឃុំទាំងអស់ដែលបានចុះធ្វើទស្សនកិច្ចក្នុងខេត្តកំពត និងខេត្តសៀមរាបបានប្រាប់ឱ្យដឹងថាមានកុមារពិការនៅក្នុងឃុំរបស់ពួកគេ ហើយកុមារពិការភាគច្រើនមិនបានទៅសាលារៀនឡើយ។ ជាក់ស្តែងឪពុកម្តាយដែលបានចូលរួមនៅឯសិក្ខាសាលាពិគ្រោះយោបល់របស់យើងបានប្រាប់ឱ្យដឹងថាសាលារៀនមួយចំនួនបានបដិសេធទទួលយកកុមារពិការសតិបញ្ញា។ បន្ទាប់ពីកុមារក្រីក្រនិងកុមារដែលរស់នៅឆ្ងាយពីសាលារៀន ឬខ្វះមធ្យោបាយធ្វើដំណើរ ជាទូទៅគ្រូបង្រៀនបាននិយាយថា កុមារពិការមិនសូវទំនងថានឹងទៅរៀនឡើយដែលការលើកឡើងបែបនេះ មានចំនួនលើសកុមារដែលរងផលប៉ះពាលពីចំណាកស្រុកបន្តិច (ទៅក្នុងសហគមន៍ និងចាកចេញពីសហគមន៍បណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍)។

កុមារពិការសតិបញ្ញាចំនួន៣នាក់ដែលបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់បាននិយាយថា ពួកគេឈប់ទៅរៀននៅឯសាលារដ្ឋទៀតហើយ ដោយសារតែពួកគេរៀនមិនទាន់សិស្សដទៃទៀត។ ពួកគេមានអារម្មណ៍ថាគ្រូមិនចេះអំពីវិធីបង្រៀនពួកគេ និងមិនយល់អំពីសេចក្តីត្រូវការរបស់ពួកគេដែលចំណុចនេះមានពិភាក្សាលម្អិតជាងនេះនៅក្នុងផ្នែកដែលនិយាយអំពីលទ្ធភាពអាចបត់បែនបាន។

នៅពេលពិភាក្សាអំពីបញ្ហាកុមារពិការ ឪពុកម្តាយរមែងតែងបញ្ចូលកុមារដែលមានជម្ងឺមួយចំនួនដូចជារលាកស្រោមខួរ និងជម្ងឺឆ្កួតជ្រូក[36]។ ឪពុកម្តាយមួយក្រុមក្នុងខេត្តសៀមរាបបាននិយាយថា កុមារាម្នាក់ដែលមានជម្ងឺឆ្កួតជ្រូកនៅក្នុងឃុំរបស់ពួកគេមិនអាចទៅរៀនបានឡើយដោយសារតែធម្មជាតិនៃជម្ងឺរបស់គាត់និងពុំមានកិច្ចគាំទ្រដើម្បីជួយឱ្យគាត់ទៅរៀនបាននោះទេ។ ក្នុងអំឡុងពេលនៃការចុះទស្សនកិច្ចទៅកាន់

---

[36] គេអាចគ្រប់គ្រងទៅលើអាការៈប្រកាច់បានប្រមាណ ៧០% នៃករណីសរុប ជាមួយនឹងការព្យាបាលវេជ្ជសាស្រ្តសមស្រប ដែលត្រូវបានកែសម្រួលជាទៀងទាត់។ នាយកដ្ឋានសុខភាពសិក្សា អាចដើរតួនាទីមួយដ៏សំខាន់នៅក្នុងករណីបែបនេះ។

សាលាបឋមសិក្សាមួយ អ្នកស្រាវជ្រាវបានជួបកុមារាម្នាក់ដែលមានជម្ងឺឆ្កួតជ្រូក នៅក្នុងទីធ្លាសាលារៀន។ អ្នកស្រាវជ្រាវបាននិយាយទៅកាន់គាត់ ម្តាយរបស់គាត់ គ្រូបង្រៀន និងកុមារដទៃទៀត និងបានរកឃើញថា គាត់ធ្លាប់ទៅរៀនញឹកញាប់កាលពីមុន ប៉ុន្តែ ឥឡូវនេះ គាត់ឈប់ទៅរៀនទៀតហើយ។ មូលហេតុមួយផ្នែក នៃការដែលគាត់ឈប់រៀនបែបនេះ គឺដោយសារតែគាត់មានការលំបាកក្នុងការរៀនសូត្រ ហើយគាត់ក៏មាន អាការៈប្រកាច់ញឹកញាប់ផងដែរ។ កុមារដែលមានជម្ងឺឆ្កួតជ្រូក កម្រទទួលបានកិច្ចគាំទ្រផ្នែកសុខភាពខ្លាំង ណាស់ ហើយគ្រូបង្រៀនអាចមិនដឹងច្បាស់អំពីវិធីដោះស្រាយចំពោះបញ្ហាប្រកាច់នេះ។ នៅពេលចុះធ្វើ ទស្សនកិច្ច អ្នកស្រាវជ្រាវបានឃើញក្មេងប្រុសម្នាក់នោះប្រកាច់នៅក្នុងកន្លែងក្មេងលេង ប៉ុន្តែ ពុំមាននរណា ម្នាក់ដឹងច្បាស់អំពីវិធីជួយកុមារាម្នាក់នោះ ឬ តើគួរជួយកុមារាម្នាក់នោះដែរឬអត់ឡើយ។ ឪពុកម្តាយបាន ប្រាប់ឱ្យដឹងថា សាលារៀនមិនបានធ្វើការងារឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់កុមារដែលមានជម្ងឺ ឬ កុមារ ពិការឱ្យចូលរៀន ឬ ជួយឪពុកម្តាយរបស់ពួកគេឱ្យចេះអប់រំពួកគេនៅឯផ្ទះឡើយ។

ឪពុកម្តាយរបស់កុមារពិការដែលបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ បានលើកឡើងអំពីកត្តា ដូចគ្នាដែលរាំងស្ទះ ចំពោះលទ្ធភាពទទួលបានការអប់រំ ដូចឪពុកម្តាយនៅក្នុងក្រុមពិភាក្សាទូទៅដែរ ឧទាហរណ៍ការដែលសាលារៀនស្ថិតនៅឆ្ងាយពីផ្ទះខ្លាំងពេក និងកង្វះមធ្យោបាយធ្វើដំណើរ។ ចំណុចខុស ប្លែកតែមួយគត់ដែលបានលើកឡើង គឺកង្វះមណ្ឌលសុខភាពនៅជិតផ្ទះរបស់ពួកគេ។ កុមារពិការដែលបាន ចូលរួមសិក្ខាសាលាពិគ្រោះយោបល់បានលើកឡើងអំពីកត្តាផ្សេងៗគ្នា ដែលខុសពីកុមារដទៃទៀតបានលើក ឡើង ដូចជាការដែលគ្រូមិនយកចិត្តទុកដាក់ចំពោះពួកគេ។ បើទោះបីជាកុមារ និងឪពុកម្តាយមួយចំនួនបាន រាយការណ៍ឱ្យដឹងអំពីបញ្ហាការរើសអើងក៏ដោយ ប៉ុន្តែកុមារ និងឪពុកម្តាយដទៃទៀតបានប្រាប់ឱ្យដឹងថាកុមារ ពិការមានលទ្ធភាពទៅរៀនបានដោយសារតែគ្រូបង្រៀន និងសិស្សបានលើកទឹកចិត្តពួកគេ។

ឪពុកម្តាយកុមារពិការបានផ្តល់មូលហេតុខុសគ្នាពីឪពុកម្តាយដទៃទៀតអំពីការដែលកូនរបស់ពួកគេ បានបោះបង់ការសិក្សា ៖

- សិស្សមានការលំបាកផ្នែកសតិបញ្ញា ដូច្នេះពួកគេមិនអាចបន្តការសិក្សារបស់ពួកគេទៅកម្រិតខ្ពស់ បាន
- ពុំមានថ្នាក់ពិសេសសម្រាប់កុមារពិការ នៅឯសាលារដ្ឋ
- កុមារពិការរងគ្រោះពីការរើសអើងពីមិត្តភក្តិ និងសហគមន៍
- ពុំមានកម្មវិធីអាហារូបករណ៍ដើម្បីគាំទ្រដល់កុមារពិការ
- កុមារពិការមានអារម្មណ៍ខ្មាស់អៀន និងខកចិត្តនៅឯសាលារៀន។

ដូចគ្នាទៅនឹងកុមារដទៃទៀតដែរកុមារពិការបាននិយាយថា កង្វះសម្ភារៈរៀនសូត្រនិងមធ្យោបាយធ្វើដំណើរ គឺជាកត្តាដែលធ្វើឱ្យពួកគេបោះបង់ការសិក្សា។ មូលហេតុដែលបានផ្តល់ជូនជាក់លាក់ចំពោះស្ថានភាពរបស់ ពួកគេរួមមាន ការដែលពួកគេរៀនមិនទាន់ដោយសារតែឈប់ជាញឹកញាប់ គឺពួកគេជាសិស្សដែលរៀនយឺត និងខ្វះសម្ភារៈបរិក្ខារ ដូចជាទីជម្រាល កៅអី និងបង្គន់សមស្រប។

ការសិក្សាមួយអំពីកុមារពិការនៅតំបន់ជនបទប្រទេសកម្ពុជាបានរកឃើញថា កុមារពិការគ្រប់អាយុចូលរៀនចំនួន៥៥%ធ្លាប់បានចូលរៀនខ្លះ ប៉ុន្តែពួកគេភាគច្រើនរៀនបានត្រឹមថ្នាក់ទី១ ឬថ្នាក់ទី២ប៉ុណ្ណោះ។ ៤៥%ទៀតមិនធ្លាប់បានចូលរៀនទាល់តែសោះ[37]។ ការសិក្សាមួយទៀតអំពីពិការភាពសតិបញ្ញានៅតំបន់ជនបទប្រទេសកម្ពុជា បានរកឃើញអត្រាវត្តមានស្រដៀងគ្នាមួយនៅឯសាលារៀនដែលមានកម្រិត ៥៤% ក្នុងចំណោមកុមារពិការ[38] ដែលអត្រានេះទាបជាងមធ្យមភាគថ្នាក់ជាតិយ៉ាងខ្លាំង។ ក្នុងចំណោមកុមារទាំងនោះ មានកុមារចំនួន ៧%បានចូលរៀនថ្នាក់អប់រំពិសេសសម្រាប់ជនគថ្លង់ ដែលផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាលមួយ[39]។

ការសិក្សាអំពីកុមារពិការនៅតំបន់ជនបទប្រទេសកម្ពុជាបានប៉ាន់ប្រមាណថា ប្រជាពលរដ្ឋប្រមាណ ៤,៧% មានពិការភាពប្រភេទណាមួយ។ គួរកត់សម្គាល់ពីការសិក្សានេះថា ក្នុងចំណោម ២៥% ដែលពិបាកក្នុងការមើលមានតែ ២% ប៉ុណ្ណោះដែលពាក់វ៉ែនតា។ ៤២% មានការលំបាកក្នុងការធ្វើចលនា ប៉ុន្តែមានតែពាក់កណ្តាលប៉ុណ្ណោះនៃក្រុមនេះដែលប្រើប្រាស់ឧបករណ៍ជំនួយការធ្វើចលនា។ កុមារមួយចំនួនអាចត្រូវបានកំណត់ថា ខ្សោយចក្ខុវិញ្ញាណ ដូចជាមើលមិនសូវច្បាស់ ប៉ុន្តែតាមពិតពួកគេគ្រាន់តែត្រូវការវ៉ែនតា ដែលសមស្របសម្រាប់ពួកគេប៉ុណ្ណោះ[40]។

កុមារមួយចំនួនអាចមានពិការភាព ប៉ុន្តែពួកគេមិនត្រូវបានកំណត់ថាជាជនពិការឡើយដោយសារតែពិការភាពរបស់ពួកគេពុំបានបង្ហាញឱ្យឃើញច្បាស់លាស់ និងខ្វះកិច្ចសហប្រតិបត្តិការក្នុងចំណោមបណ្តាក្រសួង/ទីភ្នាក់ងារនានា។ ផ្នែកមួយនៃបញ្ហានេះ គឺកង្វះសេវាសុខភាព បើទោះបីជាបញ្ហាត្រូវបានកំណត់រកឃើញក៏ដោយ។ នៅក្នុងប្រទេសកម្ពុជាមានអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ដូចជាអង្គការគ្រួសារថ្មីមនុស្សលោកថ្មី អង្គការជនពិការអន្តរជាតិ អង្គការអតីតយុវជនអន្តរជាតិកម្ពុជា សាលារៀនទន្សាយ និង Epic Arts ដែលធ្វើការងារដើម្បីផ្តល់សេវាសុខភាពនិង សេវាអប់រំពិសេស ជូនដល់កុមារពិការ *(សូមមើលប្រអប់ ២ ៖ សាលារៀនគ្រួសារថ្មីសម្រាប់កុមារពិការ)*។ ជាមួយនឹងការផ្តល់សេវាផ្ទាល់ខ្លួនរបស់ពួកគេ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនក៏ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយសាលារៀន និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកែលម្អលទ្ធភាពទទួលបានការអប់រំផងដែរ។ ឧទាហរណ៍នៅឯសាលាបឋមសិក្សាក្រុងកំពត អង្គការគ្រួសារថ្មីបាននឹងកំពុងធ្វើការងារជាមួយសាលារៀន ដើម្បីបង្កលក្ខណៈឱ្យកុមារដែលមើលមិនសូវច្បាស់ត្រូវបានបញ្ចូលនៅក្នុងថ្នាក់រៀន ព្រមទាំងផ្តល់កែវពង្រីក ជើងទ្រសៀវភៅ អំពូលដង្កៀប និងសៀវភៅអានដែលមានទំហំអក្សរធំៗ។ អង្គការគ្រួសាថ្មីបានរកឃើញថា បន្ទាប់ពីការបណ្តុះបណ្តាលបឋម ដូចជាការជួយឱ្យគ្រូបង្រៀនយល់អំពីសារៈសំខាន់នៃការរៀបចំឱ្យកុមារដែលមើលមិនសូវច្បាស់អង្គុយនៅតុខាងមុខ ការបន្ត

---

[37]Betsy VanLeit, Samol Channa, Prum Rithy, 2007, *កុមារពិការនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា PASIFIC DISABILITY REHABILITATION JOURNAL* Vol. 18 No.2

[38]Moreira, R. (2011), *ពិការភាពសតិបញ្ញានៅតំបន់ជនបទប្រទេសកម្ពុជា ការយល់ឃើញទៅលើវប្បធម៌ និងការប្រឈមរបស់គ្រួសារ* ភ្នំពេញ អង្គការ New Humanity

[39]Betsy Van Leit, Samol Channa, Prum Rithy, 2007, *កុមារពិការនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា PASIFIC DISABILITY REHABILITATION JOURNAL* Vol. 18 No.2

[40]អង្គការគ្រួសារថ្មីបានប្រាប់ឱ្យដឹងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថា នៅក្នុងក្របខ័ណ្ឌនៃគម្រោងសាកល្បងមួយនៅក្នុងខេត្តកំពត កុមារប្រមាណ ២៥នាក់ ត្រូវបានកំណត់អត្តសញ្ញាណបឋមថា ខ្សោយចក្ខុវិញ្ញាណ។ បើទោះជាដូច្នេះក្តី ក្រោយកាប៉ាន់ប្រមាណបន្ថែម គេបានដឹងថា កុមារ ១៩នាក់ ក្នុងចំណោមកុមារទាំងនោះ ត្រូវការតែវ៉ែនតាប៉ុណ្ណោះ ដើម្បីឱ្យពួកគេអាចមើលឃើញបាន។

ផ្តល់ការបង្ហាត់បង្ហាញមានសារៈសំខាន់ខ្លាំងណាស់។ នេះគឺជាឧទាហរណ៍អំពីរបៀបកំណត់អត្តសញ្ញាណនិងប៉ាន់ប្រមាណសាមញ្ញៗដើម្បីផ្តល់ជំនួយយ៉ាងងាយស្រួលចំពោះកុមារដែលអាចមានការលំបាក។

**ប្រអប់ទី២ ៖ សាលារៀនគ្រួសារថ្មីសម្រាប់កុមារពិការ**

គ្រួសារថ្មី គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ គ្រប់គ្រងសាលារៀនចំនួន៥ ក្នុងប្រទេសកម្ពុជា ដែលផ្តល់ការអប់រំជូនដល់កុមារគថ្លង់។ ប្រសិនបើកុមារម្នាក់ជាកុមារពិការភ្នែក ឬមើលមិនសូវច្បាស់កុមារនោះនឹងត្រូវសិក្សាថ្នាក់ទី១រយៈពេល២ឆ្នាំនៅសាលារៀនគ្រួសារថ្មី បន្ទាប់មកត្រូវរៀនថ្នាក់ទី២រយៈពេល១ឆ្នាំមុនពេលចូលរៀនថ្នាក់ទី៣នៅឯសាលារដ្ឋ។ នៅពេលចូលរៀននៅឯសាលារដ្ឋកុមារត្រូវទៅរៀនកន្លះថ្ងៃដូចសិស្សទូទៅក្នុងប្រទេសកម្ពុជាដែរ និងបន្ទាប់មកត្រូវរៀនកន្លះថ្ងៃបន្ថែមទៀតនៅឯសាលារៀនគ្រួសារថ្មី។ សម្រាប់កុមារថ្លង់ការសិក្សាពីថ្នាក់ដំបូងត្រូវអនុវត្តតាមដំណើរការដូចគ្នាទៅនឹងកុមារពិការភ្នែកដែរ ប៉ុន្តែពួកគេត្រូវបន្តរៀននៅសាលារៀនគ្រួសារថ្មី រហូតដល់ថ្នាក់ទី៤ និងបន្ទាប់មកត្រូវអនុវត្តតាមមាគ៌ាដូចគ្នាទៅនឹងកុមារពិការភ្នែក។កុមារថ្លង់ត្រូវរៀននៅក្នុងសាលារៀនគ្រួសារថ្មីរយៈពេលយូរជាងដោយសារតែពួកគេត្រូវចំណាយពេលវេលាយូរជាងដើម្បីរៀនភាសាសញ្ញា បើធៀបទៅនឹងការដែលកុមារពិការភ្នែកត្រូវរៀនអក្សរពក។

សាលារៀនក្នុងប្រទេសកម្ពុជា មានឧបករណ៍ពិសេសបន្តិចបន្តួច ឬស្ទើរតែគ្មានឧបករណ៍ពិសេសទាល់តែសោះសម្រាប់កុមារពិការ។ ឧទាហរណ៍ ការផលិតសៀវភៅអក្សរពកសម្រាប់កុមារពិការភ្នែក និងសៀវភៅភាសាសញ្ញាសម្រាប់កុមារថ្លង់ ត្រូវបានអង្គការគ្រួសារថ្មីធានាទាំងស្រុងថា បានអនុវត្តតាមកម្មវិធីសិក្សាផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ការត្រួតពិនិត្យកែសម្រួលមួយចំនួន[41]។

អង្គការមិនមែនរដ្ឋាភិបាលដែលយើងជួបបានគាំទ្រដល់គោលបំណងនៃការអប់រំបញ្ចូលគ្នា ដូចជាកុមារពិការទទួលបានការអប់រំនៅក្នុងថ្នាក់រៀនដែលមានលក្ខណៈជាបទដ្ឋាន។ បើទោះជាដូច្នេះក្តីពួកគេក៏បានផ្តល់ដំបូន្មានផងដែរថា មានកុមារមួយចំនួនត្រូវការឱ្យមានការអប់រំ ដោយឡែកដែលមានលក្ខណៈឯកទេសជាងនេះទើបជាការប្រសើរ។ យ៉ាងណាមិញ ថ្នាក់រៀនដាច់ដោយឡែកពីគ្នាទាំងនេះនៅតែអាចធ្វើការច្របាច់បញ្ចូលគ្នានៅក្នុងសាលារៀនមួយដែលមានលក្ខណៈជាបទដ្ឋាន។ ដង់ស៊ីតេកុមារពិការដែលមានចំនួនទាបធ្វើឱ្យមានការលំបាកក្នុងការសាងសង់សាលារៀន ពិសេសនៅក្នុងតំបន់ដែលស្ថិតនៅជិតផ្ទះរបស់ពួកគេ ដូច្នេះគេបានផ្តល់មតិយោបល់ឱ្យសាងសង់អន្តេវាសិកដ្ឋានសម្រាប់កុមារពិការ នៅឯសាលារៀនពិសេស។ ការផ្លាស់ប្តូរបែបនេះអាចជួយប្តូរទៅលើការដែលប្រព័ន្ធអប់រំបច្ចុប្បន្នមិនបានជួយដល់កុមារពិការឱ្យទៅចូលរៀននៅឯសាលា។

[41]អង្គការគ្រួសារថ្មីកំពុងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ហើយគេសង្ឃឹមថានៅពេលអនាគត ក្រសួងនឹងទទួលខុសត្រូវឱ្យបានច្រើនជាងនេះ ក្នុងការផ្តល់សៀវភៅសមស្របសម្រាប់កុមារថ្លង់ ឬ កុមារពិការភ្នែក។

### *៤.១.១២. កុមារក្រុមជនជាតិដើមភាគតិច*

បើទោះបីជាយើងបាននិយាយទៅកាន់ក្រុមជនជាតិដើមភាគតិចនៅខេត្តកំពត និងខេត្តរតនគិរី ក្នុងអំឡុងពេលពិភាក្សាជាក្រុមក៏ដោយ ប៉ុន្តែកុមារក្រុមជនជាតិដើមភាគតិចមិនធ្លាប់ត្រូវបានលើកឡើងថា ជាក្រុមកុមារជាក់លាក់មួយដែលមិនសូវទំនងថានឹងបានទៅសាលារៀនឡើយ។ ប្រាកដណាស់នៅពេលពិចារណាទៅលើសហគមន៍របស់ពួកគេតែម៉្យាង ពួកគេពុំមែនមកពីជនជាតិដើមភាគតិចមួយឡើយ ដូច្នេះវាមិនទំនងក្នុងការដកចេញនូវជាតិពន្ធុ ថាជាមូលហេតុដែលបណ្តាលឱ្យកុមារមួយចំនួនទៅសាលារៀន និងកុមារមួយចំនួនទៀតមិនទៅសាលារៀនឡើយ។

អ្វីដែលមានភាពច្បាស់លាស់នោះ គឺឪពុកម្តាយគ្រប់ក្រុមទាំងអស់ និងឪពុកម្តាយដែលបានចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់របស់យើងគិតថា វាមានភាពងាយស្រួលជាងមុនសម្រាប់កុមារមកពីក្រុមជនជាតិដើមភាគតិចក្នុងការចូលរៀននៅឯសាលា បើប្រៀបធៀបទៅនឹងកាលពី៥ឆ្នាំមុន។ ឪពុកម្តាយដែលបានចូលរួមនៅក្នុងសិក្ខាសាលាជឿថា សិស្សមានភាពរីករាយក្នុងការទៅសាលារៀន និងទទួលបានចំណេះដឹង ដូច្នេះពួកគេលើកទឹកចិត្តឱ្យកុមារដទៃទៀតទៅសាលារៀនផងដែរ។ ឪពុកម្តាយទាំងនេះ ក៏បានប្រាប់ឱ្យដឹងផងដែរថា អង្គការមិនមែនរដ្ឋាភិបាលបានជួយលើកកម្ពស់ការអប់រំ។ សិស្សមានអារម្មណ៍ថាកុមារកាន់តែច្រើនជាងមុន មានមធ្យោបាយធ្វើដំណើរ និងសម្ភារៈរៀនសូត្រ ហើយសាលារៀនមានការផ្គត់ផ្គង់ទឹក និងមានបង្គន់។

ការលំបាកជាច្រើនដែលត្រូវបានរាយការណ៍ឱ្យដឹងនៅក្នុងសិក្ខាសាលានោះ គឺជាការលំបាកដែលកើតឡើងទូទៅចំពោះកុមារដទៃទៀត ៖ កង្វះថវិកាសម្រាប់ទិញសម្ភារៈ សាលារៀននៅឆ្ងាយពេក និង ខ្វះមធ្យោបាយធ្វើដំណើរ។ បើទោះបីជាមានអន្តេវាសិកដ្ឋានសម្រាប់សិស្សដែលរស់នៅឆ្ងាយក៏ដោយសិស្សបានប្រាប់ឱ្យដឹងថា ជួនកាលអន្តេវាសិកដ្ឋានទាំងនោះអាចមានទំហំតូចពេក ដូចជាសិស្ស៤០នាក់ស្នាក់នៅក្នុងមួយបន្ទប់។ កត្តាមួយដែលខុសប្លែក គឺឪពុកម្តាយមកពីក្រុមជនជាតិដើមភាគតិចមួយបានប្រាប់ឱ្យដឹងថា សិស្សស្រីអាចឆាប់ឈប់រៀនបាន ដោយសារតែពួកគេរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង។ ភាពខុសគ្នាមួយទៀត គឺឪពុកម្តាយបានរអ៊ូរទាំថា ការដែលគ្រូបង្រៀនមានគុណភាពមិនល្អ និងការដែលពួកគេមិនចេះនិយាយភាសាក្នុងមូលដ្ឋាន គឺជាមូលហេតុដែលបណ្តាលឱ្យកុមារបោះបង់ការសិក្សា ដោយចំណុចនេះសិស្សក៏បានលើកឡើងដូចគ្នាផងដែរ។ បើទោះជាដូច្នេះក្តី ការស្រាវជ្រាវដទៃទៀតនៅសាលាអនុវិទ្យាល័យខេត្តរតនគិរីបានរកឃើញថា កង្វះគ្រូបង្រៀនដែលចេះនិយាយភាសាក្នុងមូលដ្ឋាន ពុំមែនជាមូលហេតុដែលនាំឱ្យមានការបោះបង់ការសិក្សានោះទេ ប៉ុន្តែដំណើរការរៀនសូត្រជាក់ស្តែងជាភាសាខ្មែរ គឺជាកត្តាទូទៅបំផុតដែលរួមចំណែកបណ្តាលឱ្យមានការបោះបង់ការសិក្សា[42]។

អង្គការមិនមែនរដ្ឋាភិបាលមួយ បានធ្វើការទាញទំនាក់ទំនងអំពីការដែលប្រជាពលរដ្ឋជឿថា ការអប់រំកាន់តែខ្ពស់មិនបានធ្វើឱ្យពួកគេមានបាយទទួលទាននៅលើតុកាន់តែច្រើនឡើយ។ ប្រសិនបើកូនរបស់

[42]អង្គការឃែរអន្តរជាតិ (២០១០)។ *ការធ្វើឱ្យប្រសើរឡើងនូវអត្រាសិក្សារបស់សិស្សជនជាតិដើមភាគតិច នៅក្នុងសាលារៀនមធ្យមសិក្សាកុមារមេត្រី។* មិនត្រូវបានបោះពុម្ពផ្សាយ។

ពួកគេម្នាក់ទៅសាលារៀនពួកគេនៅតែមានបរិមាណបាយនៅលើតុ ដូចគ្នាទៅនឹងការដែលកូនរបស់ពួកគេទៅស្រែចម្ការដូច្នោះដែរ។ កង្វះគុណភាពអប់រំនេះត្រូវបានដកស្រង់ថាជាមូលហេតុសំខាន់បំផុតនៃការបោះបង់ការសិក្សា ក្នុងអំឡុងពេលនៃការស្រាវជ្រាវទៅលើកុមារដែលកំពុងរៀនសូត្រ នៅឯសាលារៀនក្នុងសហគមន៍ ខ្មែរលើក្នុងខេត្តរតនគិរី[43]។ ចំណុចនេះ គឺដោយសារតែគ្រូបង្រៀនមិនបានគាំទ្រដល់សិស្សដែលរៀនយឺត។ វាអាចមិនត្រឹមតែជាគុណភាពអប់រំខ្សោយដែលជាកត្តាមួយផ្នែកបណ្តាលឱ្យកុមារបោះបង់ការសិក្សាឡើយ ប៉ុន្តែការលំបាកទំនាក់ទំនងជាមួយគ្រូបង្រៀនក៏បណ្តាលឱ្យកុមារបោះបង់ការសិក្សាផងដែរ[44]។ អង្គការមិនមែនរដ្ឋាភិបាលមួយគិតថា បញ្ហាប្រឈមនៃការរៀនសូត្រជាភាសាខ្មែរសម្រាប់អ្នកដែលភាសាកំណើត មិនមែនជាខ្មែរ និងវប្បធម៌ខុសគ្នារវាងគ្រូបង្រៀន និងសិស្ស គឺជាបញ្ហាប្រឈមពីរចម្បងៗ។ បញ្ហាទាំងនេះ ត្រូវបានលើកយកមកពិភាក្សាលម្អិតជាងនេះ នៅក្នុងផ្នែកដែលនិយាយអំពីលទ្ធភាពសម្រប។

បញ្ហារយៈចម្ងាយទៅសាលារៀន អាចត្រូវបានធ្វើឱ្យកាន់តែមានភាពធ្ងន់ធ្ងរជាងនេះ តាមរយៈការផ្លាស់ប្តូរឧស្សាហកម្មក្នុងប្រទេសកម្ពុជាដែលកាត់បន្ថយបរិមាណដី ព្រៃដែលមាននៅក្បែរភូមិមានន័យថា នៅក្នុងករណីមួយចំនួនចម្ការក្រុមជនជាតិដើមភាគតិចស្ថិតនៅកាន់តែឆ្ងាយពីភូមិដែលធ្វើឱ្យពួកគេមិនវិលត្រឡប់មកភូមិរបស់ពួកគេវិញ។

ក្រុមពិភាក្សាបានប្រាប់ឱ្យដឹងថា ថ្លៃចំណាយនៃការទៅសាលារៀនរាប់បញ្ចូលទាំងថ្លៃរៀនគួជាពិសេសនៅកម្រិតអនុវិទ្យាល័យបង្កឱ្យមានការលំបាកមួយចំនួន។ អង្គការមិនមែនរដ្ឋាភិបាលបានប្រាប់ឱ្យដឹងថា បញ្ហានេះរួមជាមួយនឹងឱកាសកាន់តែច្រើនជាងមុនក្នុងការរកប្រាក់បានបង្កឱ្យមានជាបញ្ហា។ ឥឡូវនេះកុមារអាចរកប្រាក់បាន៥ដុល្លាក្នុងមួយថ្ងៃ ដោយធ្វើការងារនៅក្នុងព្រៃ និងឧស្សាហកម្មកៅស៊ូ ហើយពួកគេអាចក្លែងបន្លំឯកសាររបស់ពួកគេបានដើម្បីបញ្ជាក់ថា ពួកគេមានអាយុល្មមអាចធ្វើការងារបាន។

[43]អង្គការយូនីសេហ្វ (២០១០)។ *ការធ្វើឱ្យប្រសើរឡើងនូវអត្រាសិក្សារបស់សិស្សជនជាតិដើមភាគតិច នៅក្នុងសាលារៀនមធ្យមសិក្សាកុមារមេត្រី។* មិនត្រូវបានបោះពុម្ពផ្សាយ។
[44]អង្គការយូនីសេហ្វ (២០១០)។ *ការធ្វើឱ្យប្រសើរឡើងនូវអត្រាសិក្សារបស់សិស្សជនជាតិដើមភាគតិច នៅក្នុងសាលារៀនមធ្យមសិក្សាកុមារមេត្រី។* មិនត្រូវបានបោះពុម្ពផ្សាយ។




កុមារជនជាតិដើមភាគតិចចូលរួមសិក្ខាសាលាពិគ្រោះយោបល់នៅភ្នំពេញ

ក្រសួងអប់រំ យុវជន និងកីឡា កំពុងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កុមារក្រុមជនជាតិដើមភាគតិច និងបានចេញសេចក្តីណែនាំដែលបង្កើតឱ្យមាននូវគោលការណ៍ណែនាំអំពីវិធីអនុវត្តការអប់រំពីរភាសា។ ផែនការសកម្មភាពរយៈពេល៥ឆ្នាំ មួយក៏កំពុងត្រូវបានអភិវឌ្ឍផងដែរ ហើយគេកំពុងធ្វើការងារជាមួយអង្គការឃែរ ដើម្បីរៀបចំឱ្យមានគ្រូបង្គោលសម្រាប់បង្រៀនគរុសិស្សពីរភាសា។ ក្រសួងអប់រំ យុវជន និងកីឡាក៏មានសាលារៀនពីរភាសាចំនួន ៥២ ដែលមានថ្នាក់ទី១ រហូតដល់ថ្នាក់ទី៣ ក្នុងខេត្តចំនួន៤ (ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ) ដោយមានសិស្សចំនួន ៤.១២៦នាក់ និងគ្រូចំនួន ២០៥នាក់។

### *៤.១.១៣. ការប្រៀបធៀបការរៀនរបស់កុមារឆ្នាំ ២០០៨ - ២០១៣*

គ្រប់ក្រុមពិភាក្សាទាំងអស់ដែលមានសមាសភាពចូលរួមពីឪពុកម្តាយ លើកលែងតែមួយក្រុមបានគិតថា ឥឡូវនេះកុមារមានភាពងាយស្រួលជាងក្នុងការទៅសាលារៀន បើធៀបទៅនឹងកាលពី៥ឆ្នាំមុន។ មូលហេតុ ដែលត្រូវបានផ្តល់ញឹកញាប់បំផុត សម្រាប់ចំណុចនេះ គឺបច្ចុប្បន្នមានសាលារៀនច្រើនជាងមុន ដែលគេអាចយល់បានថា សាលារៀនទំនងនឹងស្ថិតនៅកាន់តែជិតផ្ទះរបស់ប្រជាពលរដ្ឋ។ ការមានគ្រូបង្រៀនច្រើនជាងមុន គឺជាមូលហេតុដែលត្រូវបានលើកឡើងញឹកញាប់បំផុត លំដាប់លេខរៀងទី២។ ឪពុកម្តាយនៅខេត្តកំពត និងខេត្តរតនគិរី រមែងតែងបានប្រាប់ឱ្យដឹងថា ផ្លូវថ្នល់ដែលល្អជាងមុន (ឬ ស្ពានដែលកំពុងត្រូវបានសាងសង់) បានធ្វើឱ្យមានភាពងាយស្រួលជាងមុនយ៉ាងច្រើន។ ឪពុកម្តាយនៅខេត្តកំពតក៏

បានផ្តោតសារៈសំខាន់យ៉ាងខ្លាំង ទៅលើការដែលឪពុកម្តាយត្រូវខិតខំលើកទឹកចិត្តកូនឱ្យទៅសាលារៀនបន្ថែមទៀត ដោយឡែកឪពុកម្តាយនៅខេត្តរតនគិរី រមែងតែងបានលើកឡើងឱ្យដឹងថា វាមានភាពងាយស្រួលជាងមុនសម្រាប់កូនរបស់គេក្នុងការទៅសាលារៀន ដោយសារតែកុមារច្រើនជាងមុនចង់រៀនសូត្រជាពិសេសពួកគេបានលើកឡើងអំពីចំណង់ចំណូលចិត្តក្នុងការរៀនភាសាខ្មែរ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺខណៈពេលដែលផ្លូវថ្នល់ល្អជាងមុន និង គ្រូបង្រៀនច្រើនជាងមុនគឺជាកត្តាដែលបានធ្វើឱ្យមានភាពងាយស្រួលជាងមុនក្នុងការទៅសាលារៀនក្នុងរយៈពេល៥ឆ្នាំកន្លងមកប៉ុន្តែចំណុចទាំងនេះមិនត្រូវបានកំណត់ថា ជាកត្តាដែលរាំងស្ទះដល់ការទៅសាលារៀននាពេលបច្ចុប្បន្នឡើយ។ រយៈចម្ងាយទៅសាលារៀននៅតែត្រូវបានគេយល់ឃើញថាមានសារៈសំខាន់ ប៉ុន្តែជំនួសឱ្យសេចក្តីត្រូវការសាលារៀនបន្ថែម ប្រជាពលរដ្ឋភាគច្រើនចង់បានមធ្យោបាយធ្វើដំណើរ។ ចំណុចនេះបង្ហាញឱ្យដឹងថាអ្វីដែលមានដំណើរការប្រព្រឹត្តទៅបាននៅពេលអតីតកាល មិនគួរសន្និដ្ឋានថាអាចមានដំណើរការប្រព្រឹត្តទៅបាននៅពេលអនាគតឡើយ។ សកម្មភាពនៅពេលអនាគតអាចផ្តោតលើការជួយដល់គ្រួសារជាមួយនឹងថ្លៃចំណាយសម្រាប់ការទៅរៀន ដូចជាសម្ភារៈរៀនសូត្រនិងការផ្តល់មធ្យោបាយធ្វើដំណើរដើម្បីជួយដល់សិស្សក្នុងការទៅសាលារៀន។

មានក្រុមពិភាក្សាដែលមានសមាសភាពចូលរួមពីឪពុកម្តាយមួយក្រុម ដែលជឿថា បច្ចុប្បន្នមានការលំបាកជាងមុនក្នុងការទៅសាលារៀន ដោយក្រុមឪពុកម្តាយនេះស្ថិតនៅក្នុងក្រុងសៀមរាប។ ពួកគេបានប្រាប់ឱ្យដឹងថាបច្ចុប្បន្ន ពួកគេត្រូវចំណាយថវិកាច្រើនជាងមុនក្នុងការបញ្ជូនកូនទៅសាលារៀន។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺផលប៉ះពាល់នៃភ្ញៀវទេសចរក្នុងខេត្តសៀមរាប ត្រូវបានក្រុមឪពុកម្តាយ និងសិស្សនៅស្រុកបន្ទាយស្រីមើលឃើញជាវិជ្ជមាន ដោយពួកគេបានប្រាប់ឱ្យដឹងថា ការដែលភ្ញៀវទេសចរផ្តល់សៀវភៅ ឬជួយផ្នែកភាសាអង់គ្លេសបានធ្វើឱ្យកុមារកាន់តែមានភាពងាយស្រួលក្នុងការបន្តរៀនសូត្រនៅឯសាលារៀនហើយឪពុកម្តាយម្នាក់ថែមទាំងបាននិយាយទៀតថា តាមរយៈការលក់វត្ថុអនុស្សាវរីយ៍ កុមារអាចទៅរៀនបាន។

ឪពុកម្តាយក្រុមជនជាតិដើមភាគតិច និងឪពុកម្តាយជនពិការបាននិយាយថា ការទៅសាលារៀនមានភាពងាយស្រួលជាងកាលពី៥ឆ្នាំ។ ចំណុចនេះគឺដោយសារតែមានសាលារៀននៅក្នុងភូមិផ្លូវថ្នល់ល្អជាងមុន និងសម្ភារៈបរិក្ខារនៅឯសាលារៀនមានភាពប្រសើរជាងមុន។

### ៤.២. ភាពអាចទទួលយកបាននៃសេវាអប់រំ

សិស្សភាគច្រើនលើសលប់បានរាយការណ៍ឱ្យដឹងថា ពួកគេទទួលបានការអប់រំមួយដែលមានគុណភាពល្អហើយឪពុកម្តាយភាគច្រើនក៏បានរាយការណ៍អំពីការពេញចិត្តទៅនឹងគុណភាពអប់រំដែលមាននៅក្នុងសាលារៀនរបស់ពួកគេផងដែរ។ យ៉ាងណាមិញកម្រិតនៃភាពពេញចិត្តត្រូវតែយកមកពិចារណាធៀបទៅនឹងកម្រិតនៃការរំពឹងទុក។ ប្រសិនបើការរំពឹងទុកទៅលើគុណភាពមានកម្រិតទាបខ្លាំងពេលនោះ គុណភាពអប់រំមួយដែលល្អខ្លាំងមិនចាំបាច់តម្រូវឱ្យប្រជាពលរដ្ឋមានការពេញចិត្តឡើយ។ ចំណុចនេះអាចជាការពន្យល់

មួយផ្នែកអំពីការពេញចិត្តទាំងនេះដែលត្រូវបានរាយការណ៍ថាមានកម្រិតខ្ពស់ អាស្រ័យដោយសិស្សចំនួនពីរក្រុមបាននិយាយថា ពួកគេមានអារម្មណ៍ថាពួកគេទទួលបានគុណភាពអប់រំល្អព្រោះពួកគេអាចអាន និងសរសេរបាន។

ស្រដៀងគ្នានេះដែរ កុមារស្ទើរគ្រប់រូបត្រូវបានសម្ភាសន៍ ដែលបានបោះបង់ការសិក្សាមុនថ្នាក់ទី៩ បានគិតថាការអប់រំដែលពួកគេទទួលបានមានគុណភាពល្អ ហើយពួកគេភាគច្រើននិយាយថា ពួកគេអាចអាន និងសរសេរបាន។ បើទោះជាដូច្នេះក្តី កុមារដែលបានបោះបង់ការសិក្សាប្រមាណពាក់កណ្តាលប៉ុណ្ណោះ បាននិយាយថាពួកគេចេះលេខនព្វន្ត។ យើងឃើញថាការរំពឹងទុកគឺត្រឹមតែចេះអាន និងសរសេរបាន ប៉ុណ្ណោះ។

យើងបានសួរកុមារដែលបានបោះបង់ការសិក្សា ថាតើពួកគេចង់ធ្វើការងារអ្វី។ សម្រាប់កុមារដែលបានបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាភាគច្រើនឆ្លើយថា ពួកគេមិនដឹងថាខ្លួនចង់ធ្វើអ្វីឡើយ។ ចំណុចនេះអាចឆ្លុះបញ្ចាំងអំពីការយល់ដឹងមួយក្នុងចំណោមពួកគេថា ពួកគេមិនដឹងថាពួកគេអាចធ្វើការងារអ្វីបានឡើយជាមួយនឹងការអប់រំដ៏មានកម្រិតបែបនេះ។ ចម្លើយទូទៅបំផុតបន្ទាប់ គឺពួកគេចង់ក្លាយជាគ្រូបង្រៀន ឬជាងជួសជុលម៉ូតូ ដោយបុគ្គលម្នាក់ៗបានលើកឡើងអំពីការងារមួយចំនួន ដូចជាជាងកាត់ដេរសម្លៀកបំពាក់កម្មករសំណង់ ជាងអ៊ុតសក់ និងអ្នកលក់ដូរ។ កុមារចំនួនពាក់កណ្តាលមានអារម្មណ៍ថា ពួកគេមានការអប់រំដែលចាំបាច់សម្រាប់ការងារទាំងនេះ។

សម្រាប់កុមារដែលបានបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យ មានតែកុមារចំនួន២នាក់ក្នុងចំណោម១៥នាក់ប៉ុណ្ណោះដែលបាននិយាយថា ពួកគេមិនដឹងថាចង់ធ្វើការងារអ្វី។ ចម្លើយទូទៅបំផុតចំនួនពីរគឺការងារនៅក្នុងធនាគារឬការងារជាគ្រូបង្រៀន។ វាអាចថាប្រធានបទនៃកិច្ចសម្ភាសន៍ (ការអប់រំ) បានជះឥទ្ធិពលទៅលើប្រជាពលរដ្ឋឱ្យនិយាយថា ការក្លាយជាគ្រូបង្រៀនគឺជាការងារមួយដែលពួកគេចង់ធ្វើ។ មានមនុស្ស២នាក់ ក៏ចង់ក្លាយជាវេជ្ជបណ្ឌិត និងធ្វើការងារដទៃទៀតផងដែរ ដូចជាជាងកាត់ដេរ និងជាងអ៊ុតសក់។ កុមារដែលបានបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យចង់បានការងារដែលទាមទារឱ្យមានជំនាញខ្ពស់ជាងប្រភេទការងារដែលលើកឡើងដោយកុមារដែលបានបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា។ ជាអកុសល្យមហិច្ឆតាមានទំហំធំ ប៉ុន្តែគម្លាតរវាងមហិច្ឆតា និងតថភាពជាក់ស្តែងក៏ត្រូវបានគេយល់ឃើញថាមានទំហំធំដូចគ្នាផងដែរ អាស្រ័យដោយកុមារភាគច្រើនបាននិយាយថា ពួកគេពុំមានការអប់រំចាំបាច់ដើម្បីធ្វើការងារដែលពួកគេចង់ធ្វើឡើយ។

### *៤.២.១. ទស្សនៈរបស់សិស្សចំពោះគ្រូបង្រៀន*

ក្រុមសិស្សស្ទើរគ្រប់ក្រុមដែលយើងបាននិយាយជាមួយបានប្រាប់ឱ្យដឹងថា គ្រូល្អមានសារៈសំខាន់ដើម្បីធ្វើឱ្យគុណភាពអប់រំល្អ ហើយឪពុកម្តាយក៏បានចែករំលែកអំពីអារម្មណ៍ដូចគ្នានេះផងដែរ។ ជាទូទៅយើងឃើញថាទាំងឪពុកម្តាយ និងសិស្សសុទ្ធសឹងតែពេញចិត្តទៅនឹងគុណភាពគ្រូបង្រៀននៅក្នុងសាលារៀនរបស់ពួកគេ ហើយនៅពេលដែលសិស្សជឿថាពួកគេទទួលបានការអប់រំមួយដ៏ល្អ ត្រូវបានសួរថាហេតុអ្វីបាន

ជាពួកគេជឿយ៉ាងដូច្នេះ ចម្លើយទូទៅបំផុតដែលទទួលបានកន្លងមក គឺដោយសារតែពួកគេមានគ្រូបង្រៀនមួយដ៏ល្អ។

សូម្បីតែនៅតំបន់ជនបទ ដូចជាស្រុកបន្ទាយស្រី(ខេត្តសៀមរាប)ក្រុមសិស្សនីមួយៗបានរាយការណ៍ឱ្យដឹងថា ពួកគេពេញចិត្តទៅនឹងគុណភាពគ្រូបង្រៀនរបស់ពួកគេ។ មានក្រុមមួយចំនួនតូចដែលមិនពេញចិត្តទៅនឹងគុណភាពគ្រូបង្រៀនរបស់ពួកគេ ប៉ុន្តែចំណុចនេះមិនសូវបានលើកឡើងទូទៅជាក់លាក់នៅក្នុងខេត្តណាមួយ ឬ មានភាពខុសគ្នារវាងតំបន់ទីក្រុង និងតំបន់ជនបទឡើយ។ មានតែមួយក្រុមប៉ុណ្ណោះដែលបានបន្ទោសអំពីគុណភាពអប់រំមិនល្អទៅលើគ្រូមិនល្អ ដោយនិយាយថាគ្រូបង្រៀនកម្រពន្យល់មេរៀន សរសេរច្រើនពេកនៅលើក្ដារខៀន និងមិនប្រើប្រាស់លំហាត់ជាឧទាហរណ៍។ ក្រុមមួយទៀតបានប្រាប់ឱ្យដឹងថា ពួកគេមានគ្រូបង្រៀនមិនល្អ ប៉ុន្តែពួកគេនៅតែទទួលបានការអប់រំក្នុងកម្រិតមួយដ៏ល្អដោយសារតែសិស្សប្រឹងរៀន។

ក្រុមសិស្សជាងពាក់កណ្ដាលបាននិយាយថា ពួកគេអាចតាមទាន់មេរៀនដែលគ្រូបង្រៀនគ្រប់ពេលទាំងអស់។ អ្វីដែលសំខាន់នោះ គឺតើសិស្សមានអារម្មណ៍ថាពួកគេអាចសូមឱ្យគ្រូបង្រៀនផ្ដល់ការពន្យល់ជាថ្មីម្ដងទៀត ឬពន្យល់ក្នុងលក្ខណៈមួយដែលខុសប្លែកពីមុនបានដែរឬទេ។ ក្រុមសិស្សចំនួន៤ក្រុមបាននិយាយថា សិស្សមួយចំនួនរៀនមិនទាន់ ដោយសារតែគ្រូបង្រៀនពន្យល់មិនបានល្អ ឬមិនបានគិតគូរអំពីសិស្សដែលរៀនយឺត។ បើទោះជាដូច្នេះក្ដី ក្រុមសិស្សចំនួន៥ក្រុមបាននិយាយថា មូលហេតុដែលសិស្សរៀនមិនទាន់គឺដោយសារតែសិស្សគ្មានវិន័យនៅក្នុងថ្នាក់។

ប្រសិនបើសិស្ស ឬឪពុកម្ដាយមិនពេញចិត្តទៅនឹងគ្រូបង្រៀន ភាគច្រើនវាទាក់ទងទៅនឹងឥរិយាបថរបស់គ្រូបង្រៀន ពាក់ព័ន្ធនឹងបញ្ហាអវត្តមាន ឬការប្រមូលប្រាក់។ ឪពុកម្ដាយមួយក្រុមបានប្រាប់ឱ្យដឹងថា គ្រូបង្រៀនអវត្តមាន ដោយសារតែនាយកសាលាមិនបានពង្រឹងការអនុវត្តន៍បទបញ្ជាដែលនាំឱ្យប៉ះពាល់ដល់គុណភាព។

ឪពុកម្ដាយបានសង្កត់ធ្ងន់ថា គ្រូបង្រៀនត្រូវយកចិត្តទុកដាក់ទៅលើសិស្សរបស់ពួកគេឱ្យបានល្អផ្ដល់ការពន្យល់ច្បាស់លាស់ត្រួតពិនិត្យទៅលើការរៀនសូត្ររបស់សិស្សពួកគេឱ្យបានទៀងទាត់ (ការអាន និងការសរសេរ) ប្រកាន់ខ្ជាប់វិន័យឱ្យបានល្អ និងណែនាំសិស្សឱ្យមានសីលធម៌ល្អ។ បន្ថែមពីលើលក្ខណៈសម្បត្តិទាំងនេះ គ្រូបង្រៀនត្រូវចេះទទួលខុសត្រូវ។ ឪពុកម្ដាយក៏បានកត់សម្គាល់ផងដែរថា គ្រូបង្រៀនចាំបាច់ត្រូវកសាងទំនាក់ទំនងជាមួយឪពុកម្ដាយ និងត្រូវជូនដំណឹងទៅឪពុកម្ដាយ ប្រសិនបើកូនរបស់ពួកគេអវត្តមានពីថ្នាក់រៀន។

### *៤.២.២. ការផ្គត់ផ្គង់ និងតម្រូវការរបស់គ្រូ*

ដូចត្រូវបានគូសបញ្ជាក់នៅក្នុងផ្នែកទី៣ ប្រទេសកម្ពុជាខ្វះគ្រូបង្រៀនបឋមសិក្សា ហើយឪពុកម្ដាយនៅក្នុងឃុំខ្នារសន្ដាយ (ខេត្តសៀមរាប) បានប្រាប់ឱ្យដឹងថាគ្រូបង្រៀនទាំងនៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យរមែងតែងត្រូវបង្រៀនលើសពីមួយថ្នាក់ក្នុងពេលដំណាលគ្នា ដោយពួកគេត្រូវចាប់ផ្ដើមបង្រៀន

សិស្សមួយថ្នាក់នៅក្នុងបន្ទប់មួយ បន្ទាប់មកពួកគេត្រូវចាកចេញទៅបង្រៀននៅបន្ទប់មួយទៀត។ ក្នុងខេត្តរតនគិរី គ្រូបង្រៀនបឋមសិក្សាចំនួន៥នាក់ក្នុងចំណោម១៤នាក់ ដែលត្រូវបានសម្ភាសន៍បានប្រាប់ឱ្យដឹងថាពួកគេបង្រៀនពីរវេន ហើយពីរនាក់ក្នុងចំណោមនោះ បង្រៀនសិស្សច្រើនថ្នាក់នៅវេនរសៀល។ ការធ្វើបែបនេះទំនងនឹងបង្កឱ្យប៉ះពាល់លទ្ធភាពរបស់ពួកគេក្នុងការពន្យល់ឱ្យបានសមស្រប ឬយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់។

សិស្សពីរក្រុមដែលធ្លាប់មានបទពិសោធន៍ រៀនជាមួយគ្រូកិច្ចសន្យាបាននិយាយឱ្យដឹងថា ជាទូទៅគ្រូកិច្ចសន្យាផ្តល់ការពន្យល់បានល្អ។ យ៉ាងណាមិញ សិស្សមួយក្រុមក៏បានប្រាប់ឱ្យដឹងផងដែរថា គ្រូបង្រៀនបានផឹកស្រាមុនពេលមកបង្រៀន និងជក់បារី ខណៈពេលដែលកំពុងបង្រៀន ព្រមទាំងឈប់បង្រៀនប្រសិនបើសិស្សធ្វើឱ្យពួកគាត់ខឹង។ សិស្សទាំងនោះមានអារម្មណ៍ថា គ្រូកិច្ចសន្យាអាចខ្វះការលើកទឹកចិត្តដោយសារតែពួកគេដឹងថាការងាររបស់ពួកគេគឺជាការងារបណ្តោះអាសន្ន។

គ្រូបង្រៀនម្នាក់នៅឯសាលាល្អក់ ខេត្តរតនគិរី បានប្រាប់ឱ្យដឹងថាគ្រូកិច្ចសន្យាចំនួន១០នាក់កំពុងត្រូវបានប្រើប្រាស់នៅក្នុងឃុំល្អក់ក្នុងនោះគ្រូកិច្ចសន្យាចំនួន៣នាក់បង្រៀននៅឯសាលាល្អក់។ នៅពេលសួរសំនួរអំពីការប្រើប្រាស់គ្រូបង្រៀនកិច្ចសន្យាពួកគេភាគច្រើនបាននិយាយថា ពួកគេមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការធ្វើការងារមកបង្រៀនទៀងទាត់ និងមានចំណេះដឹងមូលដ្ឋានគ្រប់គ្រាន់ដើម្បីបង្រៀន។ ជាទូទៅគ្រូបង្រៀនមានអារម្មណ៍វិជ្ជមានចំពោះគ្រូកិច្ចសន្យា អាស្រ័យដោយគ្រូកិច្ចសន្យាជួយបង្រៀនកុមារជាច្រើនដែលគេមិនអាចមានលទ្ធភាពចូលរៀនបាននៅក្នុងតំបន់មួយចំនួន។ បើទោះជាដូច្នេះក្តីគ្រូបង្រៀនមួយចំនួនបានលើកឡើងអំពីសមត្ថភាពមានកម្រិតរបស់គ្រូកិច្ចសន្យាក្នុងការរៀបចំកិច្ចតែងការ ដឹកនាំសកម្មភាពនៅក្នុងថ្នាក់រៀន និងកង្វះជំនាញគរុកោសល្យ។

### *៤.២.៣. សិស្សត្រូវទទួលខុសត្រូវសម្រាប់ការសិក្សារបស់ពួកគេ*

កត្តាដែលសិស្សបានលើកឡើងទូទៅបំផុតបន្ទាប់ដែលជះឥទ្ធិពលទៅលើគុណភាពអប់រំ គឺឆន្ទៈរបស់សិស្ស និងសមត្ថភាពរៀនសូត្ររបស់សិស្ស។ បន្ថែមពីលើចំណុចនេះ ក្រុមសិស្សចំនួន១២ក្រុម ក្នុងចំណោម២៤ក្រុមបានរៀបរាប់ឱ្យដឹងថា ការធ្វើកិច្ចការបន្ថែមនៅឯផ្ទះ គឺជាការសំខាន់ក្នុងនោះក្រុមសិស្សអនុវិទ្យាល័យមួយក្រុមថែមទាំងបានលើកឡើងទៀតថា ពួកគេចង់បានកិច្ចការសាលាដែលគ្រូដាក់ឱ្យធ្វើនៅឯផ្ទះចំនួន៣ដងក្នុងមួយសប្តាហ៍សម្រាប់មុខវិជ្ជានីមួយៗ។

ចំណុចនេះសង្កត់ធ្ងន់ទៅលើតួនាទីរបស់សិស្សនៅក្នុងការរៀនសូត្រផ្ទាល់ខ្លួនរបស់ពួកគេដែលស្របទៅនឹងការដែលសិស្សបានប្រាប់ឱ្យដឹងថា មូលហេតុទូទៅបំផុតដែលធ្វើឱ្យសិស្សរៀនមិនទាន់ គឺដោយសារតែឥរិយាបថទន់ខ្សោយរបស់សិស្ស។ បើទោះជាដូច្នេះក្តី ក្រុមសិស្សភាគច្រើនបាននិយាយថា សិស្សមានការប្តេជ្ញាចិត្តក្នុងការរៀនសូត្រ ហើយសិស្សចំនួន៦ក្រុមបានលើកឡើងថាការដែលសិស្សចេះជួយគ្នាទៅវិញទៅមក គឺជាកត្តារួមចំណែកមួយដ៏សំខាន់ចំពោះគុណភាពអប់រំ។

គួរចាប់អារម្មណ៍កត់សម្គាល់ថា សិស្សទំនងនឹងលើកឡើងអំពីឥរិយាបថរបស់សិស្សថាមានសារៈសំខាន់ជាងកិច្ចគាំទ្រពីឪពុកម្តាយ។ ចំណុចនេះផ្ទុយទៅនឹងការយល់ឃើញរបស់សិស្សអំពីតួនាទីរបស់ឪពុកម្តាយក្នុងការជួយសិស្សទៅសាលារៀន។ ចំណុចនេះទំនងជាសិស្សគិតថា កិច្ចគាំទ្ររបស់ឪពុកម្តាយមានសារៈសំខាន់ក្នុងការជួយកូនរបស់ពួកគេឱ្យទៅសាលារៀន ប៉ុន្តែឪពុកម្តាយទំនងជាមិនសូវមានផលប៉ះពាល់ទៅលើ គុណភាពអប់រំឡើយ។ ឪពុកម្តាយមួយចំនួនបានទទួលស្គាល់ថា ដើម្បីឱ្យកូនរៀនសូត្របានកាន់តែប្រសើរឪពុកម្តាយត្រូវអប់រំកូនឱ្យមានអាកប្បកិរិយាត្រឹមត្រូវជួយពន្យល់អំពីកិច្ចការសាលាដែលគ្រូដាក់ឱ្យពួកគេធ្វើ នៅផ្ទះ និងត្រួតពិនិត្យទៅលើដំណើរការរីកចម្រើនរបស់ពួកគេ តាមរយៈការប្រាស្រ័យទាក់ទងជាមួយគ្រូបង្រៀន។

### *៤.២.៤. សៀវភៅមេរៀន និងសម្ភារៈបង្រៀន*

ក្រុមសិស្សចំនួនពាក់កណ្តាលដែលបានកំណត់ថាសៀវភៅមេរៀន និងសម្ភារៈបង្រៀនមានសារៈសំខាន់សម្រាប់គុណភាពអប់រំបានប្រាប់ឱ្យដឹងថាខ្វះសម្ភារៈទាំងនេះ។ យ៉ាងណាមិញពុំមានក្រុមសិស្សណាមួយដែលបានលើកឡើងថា សម្ភារៈបង្រៀនគឺជាមូលហេតុដែលធ្វើឱ្យពួកគេទទួលបានគុណភាពអប់រំមួយដ៏ល្អ មធ្យម ឬ អន់ខ្សោយឡើយ។ បន្ថែមពីនេះទៀតពុំមានក្រុមសិស្សណាមួយបានប្រាប់ឱ្យដឹងថា សិស្សរៀនមិនទាន់ដោយសារតែខ្វះសៀវភៅមេរៀន ឬ សម្ភារៈបង្រៀននោះទេ។

### *៤.២.៥. ការផ្តល់តម្លៃចំពោះការអប់រំ*

តម្លៃនៃការអប់រំត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងកិច្ចពិភាក្សាក្រុមសហគមន៍ ដែលឪពុកម្តាយបានលើកឡើងអំពីការរំពឹងទុករបស់ពួកគេជាច្រើនចំពោះការអប់រំ។ ក្នុងនោះរួមមានការទទួលបានចំណេះវិជ្ជាដើម្បីឱ្យកូនរបស់ពួកគេអាចទទួលបានការងារមួយដ៏ល្អ និងដើម្បីឱ្យពួកគេអាចផ្គត់ផ្គង់ខ្លួនឯង និងគ្រួសាររបស់ពួកគេបាន។ សារៈសំខាន់របស់គ្រួសារ គឺជាប្រធានបទមួយដែលបានលើកឡើងនៅក្នុងមតិយោបល់ជាច្រើនដែលបានផ្តល់ជូន ដោយឪពុកម្តាយមានបំណងឱ្យកូនរបស់ពួកគេចេះគោរព និងយកចិត្តទុកដាក់ចំពោះគ្រួសារពួកគេ និងក្លាយជាអ្នកស្នងគ្រួសារ។ បើទោះជាដូច្នេះក្តី ឪពុកម្តាយភាគច្រើនយល់ថា ការអប់រំគឺជាច្រកដើម្បីទទួលបានការងារមួយដ៏ល្អ។

### *៤.២.៦. ការប្រព្រឹត្តមិនស្មើភាពគ្នាចំពោះសិស្ស*

ក្រុមឪពុកម្តាយចំនួន៦ក្រុម ក្នុងនោះ៣ក្រុមនៅខេត្តសៀមរាបបានប្រាប់ឱ្យដឹងថា កុមារគ្រប់រូបមិនបានទទួលការយកចិត្តទុកដាក់ស្មើភាពគ្នាឡើយ ដែលទង្វើបែបនេះអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើគុណភាពអប់រំដែលសិស្សទាំងនោះទទួលបាន។ ពួកគេបានប្រាប់ឱ្យដឹងថា គ្រូបង្រៀនមានភាពលម្អៀងចំពោះសិស្សដែលបានបង់ប្រាក់រៀនគួ ឬសិស្សដែលឪពុកម្តាយបានផ្តល់ប្រាក់ទៅឱ្យគ្រូបង្រៀនដើម្បីប្រឡងជាប់។ សិស្សមួយក្រុមបានប្រាប់ឱ្យដឹងថាគ្រូរបស់ពួកគេបានផ្តល់ពិន្ទុខ្ពស់ជាងយ៉ាងខ្លាំងទៅឱ្យសិស្ស ដែលរៀនគួជាមួយគ្រូ បើធៀបទៅនឹងសិស្សដែលមិនបានរៀនគួជាមួយគ្រូ បើទោះបីជាចម្លើយរបស់សិស្សនៅក្នុងការប្រឡងមានលក្ខណៈដូចគ្នាក៏ដោយ។ ថ្នាក់រៀនគួបន្ថែមមានតម្លៃ ៥០០ រៀល។ ឪពុកម្តាយមួយក្រុម

បានប្រាប់ឱ្យដឹងថា ឪពុកម្ដាយអាចបង់ប្រាក់៨០ដុល្លាដើម្បីឱ្យកូនរបស់ពួកគេឡើងថ្នាក់ទី៩ បើទោះបីជាកុមារនោះមិនបានទៅរៀន ឬ ប្រឡងមិនជាប់ក៏ដោយ។ ក្រុមមួយទៀតនៅខេត្តសៀមរាបបានពិភាក្សាអំពីរបៀបដែលគ្រូលក់ក្រដាសប្រឡង (៥០០រៀល)។

ការស្រាវជ្រាវកន្លងមក ដែលធ្វើឡើងដោយអង្គការ NEP បានរកឃើញថាសិស្សចំនួន ៣៣% បានរាយការណ៍ឱ្យដឹងថា ពួកគេបង់ប្រាក់សម្រាប់រៀនគួនៅក្នុងសាលារៀន[45]។ នោះគ្រាន់តែជាសិស្សមួយចំនួនតូចនៅក្នុងសាលារៀនដែលមានករណីបែបនេះ ហើយការបង់ប្រាក់បែបនេះ ទំនងនឹងមានតម្លៃជាមធ្យមប្រមាណ១២.៥០០រៀល ក្នុងមួយខែដែលគ្រួសារជាច្រើនពុំមានលទ្ធភាព។ ដូច្នេះ មានតែកុមារនៃគ្រួសារដែលមានទ្រព្យធនប៉ុណ្ណោះ ទើបអាចមានលទ្ធភាពបង់ប្រាក់ និងទទួលបានប្រយោជន៍ពីការរៀនគួបន្ថែមនេះ ដែលបង្ហាញឱ្យឃើញថាបានធ្វើឱ្យការរៀនសូត្ររបស់សិស្សមានភាពកាន់តែប្រសើរ[46]។

គ្រូបង្រៀនត្រូវបានអនុញ្ញាតឱ្យបង្រៀនគួបន្ថែម ហើយប្រសិនបើសិស្សមានឆន្ទៈក្នុងការចូលរៀនគួបន្ថែម ចំណុចនេះអាចត្រូវបានគេមើលឃើញថាជាការផ្ដល់តម្លៃចំពោះការអប់រំ។ បើទោះជាដូច្នេះក្ដី Brehm et al បានរកឃើញថា ថ្នាក់បង្រៀនគួបន្ថែមត្រូវបានប្រើប្រាស់ដើម្បីបន្តបង្រៀនកម្មវិធីសិក្សាជាតិ ដែលការបង្រៀននោះមិនត្រូវបានយកមកបង្រៀនឡើងវិញនៅក្នុងថ្នាក់រៀនឡើយ ប៉ុន្តែនេះ គ្រាន់តែជាការសិក្សាមួយទៅលើសាលារៀនចំនួន៦ប៉ុណ្ណោះ។ វាអាចជាមានសិស្សដែលមិនទទួលបានកម្មវិធីសិក្សាទាំងមូល ដោយសារតែពួកគេមិនអាចមានលទ្ធភាពបង់ប្រាក់សម្រាប់រៀនគួបន្ថែម។



ក្រុមពិភាក្សារបស់ឪពុកម្ដាយនៅស្រុកបន្ទាយស្រី ខេត្តសៀមរាប

[45]Ang, S. & Conochie, G. (2012). *ការលើកកម្ពស់សិទ្ធិនៅក្នុងសាលារៀន ភ្នំពេញ, អង្គការ* NEP

[46]Brehm, Silova and Mono (2012), *ការលាក់បាំងអំពីឯកជននីយកម្ម ទៅលើការអប់រំសាធារណៈក្នុងប្រទេសកម្ពុជា ៖ ផលប៉ះពាល់ និង អត្ថន័យនៃការបង្រៀនគួ* អង្គការ Open Society Foundations

## ៤.៣. ភាពបត់បែននៃការអប់រំ

នៅពេលពិនិត្យមើលទៅលើភាពបត់បែននៃសេវាអប់រំ កម្រិតអប់រំរបស់គ្រូបង្រៀន និងគុណភាពនៃការបណ្តុះបណ្តាលដែលគ្រូបង្រៀនបានទទួលគួរត្រូវបានយកមកពិចារណា។ គ្រូបង្រៀនបឋមសិក្សាត្រូវបង្រៀនគណិតវិទ្យា ភាសាខ្មែរ ចំណេះវិទ្យាសាស្ត្រ និងមុខវិជ្ជាសិក្សាសង្គម (ដែលបញ្ចូលជំនាញបំណិនជីវិតមួយផ្នែកផងដែរ) ខណៈពេលដែលការបណ្តុះបណ្តាលគរុកោសល្យ និងចំណេះដឹងលើមាតិកានៃមុខវិជ្ជាទាំងនេះអាចមានកម្រិត។ ចំណុចនេះធ្វើឱ្យគ្រូបង្រៀនកាន់តែមានការលំបាកក្នុងការដឹងអំពីវិធីសម្របការបង្រៀនរបស់ពួកគេលើមុខវិជ្ជាទាំងនេះ ដើម្បីឱ្យកុមារគ្រប់រូបអាចរៀនចេះ ជាពិសេសនៅពេលដែលគ្រូបង្រៀនជាច្រើនមិនបានទទួលការបណ្តុះបណ្តាលអំពីការអប់រំបញ្ចូលគ្នា។

### *៤.៣.១. ការបត់បែនការអប់រំទៅតាមសេចក្តីត្រូវការរបស់កុមារពិការ*

ក្រុមឪពុកម្តាយ និងក្រុមសិស្សបានប្រាប់ឱ្យដឹងថា មានក្រុមកុមារនៅក្នុងឃុំរបស់ពួកគេ ដែលអាចត្រូវការអន្តរាគមន៍ពិសេសដើម្បីទទួលបានការអប់រំ។ កុមារទាំងនោះរួមមាន កុមារគថ្លង់ កុមារពិការភ្នែក កុមារខ្សោយអវយវៈរាងកាយកុមារមានជម្ងឺឆ្កួតជ្រូក និងកុមារពិការសតិបញ្ញា។ បន្ថែមពីនេះទៀត ឪពុកម្តាយ និង សិស្សរមែងតែងបានលើកឡើងអំពី "កុមារដែលរៀនយឺត"។ ក្រុមឪពុកម្តាយភាគច្រើនបាន និយាយថា កុមារខ្សោយអវយវៈរាងកាយ កុមារដែលស្តាប់មិនសូវឮ ឬ "កុមារដែលរៀនយឺត" បានទៅសាលារៀន។ យ៉ាងណាមិញកុមារពិការភ្នែក កុមារគថ្លង់ កុមារមានជម្ងឺឆ្កួតជ្រូក ឬកុមារពិការសតិបញ្ញាមិនបានទៅសាលារៀនឡើយ។ បន្ថែមពីនេះទៀតសាលារៀនមិនបានផ្តល់កិច្ចគាំទ្រណាមួយដើម្បីឱ្យពួកគេអាចទៅរៀនបាន ឬជួយឪពុកម្តាយក្នុងការផ្តល់ការអប់រំដល់ពួកគេនៅឯផ្ទះឡើយ។

**ប្រអប់ទី៣ ៖ កុមារខ្សោយចក្ខុវិញ្ញាណចូលរៀននៅឯសាលាក្នុងខេត្តកំពត**

នាយកសាលាបឋមសិក្សាក្រុងកំពតបានរាយការណ៍ឱ្យដឹងថា មានសិស្ស១៥នាក់ ដែលខ្សោយចក្ខុវិញ្ញាណកំពុងរៀនថ្នាក់ទី២-ថ្នាក់ទី៦នៅក្នុងសាលារបស់គាត់។ សិស្សទាំងនេះបានប្រឡងជាប់ឡើងថ្នាក់ជារៀងរាល់ឆ្នាំ។ កាលពីឆ្នាំមុនសិស្ស៣នាក់ក្នុងចំណោមសិស្សទាំងនេះបានទទួលចំណាត់ថ្នាក់សិស្សពូកែចំនួន៥នាក់លើគេនៅក្នុងថ្នាក់របស់ពួកគេ។ ពួកគេនីមួយៗបានទទួលប័ណ្ណសរសេរពីសាលារៀនសម្រាប់ សមិទ្ធិផលរៀនសូត្ររបស់ពួកគេ។

នាយកសាលាបាននិយាយថា មិនចាំបាច់ត្រូវការឱ្យមានការផ្លាស់ប្តូរចម្បងៗដើម្បីបង្កលក្ខណៈឱ្យកុមារ ទាំងនេះចូលរៀននៅក្នុងថ្នាក់ជាមួយកុមារដទៃទៀតឡើយ។ កុមារទាំងនោះបានទទួលជំនួយមួយចំនួន ដូចជាវ៉ែនតា កែវពង្រីក ឬឧបករណ៍ដទៃទៀត ដើម្បីជួយឱ្យពួកគេមើលអត្ថបទបានកាន់តែច្បាស់។ សាលារៀនបានផ្តល់សៀវភៅមេរៀន និងឯកសារមេរៀនជាសំណៅបោះពុម្ពមួយដែលមានទំហំអក្សរធំៗ ហើយគ្រូបង្រៀនបានអនុញ្ញាតឱ្យពួកគេអង្គុយនៅតុជួរខាងមុខ។

នាយកសាលាមានអារម្មណ៍ថា កុមារដែលខ្សោយចក្ខុវិញ្ញាណត្រូវបានធ្វើសមាហរណកម្មយ៉ាងល្អប្រសើរនៅក្នុងថ្នាក់រៀនពួកគេមានមិត្តភក្តិល្អៗដែលពួកគេអាចធ្វើការនិងលេងជាមួយបាន ហើយឥឡូវនេះពួកគេកាន់តែមានទំនុកចិត្តលើខ្លួនឯង និងទទួលបានការលើកទឹកចិត្តនៅក្នុងការរៀនសូត្រ។ លើសពីនេះទៀតពុំមានសេចក្តីរាយការណ៍ណាមួយអំពីការរើសអើងទៅលើពួកគេឡើយ។

កុមារមួយចំនួនដែលខ្សោយអវយវៈរាងកាយខ្សោយចក្ខុវិញ្ញាណ ឬ"កុមារដែលរៀនយឺត" បានទទួលកិច្ចគាំទ្រមួយចំនួនពីសាលារៀន ដូចជាអាហារូបករណ៍ កង់ ឬ សម្ភារៈរៀនសូត្រ។ ជួនកាលគ្រូបង្រៀនបានគាំទ្រពួកគេ ដោយអនុញ្ញាតឱ្យពួកគេអង្គុយនៅតុជួរខាងមុខ ឬអង្គុយជាមួយសិស្សដែលរៀនពូកែ។ ក្រុមសិស្សមួយចំនួននៅខេត្តកំពតបាននិយាយថា គ្រូបង្រៀនមួយចំនួនផ្តល់ការពន្យល់បន្ថែមដល់សិស្សដែលរៀនយឺតព្រមទាំងលើកទឹកចិត្តឱ្យសិស្សជួយបង្រៀនគ្នាទៅវិញទៅមក ហើយក្រុមឪពុកម្តាយចំនួន៣ក្រុមបានប្រាប់ឱ្យដឹងថាសាលារៀន និងគ្រូបង្រៀនលើកទឹកចិត្តឱ្យសិស្សដែលរៀនយឺតឱ្យមករៀនទៀងទាត់ និងផ្តល់ថ្នាក់បំប៉នដើម្បីធ្វើឱ្យការអាន និងការសរសេររបស់ពួកគេមានភាពប្រសើរឡើង ក្នុងអំឡុងពេលវិស្សមកាល[47]។

យ៉ាងណាមិញគេបានរាយការណ៍ឱ្យដឹងថា កុមារថ្លង់ ឬពិការភ្នែកមិនបានទៅសាលារៀនឡើយ។ សិស្សបានផ្តល់មូលហេតុដូចខាងក្រោមសម្រាប់បញ្ហានេះ ៖ ១) ពួកគេមិនអាចទៅសាលារៀនបានដោយខ្លួនឯង ហើយឪពុកម្តាយរបស់ពួកគេមិនអាចជូនពួកគេទៅសាលារៀន ២)សាលារៀនពុំមានសម្ភារៈបរិក្ខារសម្រាប់កុមារប្រភេទនេះ និង ៣)គ្រូបង្រៀនមិនអាចផ្តល់កិច្ចគាំទ្រជូនដល់កុមារថ្លង់ ឬកុមារពិការភ្នែកបានដោយសារតែខ្វះសមត្ថភាព។ ជាទូទៅសាលារដ្ឋពុំមានសម្ភារៈបរិក្ខារ ឬឧបករណ៍ជាក់លាក់សម្រាប់កុមារពិការអវយវៈរាងកាយឡើយបើទោះបីជាសាលារៀនមួយចំនួនដែលបានចុះធ្វើទស្សនកិច្ចមានទីជម្រាល និងបង្គន់អនាម័យសម្រាប់កុមារពិការក៏ដោយ។

ក្រុមសិស្សចំនួន៤ក្រុម និងក្រុមឪពុកម្តាយចំនួន៤ក្រុមបានរាយការណ៍ឱ្យដឹងថា សាលារៀនមិនបានផ្តល់កិច្ចគាំទ្រណាមួយជូនដល់កុមារខ្សោយអវយវៈរាងកាយ ឬកុមារខ្សោយចក្ខុវិញ្ញាណឡើយ។ ពួកគេមានអារម្មណ៍ថា គ្រូបង្រៀនមិនអាចសម្របវិធីសាស្ត្របង្រៀនរបស់ខ្លួនទៅតាមសេចក្តីត្រូវការរបស់កុមារទាំងនេះបានឡើយ ហើយកុមារទាំងនេះទំនងនឹងឆាប់បោះបង់ការសិក្សានៅប្រមាណត្រឹមថ្នាក់ទី៤។ កុមារពិការសតិបញ្ញាដែលបានចូលរួមនៅក្នុងសិក្ខាសាលារបស់យើង ក៏បានប្រាប់ឱ្យដឹងផងដែរថា គ្រូបង្រៀនមិនយល់អំពីសេចក្តីត្រូវការរបស់ពួកគេ និងមិនអាចសម្របវិធីសាស្ត្របង្រៀនដើម្បីជួយដល់ពួកគេបានឡើយ។

[47]សាលារៀនអាចបើកថ្នាក់សិក្សានៅពេលវិស្សមកាល ចន្លោះពីខែសីហា ទៅខែតុលា ដែលថ្នាក់សិក្សាទាំងនេះ រមែងតែងមានការចូលរៀនពីសិស្សដែលមិនទំនងថានឹងអាចឡើងថ្នាក់បាន។ ជាក់ស្តែង ថ្នាក់សិក្សានេះ គឺជាផ្នែកមួយនៃកម្មវិធីចូលរៀនឡើងវិញ ដែលមានគោលបំណងជួយដល់កុមារដែលនៅក្រៅសាលារៀនឱ្យវិលត្រឡប់មកសាលារៀនវិញ ប៉ុន្តែភាគច្រើន ថ្នាក់សិក្សាទាំងនេះមានការចូលរៀនពីសិស្សដែលប្រឈមទៅនឹងការមិនបានឡើងថ្នាក់ប៉ុណ្ណោះ។

ក្រសួងអប់រំ យុវជន និងកីឡា មានគោលនយោបាយស្តីពីការអប់រំបញ្ចូលគ្នា ប៉ុន្តែ មានតែគ្រូបង្រៀនត្រូវបានសម្ភាសន៍ចំនួន១១នាក់ប៉ុណ្ណោះ ក្នុងចំណោម៨៤នាក់បានប្រាប់ឱ្យដឹងថា ពួកគេបានទទួលការបណ្តុះបណ្តាលអំពីការអប់រំបញ្ចូលគ្នា។ ពួកគេក៏បានសង្កត់ធ្ងន់ផងដែរថា ការបណ្តុះបណ្តាលមានរយៈពេលខ្លីខ្លាំងណាស់ ហើយខ្លឹមសារមានភាពស្មុគស្មាញ ដូច្នេះពួកគេមានការលំបាកក្នុងការចាប់យកខ្លឹមសារដែលបានបង្រៀន។ ពួកគេបានប្រាប់ឱ្យដឹងថាពួកគេមានបំណងចង់រៀនសូត្របន្ថែមទៀតអំពីមុខវិជ្ជានេះ។

**រូបភាពទី៨ ៖ ការបណ្តុះបណ្តាលគ្រូបង្រៀនអំពីការអប់រំបញ្ចូលគ្នា**




គ្រូបង្រៀនមកពីសាលាកម្រងមួយ (៦ ទៅ៨សាលារៀន) ជួបជុំគ្នារៀងរាល់ថ្ងៃព្រហស្បតិ៍នៃសប្តាហ៍ទី៤ក្នុងខែនីមួយៗ(កិច្ចប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍)។ កិច្ចប្រជុំបច្ចេកទេសនេះ អាចត្រូវបានយកមកប្រើប្រាស់ដើម្បីពិភាក្សាអំពីវិធីសាស្ត្របង្រៀនការអប់រំបញ្ចូលគ្នា ជាមួយគ្រូបង្រៀនដែលមានសិស្សពិការនៅក្នុងថ្នាក់របស់ពួកគេ។ មេរៀនបណ្តុះបណ្តាលមួយដែលត្រូវបានរៀបចំឡើងអំពីវិធីសាស្ត្របង្រៀនបញ្ចូលគ្នាអាចត្រូវបានបង្កើតឡើងដោយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ និងការិយាល័យអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់អនុវត្តជាក់លាក់នៅក្នុងកិច្ចប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍។

បន្ថែមពីនេះទៀតក្រសួងអប់រំ យុវជន និងកីឡា អាចបង្កើតមជ្ឈមណ្ឌលធនធានមួយនៅក្នុងគ្រប់ខេត្តទាំងអស់ដែលអាចផ្តល់ការបណ្តុះបណ្តាលជូនដល់គ្រូបង្រៀនដែលមានសិស្សពិការ ឬអាចផ្តល់ព័ត៌មាន និងដំបូន្មាន។ បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលពិសេស អាចចុះធ្វើទស្សនកិច្ចតាមសាលារៀនដើម្បីផ្តល់កិច្ចគាំទ្រ និងដំបូន្មាន ជូនដល់គ្រូបង្រៀនសិស្សពិការ។ សកម្មភាពបែបនេះ ត្រូវបានអនុវត្តនៅក្នុងបណ្តាប្រទេសដទៃទៀតផងដែរ ដូចជាប្រទេសអង់គ្លេស។ នាពេលថ្មីៗនេះក្រសួងអប់រំ យុវជន និងកីឡា និង

អង្គការគ្រួសារថ្មីបានចាប់ផ្តើមកម្មវិធីថ្មីមួយនៅក្នុងស្រុកចំនួន១២ដែលអង្គការគ្រួសារថ្មីធ្វើការងារក្រោមភាពជាដៃគូជាមួយការិយាល័យអប់រំស្រុកដោយសហការជិតស្និទ្ធជាមួយបុគ្គលិកម្នាក់ដែល នឹងទទួលបានការបណ្តុះបណ្តាលបន្ថែមទាក់ទងទៅនឹងការអប់រំសម្រាប់កុមារពិការ (ជាពិសេស កុមារខ្សោយចក្ខុវិញ្ញាណកុមារពិការភ្នែក និងកុមារថ្លង់)។ បុគ្គលិកអង្គការគ្រួសារថ្មីម្នាក់ នឹងចុះធ្វើទស្សនកិច្ចសាលារៀនជាមួយបុគ្គលិកការិយាល័យអប់រំស្រុករូបនេះដើម្បីផ្តល់កិច្ចគាំទ្រ និងក្រោយមកបុគ្គលិកការិយាល័យអប់រំស្រុក នឹងត្រូវធ្វើការងារនេះតែម្នាក់ឯង។

### *៤.៣.២. ឧបសគ្គនៃការអប់រំទៅតាមសេចក្តីត្រូវការរបស់ក្រុមជនជាតិដើមភាគតិច*

ឪពុកម្តាយមកពីក្រុមជនជាតិដើមភាគតិចមួយបានប្រាប់ឱ្យដឹងថា ជាញឹកញាប់ គ្រូបង្រៀនជនជាតិខ្មែរមិនចេះនិយាយភាសាមូលដ្ឋានឱ្យបានល្អគ្រប់គ្រាន់ ដើម្បីបង្រៀនកុមារជាភាសារបស់ពួកគេនោះឡើយ។ ដោយឡែក ប្រសិនបើការបង្រៀនត្រូវបានធ្វើឡើងជាភាសាខ្មែរ សិស្សដែលមកពីក្រុមជនជាតិដើមភាគតិចបាននិយាយថា ជួនកាលគ្រូបង្រៀនរបស់ពួកគេពន្យល់ ដោយប្រើប្រាស់ពាក្យពេចន៍ដែលសិស្សមិនយល់។ សិស្សបានប្រាប់ឱ្យដឹងថា កង្វះការយល់ដឹងពាក្យពេចន៍ជាភាសាខ្មែររបស់ពួកគេ បានធ្វើឱ្យសមត្ថភាពក្នុងការអាន និងធ្វើកិច្ចការសាលារបស់ពួកគេមានកម្រិត។ អង្គការមិនមែនរដ្ឋាភិបាលមួយដែលមានឈ្មោះថាអង្គការឃែរ បានប្រាប់ឱ្យដឹងថា ភាសាខ្មែរគឺជាភាសាមួយដែលពិបាករៀនខ្លាំងណាស់សម្រាប់អ្នកដែលមិនមែនជាអ្នកនិយាយភាសាកំណើត ហើយរួមផ្សំជាមួយនឹងកត្តាវប្បធម៌ បានធ្វើឱ្យវាក្លាយជាការលំបាកចម្បងមួយដែលសិស្សមកពីក្រុមជនជាតិដើមភាគតិចជួបប្រទះ នៅពេលដែលពួកគេព្យាយាមរៀនមុខវិជ្ជាផ្សេងៗគ្នា។

ការអប់រំពីរភាសាអាចដើរតួនាទីមួយដ៏សំខាន់ក្នុងការធានាថា កុមារជនជាតិដើមភាគតិចទទួលបានការអប់រំ[48] ហើយក្រសួងអប់រំ យុវជន និងកីឡា ដោយមានកិច្ចគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជាអង្គការឃែរ និងអង្គការសហប្រតិបត្តិការអន្តរជាតិនៅកម្ពុជាInternational Cooperation Cambodia កំពុងផ្តល់ការអប់រំពីរភាសានៅសាលាបឋមសិក្សា ៖

- ថ្នាក់ទី១ ៖ ពេលវេលាចំនួន ៨០% ជាភាសាក្នុងស្រុក និងពេលវេលាចំនួន ២០% ជាភាសាខ្មែរ
- ថ្នាក់ទី២ ៖ ពេលវេលាចំនួន ៦០% ជាភាសាក្នុងស្រុក និងពេលវេលាចំនួន ៤០% ជាភាសាខ្មែរ
- ថ្នាក់ទី៣ ៖ ពេលវេលាចំនួន ៣០% ជាភាសាក្នុងស្រុក និងពេលវេលាចំនួន ៧០% ជាភាសាខ្មែរ
- ចាប់ពីថ្នាក់ទី៤ឡើងទៅ ៖ ពេលវេលាចំនួន ១០០% ជាភាសាខ្មែរ។

ឪពុកម្តាយមួយចំនួនមានអារម្មណ៍ថា គ្រូបង្រៀនដែលមិនមែនជាជនជាតិដើមភាគតិចរបស់ពួកគេ ដូចជា គ្រូបង្រៀនជនជាតិខ្មែរមិនខ្វល់ថា តើសិស្សយល់អំពីការពន្យល់របស់ពួកគេឡើយ ដូច្នេះពួកគេមិនបានព្យាយាមសម្របបច្ចេកទេសបង្រៀនរបស់ពួកគេឡើយ។ ទាក់ទងទៅនឹងបញ្ហាវប្បធម៌ ឪពុកម្តាយជឿថា

[48] Klaus, D. (2003). *ការប្រើប្រាស់ភាសាជនជាតិដើមភាគតិចនៅក្នុងការអប់រំមូលដ្ឋានដំបូង នៅប្រទេស Papua New Guinea ។* Language and Education Journal, Vol 17, Issue 2.

គ្រូបង្រៀនជនជាតិខ្មែរមួយចំនួនមិនបានគោរពវប្បធម៌របស់ជនជាតិដើមភាគតិចឱ្យបានត្រឹមត្រូវនោះទេ។ អង្គការមិនមែនរដ្ឋាភិបាលបានប្រាប់ឱ្យដឹងថា វប្បធម៌ខ្មែរ និងវប្បធម៌របស់ជនជាតិដើមភាគតិចរមែងតែងអាចមានភាពខុសគ្នាខ្លាំងដែលនាំឱ្យមានការរំពឹងទុកខុសគ្នា និងឥរិយាបថខុសគ្នា។ ចំណុចនេះអាចបង្កឱ្យមានការលំបាករវាងគ្រូបង្រៀន និងសិស្ស។ បើទោះជាដូច្នេះក្ដី សិស្សបានប្រាប់ឱ្យដឹងថា ជួនកាលគ្រូបង្រៀនបានព្យាយាមប្រើប្រាស់ ឧទាហរណ៍ពីវប្បធម៌របស់ពួកគេដើម្បីជួយឱ្យពួកគេយល់មេរៀន ឬការអនុវត្តទូទៅនៅក្នុងវប្បធម៌ខ្មែរ។

ប្រយោជន៍នៃការអប់រំពីរភាសា គឺសិស្សក៏អាចរៀនភាសាខ្មែរបានផងដែរ ហើយឪពុកម្ដាយចំនួនពីរក្រុមក្នុងខេត្តរតនគិរីមានភាពរីករាយដែលកូនរបស់ពួកគេរៀនចេះអាន និងសរសេរភាសាខ្មែរ ដោយសារតែបានចូលរៀនការអប់រំពីរភាសា។ បច្ចុប្បន្នមានសាលារៀនពីរភាសាចំនួន ៥២ ចាប់ពីថ្នាក់ទី១រហូតដល់ថ្នាក់៣ ក្នុងខេត្តចំនួន៤ (ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ) ដែលមានសិស្សចំនួន ៤.១២៦ នាក់ និងគ្រូបង្រៀនចំនួន ២០៥ នាក់។ បើទោះជាដូច្នេះក្ដី គ្រូបង្រៀនទាំងនេះសុទ្ធសឹងតែជាគ្រូកិច្ចសន្យា ប៉ុន្តែពួកគេបានទទួលការបណ្ដុះបណ្ដាលយ៉ាងច្រើនពីអង្គការឃែរ។ អង្គការឃែរក៏បានផលិតសៀវភៅមេរៀនចំនួន៥ភាសាផ្សេងៗគ្នា ដែលអនុវត្តស្របតាមកម្មវិធីសិក្សាផ្លូវការ ហើយសៀវភៅមេរៀនទាំងនេះត្រូវបានប្រើប្រាស់នៅក្នុងសាលារៀនពីរភាសា។

បច្ចុប្បន្ន មានល័ក្ខខ័ណ្ឌមួយដែលកំណត់ថា មន្ត្រីរាជការស៊ីវិលអាចត្រូវបានជ្រើសរើសលុះត្រាតែពួកគេមានអាយុក្រោម២៥ឆ្នាំប៉ុណ្ណោះយ៉ាងណាមិញក៏មានករណីលើកលែងមួយចំនួនផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡា គួរពិចារណាផ្ដល់ការលើកលែងចំពោះគ្រូកិច្ចសន្យាដែលបង្រៀននៅឯសាលាពីរភាសាដើម្បីឱ្យពួកគេអាចក្លាយជាគ្រូបង្រៀនសាលារដ្ឋដែលត្រូវបានទទួលស្គាល់ជាផ្លូវការ។ ក្រសួងអប់រំ យុវជន និងកីឡា ក៏គួរពិចារណាលើកលែង ចំពោះល័ក្ខខ័ណ្ឌតម្រូវឱ្យទទួលបានការបណ្ដុះបណ្ដាលគរុកោសល្យរយៈពេល២ឆ្នាំមុនពេលកំណត់ថា មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើជាគ្រូបង្រៀន អាស្រ័យដោយវាអាចមានការ លំបាកសម្រាប់គ្រូពីរភាសាបច្ចុប្បន្នក្នុងការឈប់បង្រៀន និងរកប្រាក់ចំណូលរហូតដល់រយៈពេល ២ឆ្នាំ។ ប្រសិនបើគេតម្រូវឱ្យមានការបណ្ដុះបណ្ដាលបន្ថែម គេអាចធ្វើយ៉ាងដូច្នេះក្នុងអំឡុងពេលវិស្សមកាលក្នុងខែ សីហា និងខែកញ្ញា។

**ប្រអប់ទី៤ ៖ គ្រូបង្រៀនកិច្ចសន្យាសម្រាប់ការអប់រំពិសេស អាចក្លាយជាមន្ត្រីរាជការស៊ីវិលពេញសិទ្ធិ**

កន្លងមក គ្រូបង្រៀននៅក្នុងសាលារៀនគ្រួសារថ្មី បានបម្រើការងារ និងទទួលបានប្រាក់បៀវត្សរ៍ពីអង្គការគ្រួសារថ្មីប៉ុណ្ណោះ។ គ្រូបង្រៀនមួយចំនួនបានក្លាយជាគ្រូបង្រៀន ដែលទទួលបានវិញ្ញាបនបត្របញ្ជាក់រួចទៅហើយ ប៉ុន្តែពុំមែនគ្រូបង្រៀនគ្រប់រូបសុទ្ធសឹងតែទទួលបានវិញ្ញាបនបត្របញ្ជាក់នោះទេ។ បច្ចុប្បន្នគ្រូបង្រៀនទាំងនោះគ្រប់រូបបានទទួលឋានៈជាមន្ត្រីរាជការស៊ីវិល និងទទួលបានប្រាក់បៀវត្សរ៍មូលដ្ឋានរបស់ពួកគេពីក្រសួងអប់រំ យុវជន និងកីឡា។ ពួកគេបន្តទទួលបានប្រាក់ឧបត្ថម្ភបន្ថែមពីអង្គការគ្រួសារថ្មី។ នៅពេលដែលពួកគេត្រូវបានផ្ទេរទៅជាមន្ត្រីរាជការស៊ីវិល ពួកគេមិនចាំបាច់ត្រូវទៅសិក្សានៅឯមជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងវិក្រឹត្យការ ឬ ត្រូវប្រឡងអ្វីឡើយ។ ដោយសារតែបទពិសោធន៍ និងការបណ្ដុះបណ្ដាល

ជាក់លាក់ដែលពួកគេបានទទួលពីអង្គការ ជាពិសេសបានផ្តល់ជូនឱ្យពួកគេបានអាចក្លាយជាមន្រ្តីរាជការស៊ីវិល បើទោះបីជាពួកគេមានអាយុលើស២៥ឆ្នាំក៏ដោយ។ ករណីដូចគ្នានេះអាចអនុវត្តបានចំពោះគ្រូបង្រៀនដែលមានស្រាប់ចំនួន ២០៥នាក់ ដែលកំពុងបង្រៀននៅក្នុងសាលារៀនពីរភាសា។

តំបន់ដែលមានសមាមាត្រក្រុមជនជាតិដើមភាគតិចខ្ពស់ជាង ដូចជា នៅតំបន់ដាច់ស្រយាលនៃខេត្តរតនគិរី ក៏ជាតំបន់ដែលរងគ្រោះពីកង្វះគ្រូបង្រៀនផងដែរ។ បញ្ហានេះនាំឱ្យឈានទៅរកការប្រើប្រាស់គ្រូកិច្ចសន្យាដែលមិនធ្លាប់បានចូលរៀនវគ្គបណ្តុះបណ្តាលរយៈពេល២ឆ្នាំមុនពេលចូលបម្រើការងារ ដែលគ្រូនៅឯសាលារដ្ឋត្រូវធ្វើហើយពួកគេក៏មិនទំនងថានឹងទទួលបានការបណ្តុះបណ្តាលខណៈពេលកំពុងបម្រើការងារផងដែរ។ ឪពុកម្តាយមួយចំនួនជឿថា គ្រូបង្រៀនទាំងនេះមិនសូវមានលទ្ធភាពក្នុងការសម្របវិធីសាស្រ្តបង្រៀនរបស់ពួកគេ ទៅតាមសេចក្តីត្រូវការរបស់កុមារឡើយ។ អង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ បានផ្តល់អនុសាសន៍ថា រដ្ឋាភិបាលគួរកំណត់អាទិភាពលើការផ្តល់ការបណ្តុះបណ្តាលបន្ថែម ជូនដល់គ្រូកិច្ចសន្យា ដើម្បីឱ្យពួកគេអាចក្លាយជាគ្រូបង្រៀននៅឯសាលារដ្ឋ។ ពួកគេក៏បានគិតផងដែរថា រដ្ឋាភិបាលគួរខិតខំជ្រើសរើសគ្រូបង្រៀនពីក្រុមជនជាតិដើមភាគតិច ដែលយល់អំពីវប្បធម៌ និងភាសាក្នុងមូលដ្ឋាន។ នៅពេលដែលទីកន្លែងបម្រើការងាររបស់គរុសិស្សកំពុងត្រូវបានបែងចែក គេអាចបម្រុងទុកនូវកូតាមួយសម្រាប់គ្រូបង្រៀនពីរភាសា។ គ្រូបង្រៀនទាំងនេះអាចចូលរួមការបណ្តុះបណ្តាលប្រក្រតីរយៈពេល២ឆ្នាំ មុនពេលចូលបម្រើការងារ ជាមួយនឹងរយៈពេល២ខែបន្ថែមទៀតនៅចុងវគ្គបណ្តុះបណ្តាលដើម្បីផ្តោតលើការបង្រៀនជាភាសា ជនជាតិដើមភាគតិច។

### *៤.៣.៣. មាតិកាបង្រៀន និងកម្មវិធីសិក្សា*

ក្រុមឪពុកម្តាយ និងសិស្សព្រមទាំងគ្រូបង្រៀនភាគច្រើនបានប្រាប់ឱ្យដឹងថា មុខវិជ្ជាដែលមាននៅក្នុងកម្មវិធីសិក្សានាពេលបច្ចុប្បន្ន មានភាពពាក់ព័ន្ធទៅនឹងសេចក្តីត្រូវការរបស់កុមារ ដោយពួកគេបានលើកឡើងអំពីការដែលកុមារចេះអាន សរសេរ និងរាប់លេខ។ សិស្សបានប្រាប់ឱ្យដឹងថា មេរៀនជំនាញបំណិនជីវិតមានសារៈប្រយោជន៍ចំពោះជីវភាពប្រចាំថ្ងៃរបស់ពួកគេ ហើយសួនបន្លែអាចជួយសន្សំប្រាក់ពួកគេតាមរយៈការកាត់បន្ថយការទិញបន្លែពីទីផ្សារ។ ឪពុកម្តាយនៅក្រុងកំពតបាននិយាយថា ជំនាញដែលបានរៀនសូត្របានបង្កលក្ខណៈឱ្យកូនរបស់ពួកគេអាចជួយដល់អាជីវកម្មគ្រួសារបាន។ យ៉ាងណាមិញ សិស្សចំនួន ១០ក្រុមបានរាយការណ៍ឱ្យដឹងថា ពួកគេមិនបានរៀនសូត្រជំនាញណាមួយដែលមានប្រយោជន៍សម្រាប់ពួកគេ និងគ្រួសាររបស់ពួកគេនៅឡើយ ។ នេះគឺជាការព្រួយបារម្ភមួយសម្រាប់កុមារនៅសាលាអនុវិទ្យាល័យ ដោយឡែកសិស្សបឋមសិក្សាមានអារម្មណ៍ថា ពួកគេនៅក្មេងពេកក្នុងការរៀនជំនាញអ្វីមួយ។

ទាំងសិស្ស និងគ្រូបង្រៀនបានកំណត់រកឃើញមុខវិជ្ជាបន្ថែមដែលមានសារៈសំខាន់ចំពោះពួកគេ ដូចជាការរៀនប្រើប្រាស់កុំព្យូទ័រ និងភាសាបរទេសដទៃទៀត។ សិស្សនៅគ្រប់ខេត្តទាំងអស់បានរៀបរាប់ភាសាអង់គ្លេស និងភាសាបារាំងថាមានសារៈសំខាន់ ដោយឡែក នៅខេត្តសៀមរាប ពួកគេក៏បានរៀបរាប់អំពីភាសាកូរ៉េ និងភាសាចិនផងដែរ។ ចាប់ផ្តើមក្នុងឆ្នាំសិក្សា២០១៣-២០១៤ ភាសាអង់គ្លេសនឹងត្រូវបង្រៀនចាប់ពី

ថ្នាក់ទី៤ជំនួសឱ្យថ្នាក់ទី៧ យ៉ាងណាមិញ គ្រូបង្រៀនបឋមសិក្សាជាច្រើននឹងទាមទារឱ្យមានការបណ្តុះបណ្តាលដើម្បីឱ្យពួកគេអាចបង្រៀនមុខវិជ្ជានេះបាន។ ការបង្រៀនសិស្សអំពីវិធីប្រើកុំព្យូទ័រត្រូវបានរាំងស្ទះ ដោយសារកង្វះអគ្គិសនីនៅតាមសាលារៀនភាគច្រើន និងលទ្ធភាពរបស់គ្រូបង្រៀនក្នុងការប្រើប្រាស់កុំព្យូទ័រ។ បើទោះជាដូច្នេះក្តី គេពុំមានការសង្ស័យឡើយថា មុខវិជ្ជាទាំងនេះគឺជាមុខវិជ្ជាដែលសំខាន់ ជាពិសេសនៅពេលដែលគេពិចារណាទៅដល់សមាហរណកម្មអាស៊ានក្នុងឆ្នាំ២០១៥។ សិស្សអនុវិទ្យាល័យគ្រប់រូបបានបង្ហាញអំពីចំណាប់អារម្មណ៍ដ៏ខ្លាំងក្លាក្នុងការជ្រើសរើសយកជំនាញមួយ ដែលជួយឱ្យពួកគេអាចបង្កើតប្រាក់ចំណូលបាន។ ជាទូទៅ ពួកគេចាប់អារម្មណ៍លើវិស័យកសិកម្ម ជាងម៉ាស៊ីន ជាងជួសជុលគ្រឿងអេឡិចត្រូនិក ជាងជួសជុលទូរស័ព្ទ ជំនាញកាត់ដេរ និងជំនាញកែសម្ផស្ស។ អ្វីដែលគួរឱ្យព្រួយបារម្ភនោះ គឺពុំមានក្រុមសិស្សណាមួយមានអារម្មណ៍ថាពួកគេអាចស្នើ ប្រធានបទដែលពួកគេចង់រៀនពីគ្រូបង្រៀនរបស់ពួកគេបានឡើយ អាស្រ័យដោយពួកគេមានអារម្មណ៍ថា ពួកគេពុំមានសិទ្ធិក្នុងការធ្វើយ៉ាងដូច្នេះនោះទេ។

គ្រូបង្រៀនបាននិយាយថា ពួកគេបានខិតខំសម្របការបង្រៀនរបស់ពួកគេទៅតាមសេចក្តីត្រូវការរបស់សិស្ស ប៉ុន្តែជាក់ស្តែង ការសម្របបច្ចេកទេសបង្រៀនត្រូវបានរាំងស្ទះ ដោយសារសមត្ថភាពរបស់ពួកគេ និង ធនធានដែលមាន។ ឧទាហរណ៍ គ្រូបង្រៀនអាចមានលទ្ធភាពបញ្ចូលជំនាញបំណិនជីវិតមូលដ្ឋានមួយចំនួនដូចជាសុខភាព និងការអប់រំអនាម័យ ព្រមទាំងសួនបន្លែប៉ុណ្ណោះ។ មានតែគ្រូបង្រៀនបឋមសិក្សាចំនួន ៩នាក់ ក្នុងចំណោម ៤៤នាក់ ប៉ុណ្ណោះដែលត្រូវបានសម្ភាសន៍ បានប្រាប់ឱ្យដឹងថា ពួកគេបានជ្រើសរើសជំនាញបំណិនជីវិត ដោយផ្អែកទៅលើសេចក្តីត្រូវការរបស់សហគមន៍ ដោយឡែក គ្រូបង្រៀនបឋមសិក្សាចំនួន២៦នាក់ បាននិយាយថា ពួកគេបង្រៀនតាមកម្មវិធីសិក្សានៅក្នុងសៀវភៅមេរៀន។ គ្រូបង្រៀនចំនួន ៥នាក់ទៀតបាននិយាយថា ពួកគេប្រើប្រាស់ថ្នាក់រៀនដើម្បីផ្តោតយកចិត្តទុកដាក់លើភាសាខ្មែរ ដោយឡែកគ្រូបង្រៀនដែលនៅសេសសល់ចំនួន៤នាក់ទៀតបាននិយាយថា ពួកគេមិនបានបង្រៀនមេរៀនបំណិនជីវិតអ្វីឡើយ។

**រូបភាពទី៩ ៖ ការជ្រើសរើសប្រធានបទជំនាញបំណិនជីវិត**



បើទោះបីជាកម្មវិធីជំនាញបំណិនជីវិត ត្រូវបានធ្វើសមាហរណកម្មទៅក្នុងកម្មវិធីសិក្សានៅឯសាលារៀនជាផ្លូវការក៏ដោយ ប៉ុន្តែកម្មវិធីនេះមិនទំនងនឹងបានផ្តល់ជំនាញជាក់លាក់ណាមួយ ទៅឱ្យសិស្សដែលអាចយកមកប្រើប្រាស់ដើម្បីជួយឱ្យពួកគេអាចចូលទៅក្នុងទីផ្សារការងារបានឡើយ។ សិស្សនៅតំបន់ទីក្រុង ទំនងនឹងមានលទ្ធភាពប្រសើរជាងក្នុងការទទួលបានកម្មវិធីអភិវឌ្ឍន៍ជំនាញ បើធៀបទៅនឹងសិស្សនៅតំបន់សហគមន៍ជនបទ ដែលមានឱកាសតិចតួច។ ជាទូទៅ នៅតំបន់ទីក្រុងឱកាសទាំងនេះ ត្រូវបានរៀបចំដោយទីភ្នាក់ងារឯកជន និងអង្គការដែលមិនស្វែងរកប្រាក់ចំណេញ។

ក្រសួងអប់រំ យុវជន និងកីឡា បានរាយការណ៍ឱ្យដឹងថា មានមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលសកម្មចំនួន៣២៣ ទូទាំងប្រទេស និងមានសិស្សចំនួន ១០.៨៩៣នាក់ (៥៨% ជាកុមារី) ចូលរួមនៅក្នុងសកម្មភាពរបស់មជ្ឈមណ្ឌលទាំងនេះ[49]។ ការសិក្សានេះបានរកឃើញថា មានវត្តមានមជ្ឈមណ្ឌលសិក្សាមួយនៅក្នុងឃុំភាគច្រើនដែលយើងបានចុះធ្វើទស្សនកិច្ច ប៉ុន្តែមជ្ឈមណ្ឌលទាំងនោះហាក់បីដូចជាផ្តល់ប្រយោជន៍តិចតួចចំពោះយុវជន និងកុមារនៅក្រៅសាលារៀន។ មជ្ឈមណ្ឌលសិក្សាទាំងនេះ ពុំមានភាពសកម្មឡើយ ហើយប្រជាពលរដ្ឋភាគច្រើនដែលត្រូវបានសម្ភាសន៍រាប់បញ្ចូលទាំងគ្រូបង្រៀនមិនបានដឹង និងមិនធ្លាប់បានប្រើប្រាស់មជ្ឈមណ្ឌលទាំងនេះឡើយ។ នៅក្នុងខេត្តកំពតសមាជិកសហគមន៍បានរៀបរាប់ឱ្យដឹងថា មជ្ឈមណ្ឌលផ្តល់ប្រយោជន៍ ចំពោះតែមនុស្សមួយចំនួនតូចប៉ុណ្ណោះ ប៉ុន្តែវាមិនបានផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រដែលពុំមានសក្តានុពលក្នុងការបង្កើតអាជីវកម្មណាមួយ ក្រោយពេលបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈឡើយ។ បន្ថែមពីនេះទៀតពួកគេបានរៀបរាប់ឱ្យដឹងទៀតថា មជ្ឈមណ្ឌលផ្តល់ការបណ្តុះបណ្តាលជំនាញអំពីតន្ត្រីប្រពៃណីដែលមិនបានជួយដល់ការរកប្រាក់ឡើយ។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### ៥.១. សេចក្តីសន្និដ្ឋាន

#### ៥.១.១.វត្តមាន និងលទ្ធភាពទទួលបានសេវា

បុគ្គលស្ទើរតែគ្រប់រូបដែលយើងបានជួបនិយាយជាមួយមានអារម្មណ៍ថា ការចូលរៀននៅពេលនេះមានភាពងាយស្រួលជាងកាលពី៥ឆ្នាំមុន ហើយបុគ្គលទាំងនោះរួមមានកុមារពិការ និងឪពុកម្តាយរបស់ពួកគេ និងក្រុមជនជាតិដើមភាគតិច។ ចំណុចនេះ ឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពជាក់ស្តែងដែលសម្រេចបានក្នុងប្រទេសកម្ពុជា ជាពិសេស នៅក្នុងការអប់រំកម្រិតបឋមសិក្សា និងមិនគួរត្រូវបានបំភ្លេចនៅក្នុងការពិភាក្សាអំពីបញ្ហាប្រឈមដែលនៅសេសសល់ឡើយ។ ជាញឹកញាប់ឪពុកម្តាយបានពន្យល់ថា ការរីកចម្រើនទាំងនេះបណ្តាលមកពីការមានសាលារៀន និងគ្រូបង្រៀនច្រើនជាងមុន ប៉ុន្តែពួកគេមិនសូវបានផ្តោតទៅលើការដែលមានផ្លូវថ្នល់ល្អជាងមុនឡើយ។ ឪពុកម្តាយក្នុងខេត្តកំពតក៏បានផ្តោតសារៈសំខាន់ខ្លាំងទៅលើការដែលឪពុកម្តាយខិតខំលើកទឹកចិត្តកូនឱ្យទៅសាលារៀនផងដែរ ដោយឡែកឪពុកម្តាយក្នុងខេត្តរតនគិរី រមែងតែង

---

[49] តួលេខទាំងនេះត្រូវបានដកស្រង់ចេញពីបទបង្ហាញមួយដែលធ្វើឡើងដោយ ឯកឧត្តម ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ នៅឯសន្និបាតអប់រំ។

ប្រាប់ឱ្យដឹងថា កុមារចង់រៀនសូត្រច្រើនជាងមុន ជាពិសេស ពួកគេបានលើកឡើងអំពីការដែលកុមារជនជាតិដើមភាគតិចចង់រៀនភាសាខ្មែរ។ ឪពុកម្តាយបាននិយាយថា ការចុះឈ្មោះចូលរៀននៅឯសាលា គឺជាដំណើរការមួយដ៏សាមញ្ញ អាស្រ័យដោយគេត្រូវការតែសំបុត្រកំណើត ឬសៀវភៅគ្រួសារប៉ុណ្ណោះ និង ពុំមានការបង់ប្រាក់អ្វីឡើយ។ គួរកត់សម្គាល់ផងដែរថា ការសិក្សានេះត្រូវបានធ្វើឡើងភាគច្រើននៅតំបន់ជនបទ និងតំបន់ជាយក្រុងប៉ុណ្ណោះ ហើយស្ថានភាពអាចខុសគ្នានៅរាជធានីភ្នំពេញ ឬ តំបន់ទីក្រុងដទៃទៀត។

មូលហេតុទូទៅបំផុតដែលកុមារបានផ្តល់ជូន អំពីការបោះបង់ការសិក្សា គឺបណ្តាលមកពីភាពក្រីក្រ ដែលធ្វើឱ្យពួកគេគ្មានលទ្ធភាពក្នុងការទិញកង់ និងសម្ភារៈរៀនសូត្រ សម្រាប់បង្កលក្ខណៈឱ្យពួកគេអាចទៅរៀនបាន។ ពួកគេក៏ទំនងនឹងជ្រើសរើសឈប់រៀនដើម្បីថែទាំបងប្អូន ធ្វើការងារជាមួយឪពុកម្តាយរបស់ពួកគេ ឬ ស្វែងរកការងារធ្វើ។ សិស្សក៏បានយល់ឃើញផងដែរថា ទាំងនេះគឺជាមូលហេតុចម្បងដែលធ្វើឱ្យពួកគេបោះបង់ការសិក្សា ប៉ុន្តែ ឪពុកម្តាយមិនសូវផ្តោតទៅលើចំណុចនេះខ្លាំងប៉ុន្មានទេ។ គួរកត់សម្គាល់ថា កុមារភាគច្រើនដែលបោះបង់ការសិក្សា បានចាប់ផ្តើមចូលរៀនថ្នាក់ទី១ នៅពេលដែលពួកគេមានអាយុលើស ៦ឆ្នាំ។ កុមារចំនួន១២នាក់ ក្នុងចំណោម១៤នាក់ ដែលយើងបានសម្ភាសន៍ និងដែលបានបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យ មានអាយុចន្លោះពី១៦ឆ្នាំ ទៅ ១៩ឆ្នាំ នៅពេលដែលពួកគេបោះបង់ការសិក្សា។ កុមារស្ទើរតែពាក់កណ្តាលដែលបោះបង់ការសិក្សាក្នុងកម្រិតបឋមសិក្សាមានអាយុ១៤-១៦ឆ្នាំ។ ស្ថិតក្នុងអាយុនេះពួកគេអាចចាប់ផ្តើមរកប្រាក់ចំណូលបាន។ វាមានសារៈ សំខាន់ដែលក្រសួងអប់រំ យុវជន និងកីឡាគប្បីដោះស្រាយបញ្ហាចូលរៀនយឺតរបស់កុមារ។

ជាក់ស្តែងពុំមែនតែឱកាសក្នុងការរកប្រាក់ប៉ុណ្ណោះទេ ដែលបណ្តាលឱ្យកុមារក្រីក្រមួយចំនួនបោះបង់ការសិក្សា ប៉ុន្តែការទៅសាលារៀនក៏មានថ្លៃចំណាយមួយចំនួនដែលធ្វើឱ្យពួកគេមានការលំបាកផងដែរ។ ប្រជាពលរដ្ឋបន្តធ្វើការបែងចែកភាពខុសគ្នារវាងភាពក្រីក្រ និងការដែលត្រូវការប្រាក់សម្រាប់ចំណាយនៅ ឯសាលារៀន។ ថ្លៃចំណាយនៃការទៅសាលារៀនដែលបង្កឱ្យមានការលំបាកបំផុត គឺការទិញសម្ភារៈរៀនសូត្រ និងមធ្យោបាយធ្វើដំណើរ ដូចជាកង់ជាដើមដែលគ្រប់ក្រុមទាំងអស់បានលើកឡើងដដែលៗថា ជាមូលហេតុនៃការបោះបង់ការសិក្សា ឬការមិនបានទៅរៀនទៀងទាត់។

ក្រសួងអប់រំ យុវជន និងកីឡា គួរបន្តគោលនយោបាយរបស់ខ្លួនក្នុងការពង្រីកកម្មវិធីអាហារូបករណ៍ អាស្រ័យដោយវាមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ទៅលើអត្រាបោះបង់ការសិក្សានៅថ្នាក់ទី៧ និង ថ្នាក់ទី៨ និងនៅកម្រិតបឋមសិក្សា។ ក្នុងឆ្នាំសិក្សា២០១២-២០១៣ កម្មវិធីស្បៀងអាហារពិភពលោកបានផ្តល់អាហារូបករណ៍ជាសាច់ប្រាក់ចំនួន ៩.០០០នាក់ (៥០ដុល្លាក្នុងមួយឆ្នាំ) ជូនដល់កុមារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាកុមារដែលក្រីក្របំផុតនៅក្នុងឃុំរបស់ពួកគេ។ អត្រាបោះបង់ការសិក្សាសម្រាប់កម្មវិធីអាហារូបករណ៍ជាសាច់ប្រាក់ មានចំនួន ២,៣៧% ដែលមានកម្រិតទាបជាងអត្រាបោះបង់ការសិក្សាទូទាំងប្រទេស បើទោះបីជាកុមារទាំងនេះ ស្ថិតនៅក្នុងចំណោមក្រុមកុមារដែលគេរំពឹងថាមានអត្រាបោះបង់ការសិក្សាខ្ពស់ជាងអត្រាបោះបង់ការសិក្សាជាមធ្យមក៏ដោយ។ នៅក្នុងការត្រួតពិនិត្យមួយទៅលើសិស្សអាហារូបករណ៍មួយចំនួនបានឱ្យដឹងថា កុមារនីមួយៗបានប្រើប្រាស់ប្រាក់អាហារូបករណ៍ដើម្បីទិញសម្ភារៈរៀនសូត្រ ដែលបង្ហាញឱ្យឃើញថាមានសេចក្តីត្រូវការសម្ភារៈរៀនសូត្រ។

ឪពុកម្ដាយ និងកុមារនៅគ្រប់ខេត្តទាំងអស់បានលើកឡើងថា រយៈចម្ងាយពីផ្ទះទៅសាលារៀន និងកង្វះមធ្យោបាយធ្វើដំណើរ គឺជាការលំបាកមួយដ៏ធំដែលរារាំងកុមារមិនឱ្យទៅរៀនបានទៀងទាត់ ជាពិសេសគឺកុមារដែលកំពុងសិក្សានៅកម្រិតអនុវិទ្យាល័យ។ ឃុំមួយចំនួនពុំមានសាលាអនុវិទ្យាល័យឡើយ ប៉ុន្តែឃុំទាំងនោះអាចមានសាលាបឋមសិក្សាច្រើន។ សាលាអនុវិទ្យាល័យមួយចំនួនក្នុងខេត្តរតនគិរី បានបង្កើតអន្តេវាសិកដ្ឋានសម្រាប់សិស្សក្រីក្រ ដែលកត្តានេះ បានដោះស្រាយបញ្ហាការធ្វើដំណើរទៅសាលារៀន។ ដើម្បីដោះស្រាយបញ្ហាសិស្សដែលមានផ្ទះនៅឆ្ងាយពីសាលារៀន គេពុំមែងតែងតែត្រូវសាងសង់សាលារៀនថ្មីនោះទេ។ ក្រសួងអប់រំ យុវជន និងកីឡា ក៏អាចពិចារណាផ្ដល់មធ្យោបាយធ្វើដំណើរ ឬអន្តេវាសិកដ្ឋានផងដែរ។

បើទោះបីជាកុមារច្រើនជាងមុនបានចូលរៀនក៏ដោយ ប៉ុន្តែក្រុមកុមារជាក់លាក់មួយចំនួនដូចជាកុមារពិការរាងកាយ កុមារពិការសោតវិញ្ញាណ ឬកុមារពិការសតិបញ្ញាមានឱកាសតិចតួចក្នុងការចូលរៀន ឬទំនងនឹងបោះបង់ការសិក្សា។ នៅក្នុងរបាយការណ៍នេះយើងបានគូសបញ្ជាក់អំពីស្ថានភាពកុមារពិការ និងកុមារក្រុមជនជាតិដើមភាគតិច។ យើងឃើញថាប្រសិនបើពុំមានកិច្ចគាំទ្រគួរឱ្យកត់សម្គាល់ពីអង្គការមិនមែនរដ្ឋាភិបាលទេនោះលទ្ធភាពក្នុងការទៅសាលារៀនរបស់ពួកគេនឹងត្រូវមានកម្រិត។ ឧទាហរណ៍ សៀវភៅមេរៀនសម្រាប់កុមារពិការភ្នែក និងកុមារដែលនិយាយភាសាដោយឡែកត្រូវបានផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាជាងដោយក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើសមាហរណកម្មគ្រូបង្រៀនសាលាសម្រាប់កុមារថ្លង់និងកុមារពិការភ្នែក ទៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលប្រកបដោយជោគជ័យប៉ុន្តែ ក្រសួងមិនទាន់បានធ្វើយ៉ាងដូច្នេះជាមួយគ្រូបង្រៀនសាលាពីរភាសានៅឡើយទេដែលមានន័យថាពួកគេគ្រាន់តែជាគ្រូកិច្ចសន្យាប៉ុណ្ណោះ។ ការប្ដូរពួកគេឱ្យក្លាយទៅជាមន្ត្រីរាជការស៊ីវិលពេញសិទ្ធិគួរតែជាអាទិភាពមួយសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ហើយអាទិភាពរបស់ក្រសួងក៏គួរផ្ដោតលើការទទួលខុសត្រូវផលិតសៀវភៅមេរៀនផ្សេងៗគ្នាផងដែរ។

អវត្តមាននៅឯសាលារៀន ពុំមែនសំដៅចំពោះតែកុមារដែលមានកំសោយអវយវៈជាក់លាក់ណាមួយ ឬ កុមារដែលមានកម្រិតចំពោះសកម្មភាពណាមួយឡើយ។ ជាក់ស្ដែង គេត្រូវបង្កើនការយកចិត្តទុកដាក់ដោះស្រាយឧបសគ្គដែលរាំងស្ទះចំពោះការទៅសាលារៀន សម្រាប់កុមារពិការជាច្រើនដែលមិនទាន់ទទួលបានការបញ្ជ្រាបឱ្យបានគ្រប់គ្រាន់។ បន្ថែមពីនេះទៀត ប្រសិនបើមានសេវាអប់រំពិសេសសម្រាប់អនុក្រុមកុមារដែលមានពិការភាពស្មុគស្មាញ ឬ ធ្ងន់ធ្ងរ សេវាទាំងនោះមានចំពោះតែតំបន់ភូមិសាស្ត្រជាក់លាក់មួយចំនួនប៉ុណ្ណោះ និងត្រូវធ្វើការពង្រីកបន្ថែម។



## ៥.១.២. ភាពអាចទទួលយកបាន

ឪពុកម្តាយ និងសិស្សភាគច្រើនពេញចិត្តទៅនឹងគុណភាពអប់រំ។ យ៉ាងណាមិញ កម្រិតនៃភាពពេញចិត្តត្រូវយកមកពិចារណាធៀបទៅនឹងកម្រិតនៃការរំពឹងទុក។ ប្រសិនបើការរំពឹងទុកទៅលើគុណភាពមានកម្រិតទាបខ្លាំង ពេលនោះគេមិនចាំបាច់តម្រូវឱ្យប្រជាពលរដ្ឋមានការពេញចិត្តទៅនឹងគុណភាពអប់រំមួយដែលល្អខ្លាំងឡើយ។ នេះអាចជាការពន្យល់មួយផ្នែកអំពីការពេញចិត្តដែលត្រូវបានរាយការណ៍ថាមានកម្រិតខ្ពស់យ៉ាងដូច្នេះ អាស្រ័យដោយសិស្សចំនួន២ក្រុមនៅសាលាជនបទខេត្តរតនគិរី មានអារម្មណ៍ថាពួកគេពេញចិត្ត ចំពោះគុណភាពអប់រំដោយសារតែពួកគេអាចអាន និងសរសេរបានដែលចំណុចនេះបង្ហាញអំពីការរំពឹងទុកដែលមានកម្រិតទាប។ ស្រដៀងគ្នានេះដែរកុមារស្ទើរគ្រប់រូបដែលត្រូវបានសម្ភាសន៍ និងដែល

បានបោះបង់ការសិក្សាមុនថ្នាក់ទី៩គិតថា ការអប់រំដែលពួកគេបានទទួលមានគុណភាពល្អ។ បើទោះជាដូច្នេះក្តីកុមារចំនួនពាក់កណ្តាលប៉ុណ្ណោះបាននិយាយថាពួកគេចេះលេខនព្វន្ត។ យើងឃើញថាការរំពឹងទុកគឺត្រឹមតែចេះអាន និងសរសេរប៉ុណ្ណោះ។

កុមារដែលយើងបានជួបនិយាយជាមួយ និងដែលបានបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យមិនអាចស្វែងរកការងារដែលពួកគេចង់ធ្វើបានឡើយ អាស្រ័យដោយមានគម្លាតមួយដ៏ធំរវាងជំនាញដែលគេត្រូវការនិងជំនាញដែលពួកគេមាន។ កុមារភាគច្រើនដែលបានបោះបង់ការសិក្សាក្នុងកម្រិតបឋមសិក្សាមិនដឹងថាពួកគេចង់ធ្វើការងារអ្វីឡើយ ហើយពួកគេធ្វើតែការងារហត្ថកម្មនិងជួយការងារគ្រួសារ។

សិស្ស និងឪពុកម្តាយស្ទើរតែគ្រប់ក្រុមបានប្រាប់ឱ្យដឹងថាគ្រូបង្រៀនដ៏ល្អ គឺជាកត្តាដ៏សំខាន់ដែលធ្វើឱ្យមានគុណភាពអប់រំល្អ ហើយក្រុមសិស្ស និងឪពុកម្តាយភាគច្រើន រាប់បញ្ចូលទាំងនៅតំបន់ជនបទផងដែរ បានរាយការណ៍ឱ្យដឹងថា ពួកគេពេញចិត្តទៅ នឹងគុណភាពគ្រូបង្រៀននៅក្នុងឃុំរបស់ពួកគេផ្សេងៗគ្នា។ ប្រសិនបើសិស្សឬឪពុកម្តាយមិនពេញចិត្តទៅនឹងគ្រូបង្រៀន វាទំនងនឹងទាក់ទងទៅនឹងឥរិយាបថរបស់គ្រូបង្រៀនចំពោះបញ្ហាអវត្តមានឬការប្រមូលប្រាក់។ ឪពុកម្តាយបានប្រាប់ឱ្យដឹងថាគ្រូបង្រៀនមានភាពលម្អៀងចំពោះកុមារដែលបង់ប្រាក់រៀនគួឬកុមារដែលឪពុកម្តាយរបស់ពួកគេបានផ្តល់ប្រាក់ទៅឱ្យគ្រូបង្រៀនដើម្បីប្រឡងជាប់។ សិស្សក៏បានប្រាប់ឱ្យដឹងផងដែរថា គ្រូរបស់ពួកគេបានផ្តល់ពិន្ទុខ្ពស់ជាងយ៉ាងខ្លាំងទៅឱ្យសិស្សដែលរៀនគួជាមួយគ្រូ បើធៀបទៅនឹងសិស្សដែលមិនបានរៀនគួជាមួយគ្រូ បើទោះបីជាចម្លើយរបស់ពួកគេនៅក្នុងការប្រឡងមានលក្ខណៈដូចគ្នាក៏ដោយ។

គេបានរាយការណ៍ឱ្យដឹងអំពីបញ្ហាកង្វះគ្រូបង្រៀន ជាពិសេសនៅខេត្តសៀមរាប និងខេត្តរតនគិរី។ នៅខេត្តសៀមរាប គ្រូបង្រៀនទាំងនៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ រមែងតែងតែត្រូវបង្រៀនលើសពីមួយថ្នាក់ស្របពេលដំណាលគ្នា។ ពួកគេចាប់ផ្តើមបង្រៀនសិស្សមួយថ្នាក់នៅក្នុងបន្ទប់រៀនមួយបន្ទាប់មកពួកគេត្រូវចាកចេញទៅបង្រៀនមួយថ្នាក់ទៀត។ នៅខេត្តរតនគិរី គ្រូបង្រៀនបឋមសិក្សាចំនួន៥នាក់ក្នុងចំណោម១៤នាក់បង្រៀនពីរវេន ក្នុងនោះមាន២នាក់បង្រៀនច្រើនកម្រិតផ្សេងៗគ្នានៅវេណរសៀល។ កត្តាទាំងនេះទំនងនឹងបង្កឱ្យមានផលប៉ះពាល់ទៅលើលទ្ធភាពរបស់ពួកគេ ក្នុងការពន្យល់ឱ្យបានសមស្របឬយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់។ បន្ថែមពីនេះទៀតមានការប្រើប្រាស់គ្រូបង្រៀនជាច្រើនដែលមិនបានទទួលការបណ្តុះបណ្តាលក្នុងខេត្តរតនគិរី។

បន្ទាប់ពីកត្តាគ្រូបង្រៀនឆន្ទៈរៀនសូត្ររបស់សិស្ស គឺជាកត្តាដែលត្រូវបានលើកឡើងទូទៅបំផុតដែលជះឥទ្ធិពលទៅលើគុណភាពអប់រំ។ សិស្សមួយចំនួនថែមទាំងបានប្រាប់ឱ្យដឹងទៀតថា ពួកគេចង់បានកិច្ចការសាលាដាក់ឱ្យធ្វើនៅផ្ទះចំនួន៣ដងក្នុងមួយសប្តាហ៍។ គួរចាប់អារម្មណ៍កត់សម្គាល់ថា សិស្សគិតថាកិច្ចគាំទ្រពីឪពុកម្តាយមានសារៈសំខាន់ក្នុងការជួយកូនឱ្យទៅរៀន ប៉ុន្តែឪពុកម្តាយមិនសូវមានឥទ្ធិពលទៅលើគុណភាពអប់រំឡើយ។

សិស្សបានប្រាប់ឱ្យដឹងអំពីកង្វះសៀវភៅមេរៀន។ បើទោះជាដូច្នេះក្តី នៅពេលដែលយើងបានសាកសួរអំពីការយល់ឃើញរបស់ពួកគេចំពោះគុណភាពអប់រំដែលពួកគេបានទទួល និងផ្តល់មូលហេតុសម្រាប់ការវិនិច្ឆ័យរបស់ពួកគេ ពុំមានក្រុមសិស្សណាមួយលើកឡើងអំពីសម្ភារៈបង្រៀន ថាជាមូលហេតុដែលធ្វើឱ្យពួកគេទទួលបានគុណភាពអប់រំមួយដ៏ល្អ មធ្យម ឬ អន់ខ្សោយឡើយ។

៥.១.៣.លទ្ធភាពសម្រប

ឪពុកម្តាយបានប្រាប់ឱ្យដឹងថា សាលារៀនមិនបានផ្តល់កិច្ចគាំទ្រ ឬ ភាពបត់បែនទន់ភ្លន់គ្រប់គ្រាន់ដើម្បីជួយដល់កុមារដែលពិការភ្នែក ថ្លង់ មានជម្ងឺឆ្កួតជ្រូក ឬកុមារពិការសតិបញ្ញាដើម្បីឱ្យពួកគេអាចទៅសាលារៀនបានឡើយ។ បន្ថែមពីនេះទៀតសាលារៀនក៏មិនបានជួយដល់ឪពុកម្តាយក្នុងការអប់រំកូននៅឯផ្ទះផងដែរ។ ពួកគេមានអារម្មណ៍ថាសាលារៀនពុំមានឧបករណ៍ ឬសម្ភារៈបរិក្ខារជាក់លាក់សម្រាប់កុមារពិការឡើយ បើទោះបីជាសាលារៀនមួយចំនួនដែលបានចុះធ្វើទស្សនកិច្ចមានទីជម្រាល និងបង្គន់អនាម័យសម្រាប់កុមារពិការក៏ដោយ។ យើងឃើញថាការឆ្លើយតបរបស់ប្រព័ន្ធអប់រំចំពោះសេចក្តីត្រូវការរបស់កុមារពិការ និងកុមារជនជាតិដើមភាគតិចនៅមានកម្រិតនៅឡើយ។

ជាញឹកញាប់កុមារពិការ និងឪពុកម្តាយរបស់ពួកគេរមែងតែងនិយាយថា គ្រូបង្រៀនមិនអាចសម្របការបង្រៀនដើម្បីជួយដល់ពួកគេបាន។ គ្រូបង្រៀនមួយចំនួនតូចបានប្រាប់ឱ្យដឹងថា ពួកគេបានទទួលការបណ្តុះបណ្តាលអំពីការអប់រំបញ្ចូលគ្នា ប៉ុន្តែពួកគេចង់រៀនសូត្របន្ថែមទៀត។ ជម្រើសមួយគឺត្រូវមានមជ្ឈមណ្ឌលធនធានមួយនៅក្នុងគ្រប់ខេត្តទាំងអស់ដែលអាចផ្តល់ការបណ្តុះបណ្តាលជូនដល់គ្រូបង្រៀនដែលមានសិស្សពិការ ឬអាចផ្តល់ព័ត៌មាន និងដំបូន្មាន និងអាចបង្កើតមេរៀនមួយជាក់លាក់សម្រាប់កិច្ចប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍។ បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលពិសេសអាចចុះធ្វើទស្សនកិច្ចតាមសាលារៀនដើម្បីផ្តល់កិច្ចគាំទ្រ និងដំបូន្មាន ជូនដល់គ្រូបង្រៀនរបស់កុមារពិការដែលស្រដៀងគ្នាទៅនឹង គ្រូបង្រៀនចល័តដែលអង្គការធ្លាប់បានប្រើប្រាស់នៅក្នុងគម្រោងមួយដែលពួកគេបានអនុវត្តនាពេលថ្មីៗនេះនិងដែលត្រូវបានអនុវត្តផងដែរនៅក្នុងប្រទេសដទៃទៀតដូចជាប្រទេសអង់គ្លេស។ នាពេលថ្មីៗនេះអង្គការគ្រួសារថ្មីបានចាប់ផ្តើមកម្មវិធីថ្មីមួយនៅក្នុងស្រុកចំនួន១២ដែលនៅក្នុងស្រុកទាំងនោះ អង្គការគ្រួសារថ្មីបានចាប់ដៃគូជាមួយការិយាល័យអប់រំស្រុក ដោយសហការជិតស្និទ្ធជាមួយបុគ្គលិក១រូប ដែលនឹងទទួលបានការបណ្តុះបណ្តាលបន្ថែមអំពីការអប់រំសម្រាប់កុមារពិការ(ជាពិសេសសម្រាប់កុមារខ្សោយចក្ខុវិញ្ញាណកុមារពិការភ្នែកនិងកុមារថ្លង់)។ បុគ្គលិកអង្គការគ្រួសារថ្មី១រូបនឹងចុះធ្វើទស្សនកិច្ចតាមសាលារៀនជាមួយបុគ្គលិកមន្ទីរអប់រំស្រុកម្នាក់នេះដើម្បីផ្តល់កិច្ចគាំទ្រ ហើយក្រោយមកបុគ្គលិកមន្ទីរអប់រំស្រុកនោះនឹងត្រូវចុះធ្វើការងារតែម្នាក់ឯង។

សិស្សក្រុមជនជាតិដើមភាគតិច ក៏បានប្រាប់ឱ្យដឹងផងដែរថា គ្រូបង្រៀនមិនអាចសម្របការបង្រៀនរបស់ខ្លួនដើម្បីជួយដល់ពួកគេបានឡើយ ឧទាហរណ៍ដូចជា ការប្រើប្រាស់ពាក្យពេចន៍ជាភាសាខ្មែរដែលពួកគេមិនយល់។ គេអាចជ្រើសរើសគ្រូបង្រៀនពីរភាសាបន្ថែមទៀត ហើយនៅពេលដែលកំពុងមានការបែងចែកគរុសិស្សគេអាចធ្វើការបម្រុងទុកកូតាមួយសម្រាប់គ្រូបង្រៀនពីរភាសា។ គ្រូបង្រៀនទាំងនេះអាចចូលរួមការ

បណ្តុះបណ្តាលប្រក្រតីរយៈពេល២ឆ្នាំមុនពេលចូលបម្រើការងារនិងការបណ្តុះបណ្តាលរយៈពេល២ខែបន្ថែមទៀតនៅចុងវគ្គដើម្បីផ្តោតលើការបង្រៀនភាសាជនជាតិដើមភាគតិច។

ទាក់ទងទៅនឹងការសម្របមាតិកាឱ្យស្របទៅតាមសេចក្តីត្រូវការរបស់សិស្ស សិស្សបានប្រាប់ឱ្យដឹងថា មេរៀនជំនាញបំណិនជីវិតមានសារៈប្រយោជន៍ចំពោះជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ និងអាចជួយដល់ពួកគេសន្សំប្រាក់បានមួយចំនួនតាមរយៈការកាត់បន្ថយទិញបន្លែពីទីផ្សារ។ ឪពុកម្តាយក៏យល់ឃើញផងដែរថា កុមារបានរៀនសូត្រជំនាញដ៏មានសារៈប្រយោជន៍ដែលអាចជួយដល់អាជីវកម្មគ្រួសារបាន។ បើទោះជាដូច្នេះក្តីសិស្សអនុវិទ្យាល័យជាច្រើនមានការព្រួយបារម្ភថា ពួកគេមិនបានរៀនសូត្រជំនាញណាមួយដែលមានសារៈប្រយោជន៍សម្រាប់ពួកគេ និង គ្រួសាររបស់ពួកគេនៅឡើយទេ។

## ៥.២. អនុសាសន៍

ផ្អែកលើគំហើញ និងការវិភាគពីការស្រាវជ្រាវរបស់យើង យើងសូមផ្តល់អនុសាសន៍ដូចខាងក្រោមដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន ការមានសេវា ភាពអាចទទួលយកបាន និងលទ្ធភាពសម្របនៃសេវាអប់រំក្នុងប្រទេសកម្ពុជា។

- ក្រសួងអប់រំ យុវជន និងកីឡា គួរផ្តល់មធ្យោបាយធ្វើដំណើរ និងអន្តេវាសិកដ្ឋាន ជាពិសេសសម្រាប់កុមារសិក្សានៅកម្រិតអនុវិទ្យាល័យ ដើម្បីជួយឱ្យពួកគេអាចបន្តសិក្សានៅឯសាលារៀន ជាពិសេសនៅដំណាក់កាលឆ្លងភូមិសិក្សាទៅកម្រិតអនុវិទ្យាល័យ។
- ក្រសួងអប់រំ យុវជន និងកីឡា គួរបន្តអនុវត្តគោលនយោបាយពង្រីកអាហារូបករណ៍របស់ខ្លួនដើម្បីជួយដល់សិស្សក្នុងការទិញសម្ភារៈរៀនសូត្រ ឯកសណ្ឋានសាលារៀន ឬ កង់។
- ក្រសួងអប់រំ យុវជន និងកីឡា គួរធ្វើយុទ្ធនាការដែលកំណត់គោលដៅនៅតំបន់ជនបទដើម្បីបញ្ចុះបញ្ចូលឪពុកម្តាយឱ្យចុះឈ្មោះកូនចូលរៀនថ្នាក់ទី១ នៅពេលដែលពួកគេមានអាយុ៦ឆ្នាំ ជាជាងនៅពេលដែលពួកគេមានអាយុ៧ឆ្នាំ ឬ ៨ឆ្នាំ។
- ក្រសួងអប់រំ យុវជន និងកីឡា គួរផ្តល់ការកសាងសមត្ថភាពជូនដល់គ្រូបង្រៀនអំពីការអប់រំបញ្ចូលគ្នា ដោយមានមេរៀនជាក់លាក់ដែលត្រូវបានបញ្ចូលនៅក្នុងកិច្ចប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍។
- យ៉ាងហោចណាស់គួរមានសាលារៀនមួយនៅក្នុងស្រុកនីមួយៗដែលផ្តល់ថ្នាក់អប់រំពិសេសសម្រាប់កុមារដោយផ្អែកលើប្រភេទពិការភាពរបស់ពួកគេ។
- ក្រសួងអប់រំ យុវជន និងកីឡា គួរកំណត់រកសាលារៀនដែលពួកគេអាចសាងសង់អន្តេវាសិកដ្ឋាន និងមានថ្នាក់អប់រំពិសេសសម្រាប់កុមារពិការនៅក្នុងសាលារៀនទូទៅមួយ។ ចំណុចនេះ មានន័យថាកុមារពិការអាចធ្វើសមាហរណកម្ម និងប្រាស្រ័យទាក់ទងជាមួយកុមារដទៃទៀត ប៉ុន្តែពួកគេមានថ្នាក់អប់រំពិសេស ដោយផ្អែកលើសេចក្តីត្រូវការរបស់ពួកគេ។
- ការត្រួតពិនិត្យទៅលើកុមារពិការគួរត្រូវបានធ្វើឡើងជាមួយនាយកដ្ឋានសុខភាពសិក្សា និងសហការជាមួយទីភ្នាក់ងារពាក់ព័ន្ធក្រសួងសុខាភិបាលនិងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវជ្រើសរើសគ្រូបង្រៀនបន្ថែមទៀត ជាពិសេសនៅតំបន់ជនបទ និងអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាលខណៈពេលកំពុងបម្រើការងារ ដើម្បីកសាងសមត្ថភាពគ្រូបង្រៀនរាប់បញ្ចូលទាំងគ្រូកិច្ចសន្យា/គ្រូសហគមន៍ផងដែរ។ គេអាចជ្រើសរើសគ្រូបង្រៀនពីរភាសាបន្ថែមទៀត ហើយគេអាចធ្វើការបម្រុងទុកកូតាមួយ សម្រាប់គ្រូបង្រៀនពីរភាសា។ គ្រូបង្រៀនទាំងនេះ អាចចូលរួមការបណ្តុះបណ្តាលប្រក្រតីរយៈពេល២ឆ្នាំមុនពេលចូលបម្រើការងារ និងការបណ្តុះបណ្តាលរយៈពេល២ខែបន្ថែមទៀតនៅចុងវគ្គ ដើម្បីផ្តោតលើការបង្រៀនភាសាជនជាតិដើម ភាគតិច។
- ក្រសួងអប់រំ យុវជន និងកីឡា គួរបញ្ចូលគ្រូបង្រៀនពីរភាសានៅក្នុងសហគមន៍ ឱ្យក្លាយជាមន្ត្រីរាជការស៊ីវិលពេញសិទ្ធិ។
- ក្រសួងអប់រំ យុវជន និងកីឡា គួរទទួលខុសត្រូវចំពោះការបោះពុម្ពសៀវភៅមេរៀន សម្រាប់ការអប់រំពីរភាសា និងសម្រាប់កុមារពិការ។ បច្ចុប្បន្ន អង្គការមិនមែនរដ្ឋាភិបាលគឺជាអ្នកផលិតសម្ភារៈទាំងនេះ ហើយក្រសួងអប់រំ យុវជន និងកីឡា គួរវិភាជន៍ថវិកាអប់រំរបស់ខ្លួនសម្រាប់ធ្វើការបោះពុម្ពសម្ភារៈទាំងនេះ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលជូនដល់គ្រូបង្រៀន។
- គប្បីមានឱកាសសម្រាប់កុមារ ក្នុងការទទួលបានការបណ្តុះបណ្តាលជំនាញនៅក្នុង ឬ ក្រៅសាលារៀន។ មជ្ឈមណ្ឌលសិក្សាសហគមន៍ គួរដើរតួនាទីសំខាន់ក្នុងការផ្តល់ការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធជូនដល់កុមារដែលនៅក្រៅសាលារៀន។

## ៦. ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ ការចូលរៀនលើសអាយុ និងការចុះឈ្មោះចូលរៀនសុទ្ធនៅកម្រិតបឋមសិក្សា

ជារៀងរាល់ឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ព ៖

ក. ចំនួនកុមារដែលមានអាយុចន្លោះពី៦-១១ឆ្នាំ (អាយុសមស្របសម្រាប់ការអប់រំកម្រិតបឋមសិក្សា)
ខ. អត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់កម្រិតបឋមសិក្សា
គ. ចំនួនកុមារចូលរៀនថ្នាក់ទី១ លើកដំបូង
ឃ. ចំនួនភាគរយកុមារចូលរៀនថ្នាក់ទី១ លើកដំបូង ដែលលើសអាយុ (អាយុច្រើនជាង៦ឆ្នាំ)។

ចំនួនកុមារអាយុចន្លោះពី៦-១១ឆ្នាំ ដែលមិនបានចូលរៀននៅសាលាបឋមសិក្សា ត្រូវបានគណនាតាមរយៈការគុណចំនួនកុមារអាយុចន្លោះពី ៦-១១ឆ្នាំ ទៅនឹងអត្រាចុះឈ្មោះចូលរៀនសុទ្ធនៅកម្រិតបឋមសិក្សា (ក x ខ)។ ចំនួនកុមារលើសអាយុដែលចូលរៀនថ្នាក់ទី១ ត្រូវបានគណនាតាមរយៈការគុណចំនួនកុមារចូលរៀនថ្នាក់ទី១ លើកដំបូង ទៅនឹងចំនួនភាគរយនៃកុមារចូលរៀនថ្នាក់ទី១ លើកដំបូងដែលលើសអាយុ (គ x ឃ)។ លទ្ធផលពីការគណនាទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងតារាងខាងក្រោម។

| ឆ្នាំសិក្សា | ចំនួនកុមារអាយុចន្លោះពី៦-១១ឆ្នាំ ដែលមិនបានចូលរៀននៅសាលាបឋមសិក្សា | ចំនួនកុមារលើសអាយុដែលចូលរៀនថ្នាក់ទី១ |
|---|---|---|
| **2008/09** | 104,778 | 135,060 |
| **2009/10** | 93,007 | 150,137 |
| **2010/11** | 90,038 | 94,755 |
| **2011/12** | 62,565 | 125,095 |
| **2012/13** | 38,086 | 103,529 |

នៅក្នុងឆ្នាំសិក្សា២០០៨-២០០៩ យោងតាមស្ថិតិ មានកុមារអាយុចន្លោះពី ៦-១១ឆ្នាំ ចំនួន ១០៤.៧៧៨ នាក់ មិនបានចូលរៀននៅសាលាបឋមសិក្សា។ យ៉ាងណាមិញ ក្នុងឆ្នាំសិក្សា២០០៩-២០១០ មានកុមារអាយុលើស៦ឆ្នាំចំនួន ១៥០.១៣៧នាក់ បានចូលរៀនសាលាបឋមសិក្សាជាលើកដំបូង។ គេមិនបានរំពឹងទុកឡើយថាចំនួនកុមារដែលបានចាប់ផ្តើមចូលរៀនលើសអាយុ៦ឆ្នាំ ក្នុងឆ្នាំសិក្សា២០០៩-២០១០ មានចំនួនច្រើនជាងកុមារអាយុ ចន្លោះពី៦-១១ឆ្នាំ ដែលមិនបានចូលរៀនកាលពីឆ្នាំមុន។ លទ្ធផលដែលគេមិនបានរំពឹងទុកស្រដៀងគ្នានេះ ក៏បានកើតឡើងនៅក្នុងឆ្នាំបន្តបន្ទាប់ផងដែរ។ ស្ថិតិទាំងនេះអាចមានសង្គតភាព ប្រសិនបើមានកុមារអាយុលើសពី ១១ឆ្នាំរាប់ពាន់នាក់ ចូលរៀនថ្នាក់ទី១ លើកដំបូង។

ខ្ទបសម្ព័ន្ធ២

ក្រសួងអប់រំ យុវជន និងកីឡា បានរាយការណ៍ឱ្យដឹងថា អត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា សម្រាប់ឆ្នាំសិក្សា២០១១-២០១២ មានចំនួន ៣,៧% ទូទាំងប្រទេសកម្ពុជា ក្នុងនោះ ៥,៣% សម្រាប់តំបន់ ទីក្រុង និង ៣,៥% សម្រាប់តំបន់ជនបទ។ តួលេខនេះ មានសង្គតភាពទៅនឹងអត្រាបោះបង់ការសិក្សា សម្រាប់គ្រប់ថ្នាក់ទាំងអស់នៅកម្រិតបឋមសិក្សា ដែលខ្ពស់ជាង ៣,៧% និងជាទូទៅមានចំនួនប្រមាណ ៨%។ តាមរយៈការប្រើប្រាស់អត្រាឡើងថ្នាក់សម្រាប់ថ្នាក់នីមួយៗនៅកម្រិតបឋមសិក្សា និងតួលេខអត្រាត្រួតថ្នាក់ គេអាចគណនាចំនួនកុមារដែលបោះបង់ការសិក្សាក្នុងថ្នាក់នីមួយៗ ព្រមទាំងឈានទៅធ្វើការគណនាអត្រាបោះបង់ការសិក្សាសរុបសម្រាប់កម្រិតបឋមសិក្សា។ តាមរយៈការគណនានេះនាំឱ្យទទួលបានអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាមានចំនួន ៧,៦% ទូទាំងប្រទេសកម្ពុជា (៦,៥% សម្រាប់ទីក្រុង និង ៧,៨% សម្រាប់តំបន់ជនបទ)។

អ្នកនិពន្ធ៖ អ្នកស្រីអាង សុផា លោកហ្គូដុង កូណូឈី កញ្ញាឈុំ ស៊ីរ៉ុម

អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធ៖ លោកជិន ច័ន្ទវាសនា លោកអ៊ុន វុត្ថា លោក រិច ចំរើន

អង្គការភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល (NEP) គឺជាអង្គការសមាជិកភាពមួយដែលលើកកម្ពស់ការពិភាក្សាយ៉ាងសកម្មពីសំណាក់អង្គការជាសមាជិករបស់ខ្លួនដែលធ្វើការងារក្នុងវិស័យអប់រំ និងជំនួសមុខឱ្យអង្គការជាសមាជិកក្នុងការតស៊ូមតិនៅក្នុងកិច្ចពិភាក្សាគោលនយោបាយនានាជាមួយក្រសួងអប់រំ យុវជន និងកីឡានៅកម្ពុជា។ មានអង្គការធ្វើការងារវិស័យអប់រំចំនួន១៣៩ ដែលជាសមាជិករបស់ NEP ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង:

sopha@nepcambodia.org

info@nepcambodia.org

Tel: 023 224 774

Website: www.nepcambodia.org

9 789996 361425

អ្នកនិពន្ធ៖ អាង សុផា, Gordon Conochie and ឈុំ ស៊ីរ៉ុម

NGO Education Partnership (NEP) គឺជាអង្គការសមាជិកភាពមួយដែលជំរុញអោយមានការសហការគ្នារវាងអង្គការក្រៅរដ្ឋាភិបាល ធ្វើការនៅក្នុងវិស័យអប់រំនិងតស៊ូមតិក្នុងនាមជាអង្គការសមាជិករបស់ខ្លួននៅក្នុងកិច្ចប្រជុំគោលនយោបាយនិងការពិភាក្សាជាមួយក្រសួងអប់រំយុវជន និង កីឡា (MoEYS) នៅក្នុងប្រទេសកម្ពុជា។ អង្គការក្រៅរដ្ឋាភិបាលចំនួន១៣៩ នៅកម្ពុជា បានធ្វើការលើវិស័យអប់រំជាសមាជិករបស់ NEP ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង

sopha@nepcambodia.org
info@nepcambodia.org
Tel: 023 224 774
Website: www.nepcambodia.org

9 789996 361425